**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# បច្ចុប្បន្នភាពនៃបទល្មើសក្នុងវិស័យ ព័ត៌មានវិទ្យានៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

| ស្រាវជ្រាវដោយ | ណែនាំដោយ |
| --- | --- |
| និស្សិតឈ្មោះ លោក **មិនា ម៉ារនិត** | លោក **ហ៊ាង ឡេង** |
| កញ្ញា **ឡៅ ស្រីលីន** | |

| | | | |
| --- | --- | --- | --- |
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | | ឆ្នាំចូលរៀន | ២០២០ |
| ជំនាន់ទី២៤ | | ឆ្នាំសរសេរសារណា | ២០២៤ |

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

**សារណាបញ្ចប់ការសិក្សា**

# បច្ចុប្បន្នភាពនៃបទល្មើសក្នុងវិស័យ ព័ត៌មានវិទ្យានៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **មិនា ម៉ារនិត**

កញ្ញា **ឡៅ ស្រីលីន**

ណែនាំដោយ

លោក **ហ៊ាង ឡេង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៤

ឆ្នាំចូលរៀន ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទ **មិនា ម៉ារនិត** និងនាងខ្ញុំ **ឡៅ ស្រីលីន** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញនីតិសាស្ត្រ ជំនាន់ទី២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០២០-២០២៤។

ជាបឋម យើងខ្ញុំសូមលំឱនកាយក្រាបប្រណិប័តន៍គោរពដល់ លោកអ្នកមានគុណទាំងទ្វេ គឺ **លោកឪពុក** និង **អ្នកម្ដាយ** ដែលលោកបានផ្ដល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា អប់រំ ទូន្មានប្រៀនប្រដៅ តាំងពីតូច រហូតដល់ពេលនេះ ហើយជាពិសេសលោកបាន ផ្ដត់ផ្ដង់ ជ្រោមជ្រែង និងទំនុកបម្រុងការសិក្សារៀនសូត្ររបស់យើងខ្ញុំតាំងពីបឋមសិក្សារហូតមកដល់ថ្នាក់ឧត្ដមសិក្សា។

សូមគោរពថ្លែងអំណរគុណចំពោះ **ឯកឧត្ដមបណ្ឌិត លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ព្រមទាំង លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ ដែលបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាព លះបង់ទាំងពេលវេលា និងកម្លាំង កាយចិត្ត ក្នុងការបង្ហាត់បង្រៀន ណែនាំ ទូន្មានប្រៀនប្រដៅ យ៉ាងយកចិត្តទុកដាក់ចំពោះនិស្សិតទាំងអស់ ក្នុងគោលបំណង បណ្ដុះបណ្ដាលឱ្យនិស្សិតគ្រប់រូបក្លាយជាធនធានមនុស្សសម្រាប់សង្គមជាតិ។

ជាពិសេស សូមគោរពថ្លែងអំណរគុណចំពោះ **លោកគ្រូសាស្ត្រាចារ្យ ហ៊ាខ ឡេខ** ជាសាស្ត្រាចារ្យណែនាំ ដែលបានលះបង់ពេលវេលាដ៏មានតម្លៃ ក្នុងការជួយណែនាំ ផ្ដល់ដំបូន្មាន ផ្ដល់យោបល់ សម្រាប់យើងខ្ញុំ ហើយលោកបានជួយកែលម្អកំហុសឆ្គងដែលកើតមានឡើង ដើម្បីឱ្យយើងខ្ញុំអាចរៀបចំក្នុងការស្រាវជ្រាវ ចងក្រងសារណាបញ្ចប់ការសិក្សាមួយនេះឡើង។

សូមសម្ដែងនូវអំណរគុណដ៏ជ្រាលជ្រៅចំពោះអ្នកនិពន្ធ និងប្រាជ្ញ ព្រមទាំងទស្សនៈវិទូ ទាំងឡាយ ដែលយើងខ្ញុំបាន សិក្សាស្រាវជ្រាវពីស្នាដៃរបស់លោក ក្នុងការបំពេញសារណាបញ្ចប់ការសិក្សានាពេលកន្លងមក។

ជាទីបញ្ចប់ យើងខ្ញុំសូមប្រសិទ្ធពរជ័យសិរីបវរជូនលោកអ្នកមានគុណ ឯកឧត្ដម លោកជំទាវ លោក លោកស្រី និងសាស្ត្រាចារ្យទាំងអស់ សូមបានប្រកបដោយជោគជ័យគ្រប់ភារកិច្ច និងសូមទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

នៅពេលដែលបច្ចេកវិទ្យាវាយលុកទៅក្នុងសង្គមកាន់តែស៊ីជម្រៅ វាបានជួយជំរុញឱ្យវិស័យជាច្រើនមានការរីកលូតលាស់ទៅមុខ និងជាកាតាលីករក្នុងការជំរុញសេដ្ឋកិច្ចផងដែរ។ ទន្ទឹមនឹងនេះ វាក៏បង្កើតឱ្យមានជាបទល្មើសផងដែរ ដោយសារតែជនទុច្ចរិតបានប្រើបច្ចេកវិទ្យាទំនើបនោះមកធ្វើជាឈ្នាន់ក្នុងប្រព្រឹត្តបទល្មើស។ ទោះបីជាការប្រព្រឹត្តនោះ មិនបានបង្កជារបួសស្នាមរូបរាងកាយ ប៉ុន្តែវាបានបង្កជាផលប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ កិត្តិយស របស់ជនរងគ្រោះជាខ្លាំង ពោលគឺប៉ះពាល់ទៅដល់សិទ្ធិឯកជនភាពរបស់ពួកគេ។

ដោយមើលឃើញថា ក្នុងទិដ្ឋភាពនៃការវិវត្តនៃបច្ចេកវិទ្យា កម្ពុជាក៏ដូចជាប្រទេសជាច្រើនដែរដែលកំពុងតែប្រឈមនឹងការកើនឡើងនៃឧក្រិដ្ឋកម្មបច្ចេកវិទ្យាព័ត៌មាន។ ក្នុងនាមយើងជាពលរដ្ឋម្នាក់នៅក្នុងសង្គមគួរគប្បីឈ្វេងយល់ តាមដាន ព្រមទាំងត្រៀមខ្លួនក្នុងការការពារខ្លួនពីការវាយប្រហាររបស់ជនទុច្ចរិតដែលបានប្រើបច្ចេកវិទ្យាមកប្រព្រឹត្តបទល្មើសផងដែរ។ ស្របពេលជាមួយគ្នានេះ **រាជរដ្ឋាភិបាលនីតិកាលទី៧** នៃរដ្ឋសភាបាននិងកំពុងយកចិត្តទុកដាក់ខ្ពស់តាមរយៈការដាក់ចេញនូវ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១** កំណត់យក **អាទិភាពគន្លឹះ ៥** គឺៈ "**មនុស្ស, ផ្លូវ, ទឹក, ភ្លើង** និង **បច្ចេកវិទ្យា**" ជាពិសេស គឺ **បច្ចេកវិទ្យាឌីជីថល** សម្រាប់ឆ្លើយតបទៅនឹងបដិវត្តឧស្សាហកម្មទី៤។ ស្របពេលជាមួយគ្នានេះដែរ យើងខ្ញុំទាំងពីរនាក់ ដែលជានិស្សិតថ្នាក់បរិញ្ញាបត្រឆ្នាំទី ៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានសិក្សាស្រាវជ្រាវ និងចងក្រងអត្ថបទសារណាស្តីពី **បច្ចុប្បន្នភាពនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា** ក្រោមការដឹកនាំរបស់លោក **ហ៊ាខ ឡេខ** ជាសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ដោយហេតុថា យើងខ្ញុំបានកត់សម្គាល់ឃើញថាបទល្មើសប្រភេទនេះបានកំពុងកើតឡើងជារៀងរាល់ថ្ងៃ ហើយជនរងគ្រោះ ទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីបទល្មើសនេះ។ បន្ថែមពីនេះ យើងខ្ញុំបានលើកយកបទដ្ឋានគតិយុត្តជាតិជាចម្បង និងធ្វើការបញ្ចូលជាមួយនឹងអត្ថបទ ក៏ដូចជាខ្លឹមសារនៃការសិក្សាស្រាវជ្រាវអន្តរជាតិក្នុងគោលបំណងជាប្រយោជន៍សម្រាប់និស្សិត ក៏ដូចជាសាធារណៈជនផងដែរ។

ជាកិច្ចបញ្ចប់ យើងខ្ញុំ ទន្ទឹងរង់ចាំនូវរាល់មតិទាំងឡាយក្នុងគោលបំណងស្ថាបនា ពីសំណាក់ឯកឧត្តមលោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា សាស្ត្រាចារ្យ សិស្ស និស្សិត និងមិត្តអ្នកអានទាំងអស់ដើម្បីជាការកែលម្អដល់រូបយើងខ្ញុំ។

# មាតិកា

ទំព័រ


សេចក្តីផ្តើម ........................................................................................................ ១

**ជំពូកទី១**

**ទិដ្ឋភាពទូទៅនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា**

**១.១ ការកកើត និងមូលហេតុនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា** .......... ៨

១.១.១ ការកកើតបទល្មើសក្នុងវិស័យព័ត៌មានវិទ្យា ........................................ ៩

១.១.២ មូលហេតុដែលនាំឱ្យមានបទល្មើសក្នុងវិស័យព័ត៌មានវិទ្យា ........................ ១០

**១.២ ក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា** ........ ១២

១.២.១ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ........................................ ១២

១.២.២ សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន ............................ ១៤

**១.៣ ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងលំហាចំពោះបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា** ........................................................................ ១៩

១.៣.១ បទល្មើសដែលបានប្រព្រឹត្ត ឬចាត់ថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ........... ១៩

១.៣.២ បទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ...................... ២០

**ជំពូកទី២**

**បច្ចុប្បន្នភាពនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា**

**២.១ បទល្មើសក្នុងវិស័យព័ត៌មានវិទ្យាបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា** ........................................................................ ២៤

២.១.១ បទចូលទៅដល់ ឬ ស្ថិតនៅនឹងប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ .................... ២៥

២.១.២ បទបង្កើតជាឧបសគ្គដល់ដំណើរការនៃប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ ................ ២៨

២.១.៣ បទបញ្ចូល លុបបំបាត់ ឬ កែប្រែដោយទុច្ចរិតនូវទិន្នន័យ ................................ ២៨

២.១.៤ បទចូលរួមក្នុងក្រុមប្រមូលផ្តុំ ឬ ក្នុងសន្ធិផ្តិភាពដើម្បីរៀបចំប្រព្រឹត្តបទល្មើស..................... ២៩

២.១.៥ ការប៉ុនប៉ង ........................................................................ ៣០

២.១.៦ ទោសបន្ថែម : ប្រភេទ និងរយៈពេល ................................................ ៣០

**២.២ អំពើថ្មីៗដែលជាផ្នែកនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា** ................ ៣១

២.២.១ បទល្មើសបច្ចេកវិទ្យាធំៗនៅកម្ពុជា ................................................ ៣២

២.២.១.១ ការដាក់ផ្លាក់លួចយកព័ត៌មាន (Phishing attack) ........ ៣៣
២.២.១.២ ការខលទូរសព្ទបញ្ឆោតលួចព័ត៌មាន (Vishing attack)........ ៣៤
២.២.១.៣ ការវាយប្រហារផ្អាកដំណើរការប្រព័ន្ធ (Distributed attack)........ ៣៤
២.២.១.៤ ការលួចអត្តសញ្ញាណ (Identify theft) ........ ៣៤
២.២.១.៥ មេរោគជម្រិតទារប្រាក់ (Ransomware attacks)........ ៣៤
**២.២.២ បទល្មើសបច្ចេកវិទ្យាធំៗកើតមាននាពេលបច្ចុប្បន្ននៅកម្ពុជា** ........ ៣៤
២.២.២.១ ការបរិហារកេរ្តិ៍លើបណ្តាញផ្សព្វផ្សាយសង្គម (Social Media Defamation) ........ ៣៥
២.២.២.២ ព័ត៌មានមិនពិត (Fake News)........ ៣៦
២.២.២.៣ ការជំរិត ឬ គំរាមកំហែងដោយប្រើប្រាស់រូបភាព ឬ វីដេអូអាសអាភាសរបស់ជនរងគ្រោះ និងគំរាមទារប្រាក់(Sex Extortion) ........ ៣៨
២.២.២.៤ អំពើគំរាមកំហែង ឬ យាយីប្រើមធ្យោបាយអ៊ីនធឺណែត (Cyberbully/CyberHarassment) ........ ៣៩
២.២.២.៥ អំពើឆបោកដោយប្រើប្រាស់មធ្យោបាយបច្ចេកវិទ្យា (Money Scam) ........ ៤១
**២.៣ ក្រសួង និងស្ថាប័នមានសមត្ថកិច្ចលើបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា** ........ ៤២
**២.៣.១ ក្រសួងមហាផ្ទៃ** ........ ៤២
២.៣.១.១ អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ........ ៤៣
២.៣.១.២ នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា........ ៤៤
**២.៤ នីតិវិធីនៃការដាក់ពាក្យបណ្តឹង** ........ ៤៥
**២.៤.១ ការដាក់ពាក្យបណ្តឹងដោយផ្ទាល់** ........ ៤៥
**២.៤.២ ការដាក់ពាក្យបណ្តឹងតាមប្រព័ន្ធអនឡាញ** ........ ៤៥

## ជំពូកទី៣

## ផលប៉ះពាល់ ការទប់ស្កាត់ និងវិធានការ ចំពោះបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា

**៣.១ ផលប៉ះពាល់នៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា** ........ ៤៩
**៣.១.១ ផលប៉ះពាល់ចំពោះបុគ្គលប្រើប្រាស់ផ្ទាល់ និងជីវភាពប្រចាំថ្ងៃ** ........ ៤៩
**៣.១.២ ផលប៉ះពាល់ចំពោះសង្គមជាតិ** ........ ៥១
**៣.២ ការទប់ស្កាត់ចំពោះបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា** ........ ៥១
**៣.២.១ បុគ្គលដែលប្រើប្រាស់ផ្ទាល់** ........ ៥១

៣.២.២ ក្រសួង និងស្ថាប័នដែលមានសមត្ថកិច្ច............................................................................................៥២
**៣.៣ ការដាក់ចេញនូវវិធានការរបស់រាជរដ្ឋាភិបាលកម្ពុជា**.....................................៥៣
៣.៣.១ ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥.................... ៥៣
៣.៣.២ គោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២២-២០៣៥ ..................................................... ៥៤
៣.៣.៣ យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា................. ៥៥
**សេចក្តីសន្និដ្ឋាន**.............................................................................................................................៥៧
**អនុសាសន៍**................................................................................................................................... ៥៩
**ឯកសារយោង**
**បញ្ជីឧបសម្ព័ន្ធ**

## បញ្ជីវាក្យស័ព្ទ

**ទិន្នន័យ** (Data) បណ្តុំលេខ អក្សរ និមិត្តសញ្ញា សារ រូបភាព សំឡេង វីដេអូ ព័ត៌មាន ឬ កម្មវិធីអេឡិកត្រូនិក ដែលត្រូវបានរៀបចំក្នុងទម្រង់សមស្របសម្រាប់ប្រើប្រាស់ក្នុងមូលដ្ឋានទិន្នន័យ ឬប្រព័ន្ធអេឡិកត្រូនិក។[១]

**ទូរគមនាគមន៍** (១) វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាក្នុងការបញ្ជូន និងទទួលស៊ីញ៉ាល់ ទិន្នន័យ សំឡេង រូបភាព ឬប្រភេទព័ត៌មានដទៃទៀតតាមរយៈការប្រើប្រាស់ថាមពលក្រោមរូបភាពទម្រង់អេឡិចត្រូម៉ាញ៉េទិក អគ្គិសនី វិទ្យុ ពន្លឺ ឬទម្រង់ដទៃទៀត។[២]

(២) ការផ្សាយ ការបញ្ជូន ឬការទទួលស៊ីញ៉ាល់ អក្សរ រូបភាព សំឡេង ឬព័ត៌មានគ្រប់គ្រប់ប្រភេទ តាមមធ្យោបាយខ្សែកាប តាមអុបទិក តាមវិទ្យុអគ្គិសនី ឬតាមប្រព័ន្ធអេឡិចត្រូនិកម៉ាញ៉េទិកផ្សេងៗទៀត។[៣]

**បច្ចុប្បន្នភាព** (នាម) ភាពនៃពេលដែលកំពុងតែមាននៅទីចំពោះមុខ គឺពេលឥឡូវនេះ។[៤]

**បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន** សំណុំនៃទំនិញ សេវា សម្ភារៈ ដែលបានប្រើប្រាស់សម្រាប់ផលិតទុកធ្វើប្រព្រឹត្តិកម្មចែកចាយ និងផ្លាស់ប្តូរព័ត៌មាន។[៥]

**បច្ចេកវិទ្យាព័ត៌មាន** (នាម) បច្ចេកទេសតាមបែបវិទ្យាសាស្ត្រ ដែលប្រើសម្រាប់បង្កើត ទទួល រក្សាទុក ប្រតិបត្តិ និងចែករំលែកព័ត៌មានតាមរយៈគ្រឿងអេឡិកត្រូនិករាប់បញ្ចូលទាំងកុំព្យូទ័រ ទូរសព្ទ ទូរទស្សន៍ វិទ្យុជាដើម។[៦]

**បរិយាបន្នកម្ម** (នាម) វិធានការឬគោលនយោបាយដែលរាប់បញ្ចូល ឬផ្តល់លទ្ធភាពដល់អ្នកពាក់ព័ន្ធទាំងអស់ដើម្បីទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចពីដំណើរការនៃការអនុវត្ត គម្រោងកម្មឬគោលនយោបាយ។[៧]

**ប្រព្រឹត្តិកម្ម** (នាម មើលពាក្យ ប្រព្រឹត្តកម្ម) ការប្រព្រឹត្តទៅ ដំណើរការ ការទទួល ការសម្អាត ការព្យាបាល។[៨]

**ប្រព័ន្ធ** (នាម) ចងរឹតរួត ចងឆ្វាក់ ចងក្រង។[៩]

---

[១] ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, *ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥*, (ភ្នំពេញ៖ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, ២០២១), លេខ១៤, ទំព័រទី៩៨។

[២] សន្ទានុក្រមគតិយុត្ត ក្រុមប្រឹក្សានីតិកម្ម២០២២។

[៣] សន្ទានុក្រមគតិយុត្ត ក្រុមប្រឹក្សានីតិកម្ម២០២២។

[៤] វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត។

[៥] សន្ទានុក្រមគតិយុត្ត ក្រុមប្រឹក្សានីតិកម្ម២០២២។

[៦] វចនានុក្រមខ្មែរ២០២២ ក្រុមប្រឹក្សាជាតិភាសាខ្មែរនៃរាជបណ្ឌិតសភាកម្ពុជា។

[៧] វចនានុក្រមខ្មែរ២០២២ ក្រុមប្រឹក្សាជាតិភាសាខ្មែរនៃរាជបណ្ឌិតសភាកម្ពុជា។

[៨] វចនានុក្រមខ្មែរ២០២២ ក្រុមប្រឹក្សាជាតិភាសាខ្មែរនៃរាជបណ្ឌិតសភាកម្ពុជា។

[៩] វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត។

**ប្រព័ន្ធ១** (នាម) បណ្តុំនៃវត្ថុ សម្ភារៈជាដើម ដែលអាចភ្ជាប់ ឬ ដំណើរការជាមួយគ្នា។ល។[១០]

**ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន** (បបព) សំដៅដល់អ្នកពាក់ព័ន្ធដំណើរការ និងបច្ចេកវិទ្យាដែលអាចផ្តល់នូវព័ត៌មានតាមតម្រូវការដោយស្វ័យប្រវត្តិ។[១១]

**ព័ត៌មានវិទ្យា** (នាម) វិទ្យាសាស្ត្រសិក្សាអំពីព័ត៌មាន។ ការសិក្សាទីនេះ សំដៅលើបច្ចេកទេសប្រមូលផ្តុំ រៀបចំ ដោះស្រាយទាក់ទងនឹងការកត់ត្រាតាមបែបឌីជីថល។[១២]

**រដ្ឋាភិបាលឌីជីថល** (Digital Government) ដំណើរការនៃការធ្វើទំនើបកម្មលើប្រព័ន្ធគ្រប់គ្រងរដ្ឋាភិបាល និងសេវាសាធារណៈ តាមរយៈការប្រើប្រាស់នូវបច្ចេកវិទ្យាឌីជីថល ដូចជាកុំព្យូទ័រ ឧបករណ៍ឆ្លាត និង ប្រព័ន្ធអ៊ីនធឺណិត សំដៅជួយសម្រួល ដល់ការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់រដ្ឋ ការសម្រេចចិត្ត និងការផ្តល់សេវាជូនប្រជាពលរដ្ឋ វិស័យឯកជន និងស្ថាប័នពាក់ព័ន្ធនានាប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងបរិយាបន្នកម្ម។[១៣]

**សន្និធិភាព** ដំណើរព្រមព្រៀងគ្នាដោយរបៀបណាមួយ។[១៤]

**ស្វ័យប្រវត្ត** (គុណនាម) ដែលកម្រើកឬដែលវិល, ដែលប្រព្រឹត្តទៅខ្លួនឯង។ល។[១៥]

**ស្វ័យប្រវត្តិ** (នាម) ភាវៈឬភាពនៃការប្រព្រឹត្តទៅដោយខ្លួនឯងដោយឥតដឹងអ្វី។[១៦]

**ឧក្រិដ្ឋកម្មសាយប័រ** (Cybercrime) បទល្មើស ដែលប្រព្រឹត្តនៅក្នុងបណ្តាញបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានដូចជា ការចូលលួច ក្លែងបន្លំ ឬ កែឯកសារ ការបញ្ចូលមេរោគ ការផ្ញើសារគំរាមកំហែង ឬចាប់ជំរិត ឬ ការធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សេដ្ឋកិច្ច និង សង្គមជាតិ។[១៧]

**ឧស្សាហកម្ម ៤.0** (Industry ៤.0) បរិបទនៃការវិវឌ្ឍឧស្សាហកម្មដែលបច្ចេកវិទ្យាអនុញ្ញាតឱ្យមានការបញ្ចូលគ្នានៃទិន្នន័យពីម៉ាស៊ីន ឧបករណ៍ និងសេនស័រ ពីខ្សែច្រវាក់ផលិតកម្ម និងពីការប្រើប្រាស់របស់មនុស្ស ហើយដែលផ្តល់ព័ត៌មានច្បាស់លាស់ និង

---

[១០] វចនានុក្រមខ្មែរ២០២២ ក្រុមប្រឹក្សាជាតិភាសាខ្មែរនៃរាជបណ្ឌិតសភាកម្ពុជា។

[១១] សន្ទានុក្រមគតិយុត្ត ក្រុមប្រឹក្សានីតិកម្ម២០២២។

[១២] វចនានុក្រមខ្មែរ២០២២ ក្រុមប្រឹក្សាជាតិភាសាខ្មែរនៃរាជបណ្ឌិតសភាកម្ពុជា។

[១៣] ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, *ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥*, (ភ្នំពេញ៖ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, ២០២១), លេខ២៦ ,ទំព័រទី៩៩។

[១៤] សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែកព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី។

[១៥] វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត។

[១៦] វចនានុក្រមខ្មែរ២០២២ ក្រុមប្រឹក្សាជាតិភាសាខ្មែរនៃរាជបណ្ឌិតសភាកម្ពុជា។

[១៧] ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, *ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥*, (ភ្នំពេញ៖ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, ២០២១), លេខ១២ ,ទំព័រទី៩៨។

ទាន់ពេល ដល់អ្នកផលិត និង អ្នកពាក់ព័ន្ធ សំដៅធ្វើឱ្យប្រសើរឡើងនូវខ្សែច្រវាក់ផលិតកម្មទាំងមូល។[១៨]

**អ៊ីនធឺណិត** (Internet) បណ្ដាញកុំព្យូទ័រសកលដែលភ្ជាប់គ្នាតាមរយៈពិធីសារគមនាគមន៍រួមមួយដើម្បីចែករំលែក និង ផ្ដល់ព័ត៌មាន។[១៩]

---

[១៨] ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, *ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥*, (ភ្នំពេញ៖ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, ២០២១), លេខ៨៤ ,ទំព័រទី១០១។

[១៩] ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥, (ភ្នំពេញ៖ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, ២០២១), លេខ៨៥ ,ទំព័រទី១០១។

# សេចក្ដីផ្ដើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ជាការពិតណាស់ នៅពេលដែលសម័យកាលមានការឈានទៅមុខបន្តិចម្ដងៗ ពីមួយសម័យកាលទៅមួយសម័យកាល យើងតែងសង្កេតឃើញថា បណ្ដាប្រទេសនានានៅសាកលលោកមានការអភិវឌ្ឍលើវិស័យជាច្រើន ក៏ដូចជាមានភាពរីកចម្រើនគួរឱ្យកត់សម្គាល់ផងដែរ។ ក្នុងនោះដែរធ្វើការសង្កេតឃើញថាមានការអភិវឌ្ឍ និងមានភាពរីកចម្រើនលើវិស័យជាច្រើនដូចជា វិស័យឧស្សាហកម្ម វិស័យសេដ្ឋកិច្ច វិស័យនគរូបនីយកម្ម វិស័យសង្គមកិច្ច វិស័យយុត្តិធម៌ វិស័យការងារ វិស័យអប់រំ វិស័យសុខាភិបាល វិស័យព័ត៌មានវិទ្យា និងទៅលើវិស័យជាច្រើនទៀត។ តែអ្វីដែលពិសេសនោះ ឃើញថាមានភាពរីកចម្រើន និងមានការអភិវឌ្ឍលើសពីការរំពឹងទុកនោះ គឺទៅលើវិស័យព័ត៌មានវិទ្យា ក្នុងទ្រង់ទ្រាយមួយដ៏ធំប៉ុន្មានឆ្នាំចុងក្រោយនេះ។ ទន្ទឹមនឹងការអភិវឌ្ឍ និងភាពរីកចម្រើនទៅលើវិស័យនេះ យើងតែងតែឃើញមានបញ្ហាកើតឡើងទោះតិចក្ដី ឬច្រើនក្ដីតែងតែកើតឡើងទន្ទឹមគ្នា។ មានបណ្ដាប្រទេសជាច្រើនក្នុងសាកលលោកមានការអភិវឌ្ឍ និងមានការរីកចម្រើនយ៉ាងខ្លាំងក្នុងវិស័យព័ត៌មានវិទ្យាក្នុងនោះគឺទៅលើបច្ចេកវិទ្យា ឬប្រព័ន្ធបច្ចេកវិទ្យាដែលជាផ្នែកមួយនៃវិស័យព័ត៌មានវិទ្យាផងដែរ ដោយឡែកយើងឃើញថា មិនថាប្រទេសមហាអំណាចក្ដី ឬប្រទេសមិនមហាអំណាចក្ដីតែងតែឃើញបណ្ដាប្រទេសទាំងអស់នោះ មានការព្យាយាមខិតខំក្នុងការអភិវឌ្ឍទៅលើផ្នែកបច្ចេកវិទ្យា ក្នុងរូបភាពមួយដែលមនុស្សទូទៅអាចយល់ដឹងនិងសិក្សាបាន ឬក្នុងរូបភាពម្យ៉ាងទៀតដែលមនុស្សទូទៅពិបាកក្នុងការយល់ដឹងនិងសិក្សាផងដែរ។[២០] នាពេលបច្ចុប្បន្ននេះ បណ្ដាប្រទេសជាច្រើនមានបញ្ហាជាច្រើនបានកំពុងនឹងកើតឡើងជាបន្តបន្ទាប់ ដោយសារតែភាពទំនើបកម្មនៃបច្ចេកវិទ្យាសម័យថ្មី ក៏ដូចជាមានការអភិវឌ្ឍ និងមានភាពរីកចម្រើនខ្លាំងក្លាលើសពីការរំពឹងទុករបស់មនុស្សទូទៅ។

វិស័យព័ត៌មានវិទ្យា យើងឃើញថាមានវិសាលភាពធំទូលាយដោយហេតុថា វិស័យព័ត៌មានវិទ្យាមានលក្ខណៈបែបវិទ្យាសាស្ត្រ មិនតែប៉ុណ្ណោះមានលក្ខណៈបត់បែន អភិវឌ្ឍទៅតាមសម័យកាលយ៉ាងឆាប់រហ័សផងដែរ។[២១] វិស័យព័ត៌មានវិទ្យា បានផ្លាស់ប្ដូរការរស់នៅរបស់មនុស្សគ្រប់រូបឱ្យមានភាពទាន់សម័យទៅតាមសម័យកាល និងបានជំរុញឱ្យមនុស្សគ្រប់រូបមានការរស់នៅតាមបែបថ្មី យល់ដឹងអំពីទំនើបកម្មនៃបច្ចេកវិទ្យា ជាពិសេសព្រមទាំងស្របទៅតាមបរិបទនៃបដិវត្តន៍ឧស្សាហកម្ម៤.០ផងដែរ។[២២] សព្វថ្ងៃនេះការរីកចម្រើនបានឈានទៅមុខដោយមានសក្ដានុពលយ៉ាងខ្លាំង ដោយសារតែសកម្មភាពរីកចម្រើន និង

[២០] https://shorturl.at/VZW២c (ចូលទស្សនាថ្ងៃទី១៥ មីនា ២០២៤)។

[២១] https://shorturl.at/jCA0B (ចូលទស្សនាថ្ងៃទី១៥ មីនា ២០២៤)។

[២២] https://shorturl.at/FE៣re (ចូលទស្សនាថ្ងៃទី១៥ មីនា ២០២៤)។

សកម្មភាពនៃការអភិវឌ្ឍដែលកើតចេញពីសកម្មភាពរបស់មនុស្សទាំងនេះហើយដែលនាំឱ្យមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សក្នុងលក្ខណៈទ្រង់ទ្រាយដ៏ធំ។ ទន្ទឹមនឹងគ្នានេះ ឥទ្ធិពលនៃវិស័យព័ត៌មានវិទ្យាបានបង្កឱ្យមានផលវិជ្ជមាន និងផលអវិជ្ជមានផងដែរ ហើយផលអវិជ្ជមាននេះហើយ ដែលធ្វើឱ្យកើតមានជាបទល្មើសក្នុងវិស័យព័ត៌មានវិទ្យា នេះជាបញ្ហាដែលត្រូវយកចិត្តទុកដាក់ខ្ពស់ ត្រូវយកមកវិភាគ និងដាក់ចេញនូវដំណោះស្រាយក្នុងការគ្រប់គ្រងទៅលើបញ្ហាទាំងនេះ។[២៣] ក្នុងសម័យបច្ចុប្បន្ននេះ មនុស្សទូទាំងពិភពលោករស់នៅក្នុងសម័យបែបទំនើបដែលមានបច្ចេកវិទ្យាទំនើបកម្មខ្ពស់ និងភាពជឿនលឿនសម្បូរបែបសព្វគ្រប់បែបយ៉ាង មួយវិញទៀត ភាពជឿនលឿន ក៏ដូចជា ទំនើបកម្មនៃបច្ចេកវិទ្យា[២៤] ពិតជាបង្កភាពងាយស្រួលដល់មនុស្សទូទាំងពិភពលោកក្នុងការរស់នៅប្រចាំថ្ងៃ ដើម្បីប្រាស្រ័យទាក់ទងគ្នាបានពីប្រទេសមួយទៅប្រទេសមួយ ឬពីទីបមួយទៅទីបមួយទៀតបាន គឺដោយការទាក់ទងគ្នាតាមប្រព័ន្ធអ៊ីនធឺណិត (Internet) យ៉ាងងាយស្រួល ដោយគ្រាន់តែបញ្ចូលព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់តាមប្រព័ន្ធទំនាក់ទំនងសង្គមហ្វេសបុក (Facebook), តេឡេក្រាម (Telegram) ជាដើម ឬតាមរយៈប្រព័ន្ធទូរសព្ទ។[២៥] ព័ត៌មានវិទ្យា ឬ បច្ចេកវិទ្យាព័ត៌មានវិទ្យា ក្នុងពិភពលោកកំពុងមានការរីកចម្រើនយ៉ាងឆាប់រហ័ស ជាពិសេសក្នុងយុគសម័យបដិវត្តន៍ឧស្សាហកម្មជំនាន់៤.០ ត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយក្នុងប្រព័ន្ធគ្រប់គ្រងការងារ ការបែងចែកការងារ ការគ្រប់គ្រងទិន្នន័យ និងការប្រាស្រ័យទាក់ទងជាសាធារណៈ និងមានជាច្រើនទៀត។ ពិតណាស់ បច្ចេកវិទ្យាពិតជាបង្កលក្ខណៈងាយស្រួល និងកាត់បន្ថយការចំណាយពេលវេលា ហើយថែមទាំងទទួលបានអត្ថប្រយោជន៍ជាច្រើនពីបច្ចេកវិទ្យាទាំងនោះ។[២៦]

ដោយឡែកយ៉ាងណាមិញ មានមនុស្សមួយចំនួនបានយកភាពជឿនលឿននៃព័ត៌មានវិទ្យា ឬ បច្ចេកវិទ្យាព័ត៌មានទាំងនោះប្រើប្រាស់ក្នុងផ្លូវមិនល្អ ដែលបង្កឱ្យមានជាបទល្មើសផ្សេងៗ ដែលជាហេតុនាំឱ្យមានបញ្ហាដល់អ្នកប្រើប្រាស់ផ្ទាល់ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសង្គម។[២៧] សព្វថ្ងៃនេះ ប្រទេសកម្ពុជា ជាប្រទេសដែលកំពុងអភិវឌ្ឍ និងបន្តអភិវឌ្ឍជាបន្តបន្ទាប់ ទន្ទឹមនឹងគ្នានោះ ក៏កើតមានឡើងនូវឧក្រិដ្ឋកម្មសាយប័រ ដែលជាផ្នែកនៃបទល្មើសតាមបច្ចេកវិទ្យាព័ត៌មាននៅកម្ពុជា ហើយបាន និងកំពុងកើតមានឡើងជាហូរហែ ដែលជាក្តីកង្វល់របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងបរិបទថ្មីនៃសម័យបច្ចេកវិទ្យា។

[២៣] https://www.comptia.org/content/articles/what-is-information-technology (ចូលទស្សនាថ្ងៃទី១៥ មីនា ២០២៤)។

[២៤] https://shorturl.at/NMlmY (ចូលទស្សនាថ្ងៃទី១៥ មីនា ២០២៤)។

[២៥] freshnewsasia.com) (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[២៦] https://www.information.gov.kh/articles/៣២១០០ (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[២៧] យល់ដឹងផ្នែកច្បាប់៖ បទល្មើសក្នុងវិស័យព័ត៌មានវិទ្យា (freshnewsasia.com) (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយមើលឃើញពីភាពចាំបាច់ និងចំណុចមួយចំនួនដែលយើងគួរលើកយកមកពិចារណា ចំពោះប្រធានបទខាងលើ ទើបយើងសម្រេចចោទបានឡើងនូវចំណោទបញ្ហាចំនួន ៣ ដើម្បីធ្វើការឆ្លើយតបទៅនឹងប្រធានបទនោះ។ សំណួរស្រាវជ្រាវមានដូចតទៅ៖

១. តើទិដ្ឋភាពទូទៅនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជាមានសញ្ញាណដូចម្តេច?

២. តើបច្ចុប្បន្នភាពនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជាមានរូបភាពយ៉ាងដូចម្តេចខ្លះ?

៣. តើមានផលប៉ះពាល់ និងវិធានការទប់ស្កាត់យ៉ាងដូចម្តេចខ្លះចំពោះបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវដែលកំណត់យកនូវប្រធានបទដែលស្តីអំពី **បច្ចុប្បន្នភាពនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា** គឺក្នុងគោលបំណងដើម្បីធ្វើការសិក្សាស្រាវជ្រាវទៅលើទិដ្ឋភាពទូទៅនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា ព្រមទាំងបច្ចុប្បន្នភាពនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា និងបង្ហាញពីផលប៉ះពាល់ដែលបណ្តាលមកពីបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា ជាពិសេសនឹងលើកឡើងពីវិធានការទប់ស្កាត់ចំពោះបទល្មើសនេះផងដែរ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ដោយមើលឃើញថាបទល្មើសក្នុងវិស័យព័ត៌មានវិទ្យា មានការកកើតឡើងជាច្រើន ក្រោមរូបភាពថ្មីៗក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ដូច្នេះ ក្រុមយើងខ្ញុំនឹងសូមសិក្សាស្រាវជ្រាវ តែទៅលើបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជាដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា រួមជាមួយនឹងអំពើថ្មីៗដែលជាផ្នែកនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជានៅដើមឆ្នាំ២០២២ រហូតមកដល់ពាក់កណ្តាលឆ្នាំ២០២៤ តែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ប្រធានបទស្តីអំពី **បច្ចុប្បន្នភាពនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា** បានដើរតួនាទីយ៉ាងសំខាន់ក្នុងការបញ្ជ្រាបការយល់ដឹងបន្ថែមទៅដល់ មិត្តនិស្សិតដែលសិក្សាជំនាញនីតិសាស្ត្រ អ្នកសិក្សាស្រាវជ្រាវផ្នែកច្បាប់ ក៏ដូចជាគ្រប់បុគ្គលដែលមានបំណងចង់យល់អំពីផ្នែកច្បាប់ និងយុត្តិធម៌ផងដែរ ជាពិសេសពាក់ព័ន្ធនឹងបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ និងចងក្រងសារណាមួយនេះឡើង ត្រូវបានរៀបចំដោយយកចិត្តទុកដាក់ ជាមួយនឹងការប្រមូលឯកសារពាក់ព័ន្ធទាំងជាតិ និងអន្តរជាតិ ដែលមានប្រភពច្បាស់លាស់គួរឱ្យទុកចិត្តបានជាពិសេស បទដ្ឋានគតិយុត្តជាតិ ដែលចូលជាធរមានរួចមកហើយ ជួបផ្សំជាមួយឯកសារផ្លូវការ ស្នាដៃសៀវភៅដែលបានរៀបរៀងឡើងដោយសាស្ត្រាចារ្យផ្នែកនីតិសាស្ត្រ និងព័ត៌មានតាមប្រព័ន្ធអ៊ីនធឺណែត ដែលច្បាស់ការ និងទុកចិត្តបាន។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្រោយពីទទួលបានការណែនាំពីសាស្ត្រាចារ្យ **ហ៊ាង ឡេង** យើងខ្ញុំទាំងពីរនាក់បានសម្រេចបែងចែករចនាសម្ព័ន្ធនៃការស្រាវជ្រាវដូចខាងក្រោម៖

- **សេចក្តីផ្តើម**
- **ជំពូកទី១ ទិដ្ឋភាពទូទៅនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា៖** នៅក្នុងជំពូកនេះ ក្រុមយើងខ្ញុំសូមបកស្រាយអំពី ការកកើត និងមូលហេតុនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា និងក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា ព្រមទាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងលំហាចំពោះបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា។
- **ជំពូកទី២ បច្ចុប្បន្នភាពនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា៖** នៅក្នុងជំពូកនេះ ក្រុមយើងខ្ញុំសូមបកស្រាយអំពីបទល្មើសក្នុងវិស័យព័ត៌មានវិទ្យាបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, អំពើថ្មីៗដែលជាផ្នែកនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា, ក្រសួង និងស្ថាប័នដែលមានសមត្ថកិច្ចលើបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា និងនីតិវិធីនៃការដាក់ពាក្យបណ្តឹងចំពោះបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា។
- **ជំពូកទី៣ ផលប៉ះពាល់ ការទប់ស្កាត់ និងវិធានការចំពោះបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា៖** ដែលបរិយាយអំពី ផលប៉ះពាល់នៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា, ការទប់ស្កាត់ចំពោះបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា និងការដាក់ចេញនូវវិធានការរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា។

# ជំពូកទី១

# ទិដ្ឋភាពទូទៅនៃបទល្មើស
# ក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា

# ជំពូកទី១
# ទិដ្ឋភាពទូទៅនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា

បទល្មើសក្នុងវិស័យព័ត៌មានវិទ្យា គឺជាប្រភេទបទល្មើសមួយប្រភេទដែលគ្មានរបួសស្នាមខាងក្រៅទេ តែដោយឡែក បទល្មើសក្នុងវិស័យព័ត៌មានវិទ្យាបានបង្កព្យសនកម្មដល់សិទ្ធិឯកជនភាពយ៉ាងខ្លាំង ឬប៉ះពាល់ដល់កិត្តិយស កេរ្តិ៍ឈ្មោះរបស់ជនរងគ្រោះ។ ទៀតសោត បទល្មើសក្នុងវិស័យព័ត៌មានវិទ្យាបានបង្ហាញឱ្យឃើញអំពីធាតុសត្យានុម័ត និងធាតុអត្តនោម័ត គឺថាមានលក្ខណៈពិសេសគួរឱ្យកត់សម្គាល់។ បទល្មើសក្នុងវិស័យព័ត៌មានវិទ្យា អាចមានការកើតឡើងតាមរូបភាពជាច្រើន ដោយបទល្មើសនេះកើតឡើងតាមរយៈការប្រើប្រាស់មធ្យោបាយដូចជាការប្រើប្រាស់បច្ចេកវិទ្យា ការប្រើប្រាស់ប្រព័ន្ធទូរគមនាគមន៍ និងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណែតជាអាទ៍។[២៨] បទល្មើសក្នុងវិស័យព័ត៌មានវិទ្យា គឺជាបទល្មើសព្រហ្មទណ្ឌដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាជាធរមាន។ យើងសង្កេតឃើញថា បច្ចុប្បន្ននេះមានករណីជាច្រើនដែលកើតមានឡើងមានរូបភាពដូចជា ការលួចចូលក្នុងទិន្នន័យឯកជនរបស់បុគ្គលដទៃទៀតដែលបទល្មើសនេះកំពុងតែកើតមានឡើងជាបន្តបន្ទាប់។ បន្ថែមពីនោះ មិនត្រឹមតែមានការលួចចូលក្នុងទិន្នន័យឯកជនប៉ុណ្ណោះទេ ថែមទាំងមានការលួចយកទៅប្រើប្រាស់ក្រោមរូបភាពជាបទល្មើសឆបោក ឬចាប់ជំរិតទាមទារប្រាក់ផ្សេងៗដែលបណ្តាលឱ្យមានភាពវឹកវរក្នុងសង្គម ក៏ដូចជាប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ម្ចាស់សាមីគណនីជាដើម។[២៩] ម្យ៉ាងវិញទៀតបច្ចេកវិទ្យាក៏ជាមុខព្រួញយ៉ាងសំខាន់ដែលបង្កឱ្យមានបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជាផងដែរ។[៣០] បច្ចេកវិទ្យាអាចនាំយើងឱ្យមានភាពងាយស្រួលក្នុងការរស់នៅប្រចាំថ្ងៃក្នុងការបំពេញការងារ និងក្នុងការប្រាស្រ័យទាក់ទងគ្នា ហើយក៏អាចបង្កជាហានិភ័យដល់មនុស្សក្នុងសង្គមបានផងដែរ ប្រសិនបើយើងយកភាពជឿនលឿននៃទំនើបកម្មបច្ចេកវិទ្យានេះទៅប្រើប្រាស់ក្នុងផ្លូវមិនល្អ។[៣១]

ដោយឡែក ឧក្រិដ្ឋកម្មសាយប័រ គឺជាបទល្មើសដែលប្រព្រឹត្តនៅក្នុងបណ្តាញបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន រួមមាន ការចូលឬស្ថិតនៅ, ការលួច, ការក្លែងបន្លំ, ការកែឯកសារឬទិន្នន័យ, ការលុបបំបាត់ឯកសារឬទិន្នន័យ, ការបញ្ចូលមេរោគ, ការបង្កើតជាឧបសគ្គ, ការផ្ញើសារគំរាម, ការចាប់ជំរិតឬរាល់អំពើទាំងឡាយណា

---

[២៨] THOMAS J. HOLT AND ADAM M. BOSSLER, *Cybercrime in progress: theory and prevention of technology-enabled offenses / Thomas J. Holt and Adam M. Bossler* (New York: Routledge, first published ២០១៦), page១-២។

[២៩] យល់ដឹងផ្នែកច្បាប់៖ បទល្មើសក្នុងវិស័យព័ត៌មានវិទ្យា (freshnewsasia.com) (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[៣០] យល់ដឹងផ្នែកច្បាប់៖ បទល្មើសក្នុងវិស័យព័ត៌មានវិទ្យា (freshnewsasia.com) (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[៣១] យល់ដឹងផ្នែកច្បាប់៖ បទល្មើសក្នុងវិស័យព័ត៌មានវិទ្យា (freshnewsasia.com) (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

ដែលបង្កជាបញ្ហាដល់ប្រព័ន្ធប្រព្រឹត្តិកម្មដោយស្វ័យប្រវត្តនៃទិន្នន័យដែលធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ និង សណ្តាប់ធ្នាប់សង្គមជាតិ ព្រមទាំងប៉ះពាល់សិទ្ធិឯកជនភាពផងដែរ។[៣២]

ទោះបីយ៉ាងណាក្តីរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងដែលមានសមត្ថកិច្ចពាក់ព័ន្ធ បានព្យាយាម ខិតខំប្រឹងប្រែងដោះស្រាយរាល់បញ្ហាទាំងអស់នោះជូនចំពោះប្រជាពលរដ្ឋផងដែរ ដោយរាជរដ្ឋាភិបាលបានធ្វើ ការការពារ ទប់ស្កាត់ ផ្សព្វផ្សាយ បង្ការ បង្ក្រាប និងជាពិសេសធ្វើការតាក់តែងលិខិតបទដ្ឋានគតិយុត្តដែល ពាក់ព័ន្ធនឹងបញ្ហាទាំងនេះផងដែរ។ ដោយថ្មីៗនេះ ស្ថាប័នដែលមានសមត្ថកិច្ចលើបញ្ហានេះបានធ្វើការពិគ្រោះ យោបល់អំពីសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន ដើម្បីធ្វើការប្រយុទ្ធប្រឆាំងបទល្មើស បច្ចេកវិទ្យាព័ត៌មាន។ ចំពោះ សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន គឺមាន៩ជំពូកនិង៥៥មាត្រា ដែលមានគោលបំណង ធានាសុចរិតភាពនៃការប្រើប្រាស់ ការគ្រប់គ្រងប្រព័ន្ធកុំព្យូទ័រ ទិន្នន័យកុំព្យូទ័រ និង ការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងការពារសិទ្ធិសេរីភាពរបស់បុគ្គល ដោយកំណត់អំពី វិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាប បទល្មើសបច្ចេកវិទ្យាព័ត៌មាន។ សេចក្តីព្រាងច្បាប់នេះមានវិសាលភាព អនុវត្តរាល់សកម្មភាពទាំងអស់ដែលពាក់ព័ន្ធនឹងបទល្មើសបច្ចេកវិទ្យាព័ត៌មានដែលប្រព្រឹត្តនៅក្នុងឬនៅក្រៅ ដែនដីនៃព្រះរាជាណាចក្រកម្ពុជា។[៣៣] យ៉ាងណាមិញ គួសបញ្ជាក់ផងដែរថាពាក្យ ព័ត៌មានវិទ្យា (Information Technology) ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ មិនបានបញ្ញត្តិជាក់លាក់ និងមិនទាន់ផ្តល់ នូវជាអត្ថន័យ ឬនិយមន័យនៃពាក្យ ព័ត៌មានវិទ្យា (Information Technology) ច្បាស់លាស់នៅឡើយទេ។ ដោយឡែក យើងសង្កេតឃើញថា ពាក្យ **ព័ត៌មានវិទ្យា** បើតាមវចនានុក្រមខ្មែរ២០២២ដោយក្រុមប្រឹក្សាជាតិ ភាសាខ្មែរនៃរាជបណ្ឌិតសភាកម្ពុជា បានផ្តល់នូវនិយមន័យថា (ន) ជាវិទ្យាសាស្រ្តសិក្សាព័ត៌មាន ការសិក្សា ព័ត៌មានទីនេះ សំដៅទៅលើបច្ចេកទេសប្រមូលផ្តុំ រក្សាទុក រៀបចំ ដោះស្រាយទាក់ទងនឹងការកត់ត្រាតាមបែប ឌីជីថល។[៣៤] រីឯ ពាក្យ **បច្ចេកវិទ្យាព័ត៌មានវិទ្យា** បើតាមវចនានុក្រមខ្មែរ២០២២ដោយក្រុមប្រឹក្សាជាតិភាសាខ្មែរ នៃរាជបណ្ឌិតសភាកម្ពុជា បានផ្តល់នូវនិយមន័យថា (ន) ជាបច្ចេកទេសតាមបែបវិទ្យាសាស្រ្ត ដែលប្រើសម្រាប់ បង្កើត ទទួល រក្សាទុក ប្រតិបត្តិ និងចែករំលែកព័ត៌មានតាមរយៈគ្រឿងអេឡិកត្រូនិករាប់បញ្ចូលទាំងកុំព្យូទ័រ ទូរសព្ទ ទូរទស្សន៍ វិទ្យុជាដើម។[៣៥] យើងធ្វើការសន្និដ្ឋានបានថា ពាក្យ ព័ត៌មានវិទ្យា ឬបច្ចេកវិទ្យាព័ត៌មានវិទ្យា

---

[៣២] ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, *ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥,* (ភ្នំពេញ៖ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ២០២១), លេខ១២, ទំព័រទី៩៨។

[៣៣] https://nw.ax/4AI (ចូលទស្សនានៅថ្ងៃទី២៣ មីនា ២០២៤)។

[៣៤] វចនានុក្រមខ្មែរ២០២២ ក្រុមប្រឹក្សាជាតិភាសាខ្មែរនៃរាជបណ្ឌិតសភាកម្ពុជា។

[៣៥] វចនានុក្រមខ្មែរ២០២២ ក្រុមប្រឹក្សាជាតិភាសាខ្មែរនៃរាជបណ្ឌិតសភាកម្ពុជា។

មានវិសាលភាពទូលំទូលាយ ហើយទៀតសោតមានការផ្តល់នូវនិយមន័យផ្សេងៗគ្នាតែមានភាពស្រដៀងគ្នា។ ដូច្នេះយើងធ្វើការសន្និដ្ឋានបានថាពាក្យ ព័ត៌មានវិទ្យា ឬបច្ចេកវិទ្យាព័ត៌មានវិទ្យា គឺជាវិទ្យាសាស្ត្រក្នុងការសិក្សាព័ត៌មាន លក្ខណៈបច្ចេកទេសប្រមូលផ្តុំ រៀបចំ ដោះស្រាយទាក់ទងនឹងការកត់ត្រាតាមបែបឌីជីថលគ្រប់គ្រងការប្រើប្រាស់ទិន្នន័យបច្ចេកវិទ្យា ដើម្បីទទួលបានគ្រប់ព័ត៌មានដោយការប្រើប្រាស់មធ្យោបាយដូចជា កុំព្យូទ័រ ប្រព័ន្ធទូរគមនាគមន៍ ប្រព័ន្ធអ៊ីនធឺណែត បច្ចេកវិទ្យា ឌីជីថល និងឧបករណ៍ជាច្រើនផ្សេងៗទៀត។

ជាមូលដ្ឋានគ្រឹះ ជំនួយក្នុងការឈ្វេងយល់ទៅលើប្រធានបទនេះទាំងស្រុងឱ្យមានលក្ខណៈស៊ីជម្រៅអំពី ទិដ្ឋភាពទូទៅនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា ជាបឋម គួរគប្បីធ្វើការសិក្សាស្រាវជ្រាវអំពី **ការកកើត និងមូលហេតុនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា** (១.១) បន្ទាប់មកធ្វើការសិក្សាស្រាវជ្រាវអំពី **ក្របខណ្ឌច្បាប់ពាក់ព័ន្ធបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា** (១.២) និងជាចុងក្រោយយើងនឹងធ្វើការសិក្សាស្រាវជ្រាវអំពី **ការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងលំហាចំពោះបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា** (១.៣)។

## ១.១ ការកកើត និងមូលហេតុនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា

គួសបញ្ជាក់ផងដែរថា ប្រទេសកម្ពុជា ជាប្រទេសមួយដែលបានឆ្លងកាត់ក្រោមភ្លើងសង្គ្រាមដ៏សែនជូរចត់នៅអំឡុងឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ក្រោយពីបានរួចផុតពីភ្លើងសង្គ្រាមឆ្នាំ១៩៧៩ បានបញ្ចប់នៅឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការរៀបចំនូវហេដ្ឋារចនាសម្ព័ន្ធប្រទេសជាតិការគ្រប់គ្រងប្រទេសឡើងវិញ និងបានរៀបចំដាក់ចេញនូវយន្តការជាច្រើនក្នុងការអភិវឌ្ឍប្រទេស ព្រមទាំងស្តារប្រទេសលើគ្រប់វិស័យទាំងអស់នៅក្នុងប្រទេសកម្ពុជារហូតមកទល់ពេលបច្ចុប្បន្ន។

បច្ចុប្បន្ននេះ ការរីកចម្រើនបានឈានទៅមុខដោយមានសក្តានុពលភាពយ៉ាងខ្លាំង ស្របពេលនៃការរីកចម្រើនឃើញថាមានការកើតមានឡើងនូវបទល្មើសក្នុងវិស័យព័ត៌មានវិទ្យាជាច្រើន ដោយសារតែវិស័យបច្ចេកវិទ្យាមានការរីកចម្រើន។ ក្នុងនោះដែរ យើងឃើញថាមានបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យាកើនឡើងជាបន្តបន្ទាប់ ធ្វើឱ្យប៉ះពាល់ដល់សន្តិសុខជាតិ ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងប៉ះពាល់ដល់ផលប្រយោជន៍ប្រជាពលរដ្ឋ ជាចំណុចដែលគួរឱ្យមានការព្រួយបារម្ភ។

ការកកើតបទល្មើសនីមួយៗតែងតែមានហេតុ និងផល ដូច្នេះដើម្បីមើលឱ្យឃើញអំពីទិដ្ឋភាពនៃការកកើត និងមូលហេតុនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជាក្នុងផ្នែកនេះយើងនឹងធ្វើការសិក្សាអំពី **ការកកើតបទល្មើសក្នុងវិស័យព័ត៌មានវិទ្យា** (១.១.១) និង**មូលហេតុដែលមានបទល្មើសក្នុងវិស័យព័ត៌មានវិទ្យា** (១.១.២)។

### ១.១.១ ការកើតបទល្មើសក្នុងវិស័យព័ត៌មានវិទ្យា

មកទល់ពេលនេះ វិស័យព័ត៌មានវិទ្យា ទូរគមនាគមន៍ និងបច្ចេកវិទ្យា នៃព្រះរាជាណាចក្រកម្ពុជា មានការរីកចម្រើនយ៉ាងខ្លាំង។ យោងតាមរបាយការណ៍ចេញផ្សាយដោយ Hootsuite នៅឆ្នាំ២០២០ បង្ហាញថា ព្រះរាជាណាចក្រកម្ពុជាមានក្រុមហ៊ុនផ្គត់ផ្គង់សេវាអ៊ីនធឺណែតប្រមាណ៤៧ក្រុមហ៊ុន ចំណែកឯតួលេខនៃការប្រើប្រាស់អ៊ីនធឺណិតមានចំនួន៨.៨៦លាននាក់(៥២,៦%) អ្នកប្រើប្រាស់បណ្តាញសង្គមមានចំនួនប្រហែលជា ១២លាននាក់(៧១,៣%) ចំណែកការប្រើប្រាស់សេវាទូរសព្ទប្រហែលជាប្រមាណ២១.១៨លាននាក់ស្មើនឹង ១២៥,៨% ប្រៀបធៀបនឹងចំនួនប្រជាជនកម្ពុជាសរុប។[៣៦]

ទន្ទឹមនឹងការវិវត្តនៃបច្ចេកវិទ្យា វិស័យព័ត៌មានវិទ្យា និងទូរគមនាគមន៍ យើងសង្កេតឃើញថាមាន បទល្មើសដែលប្រើប្រាស់បច្ចេកវិទ្យា ឬប្រព័ន្ធបច្ចេកវិទ្យាជាមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើសក៏កំពុង កើតមានឡើងជាច្រើនករណី និងមានបងប្អូនប្រជាពលរដ្ឋក្លាយជាជនរងគ្រោះជាបន្តបន្ទាប់ផងដែរ។[៣៧] តែប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រទេសកម្ពុជា ស្របពេលដែលវិស័យបច្ចេកវិទ្យា ទូរគមនាគមន៍ ព័ត៌មានវិទ្យា និង ឌីជីថលមានការរីកចម្រើន ក្នុងនោះ ក៏មានបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យាកើនឡើងជាច្រើន។ ទៀតសោត សម័យកាលកាន់តែជឿនលឿន បច្ចេកវិទ្យាក៏មានភាពរីកចម្រើន ការកើតមានឡើងនូវបទល្មើសក៏ថ្មីផងដែរ។ យោងតាមការសិក្សាស្រាវជ្រាវអំពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន ក្រុមការងារបច្ចេកទេសនៃនាយកដ្ឋានព័ត៌មានវិទ្យា បានធ្វើការរៀបរាប់អំពីស្ថានភាពបទល្មើសបច្ចេកវិទ្យាព័ត៌មានធំៗដែលកំពុងកើតមាន ក៏ដូចជាបន្ត កើនឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជារួមមានដូចជា បទល្មើសឆបោកប្រាក់ (Money-Deposit/Flipping Scam)[៣៨] ការលួចកាន់កាប់គណនីអនឡាញខុសច្បាប់(Account Phishing/Hijacking)[៣៩] ការដាក់ផ្លាក់លួច យកនូវព័ត៌មាន(Phishing Attack)[៤០] បទល្មើសបរិហារកេរ្តិ៍/សម្លុតឬយាយី (Cyberdefamation/Harassment/ Bully)[៤១] ការបរិហារកេរ្តិ៍លើបណ្តាញផ្សព្វផ្សាយសង្គម (Social Media-Defamation)[៤២] បទល្មើសថត សកម្មភាពអាក្រាតជម្រិតទារប្រាក់ (Sextortion)[៤៣] បទល្មើសជម្រិតទារប្រាក់/បទល្មើសការចម្លងមេរោគ

---

[៣៦] https://shortifyme.co/GUaia (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[៣៧] https://shortifyme.co/6hktl (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[៣៨] https://shortifyme.co/j9IG6 (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤ )។

[៣៩] https://shortifyme.co/2kkqZ (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤ )។

[៤០] https://shortifyme.co/lNIGk (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[៤១] https://shortifyme.co/wnVZh (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤ )។

[៤២] https://shortifyme.co/MvBxw (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[៤៣] https://shortifyme.co/cavKA (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤ )។

(Malware /Ransomware)[៤៤] ការលួចយកអត្តសញ្ញាណ (Identify Theft)[៤៥] បទល្មើសបន្លំលួចប្រាក់តាមប្រព័ន្ធបច្ចេកវិទ្យា (Money-Fraud)[៤៦] ការបន្លំលួចប្រាក់ពីគណនីធនាគារ (Money-Fraud)[៤៧] បទល្មើសជ្រៀតចូលប្រព័ន្ធដោយខុសច្បាប់ (System-Compromise/Hacking)[៤៨] និងជាច្រើនទៀត។ យើងសង្កេតឃើញថាមានការកកើតឡើងនូវបទល្មើសក្នុងវិស័យព័ត៌មានវិទ្យាក្នុងទ្រង់ទ្រាយធំ និងមានគ្រប់រូបភាពថ្មីៗខណៈពេលដែលក្របខណ្ឌច្បាប់នៅកម្ពុជាមានលក្ខណៈមិនទាន់ជាក់លាក់នៅឡើយទាំងច្បាប់ពិសេស និងច្បាប់នីតិវិធី ដោយសារតែប្រទេសកម្ពុជាកំពុងតែធ្វើសេចក្តីព្រាងច្បាប់ពាក់ព័ន្ធនឹងបទល្មើសបច្ចេកវិទ្យាព័ត៌មាននៅឡើយ។

កត្តាដែលនាំឱ្យមានបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា គឺមានមូលហេតុនៃការកកើតហើយមូលហេតុទាំងនេះ យើងនឹងធ្វើការសិក្សានៅចំណុច (១.១.២) ខាងក្រោមនេះ។

### ១.១.២ មូលហេតុដែលនាំឱ្យមានបទល្មើសក្នុងវិស័យព័ត៌មានវិទ្យា

ទន្ទឹមនឹងសម័យកាលកាន់តែជឿនលឿន បច្ចេកវិទ្យាក៏មានភាពរីកចម្រើន ការកើតមានឡើងនូវបទល្មើសក្រោមរូបភាពថ្មីៗផងដែរ។ យើងសង្កេតឃើញថា មានបទល្មើសកើតឡើងតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាជាមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើសកំពុងកើតមានជាច្រើនករណី និងមានបងប្អូនប្រជាពលរដ្ឋក្លាយជាជនរងគ្រោះជាបន្តបន្ទាប់។ ប៉ុន្តែបើយើងសិក្សាឱ្យបានស៊ីជម្រៅគឺមានមូលហេតុ និងមានកត្តារួមផ្សំមួយចំនួនដែលបង្កឱ្យមានបទល្មើសក្នុងវិស័យព័ត៌មានវិទ្យាមានការកើនឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ។[៤៩]

ក្នុងនោះកត្តារួមផ្សំមានដូចតទៅ៖

❖ **កត្តាកំណើននៃការប្រើប្រាស់បច្ចេកវិទ្យាពីសំណាក់ប្រជាពលរដ្ឋទូទៅ**

យោងតាមរបាយការណ៍ដែលត្រូវបានចេញផ្សាយដោយ Hootsuite នៅឆ្នាំ២០២០បង្ហាញថាព្រះរាជាណាចក្រកម្ពុជា មានក្រុមហ៊ុនផ្គត់ផ្គង់សេវាអ៊ីនធឺណែត ប្រមាណ៤៧ក្រុមហ៊ុន ចំណែកតួលេខនៃការប្រើប្រាស់អ៊ីនធឺណិតមានចំនួន៨.៨៦លាននាក់(៥២,៦%) អ្នកប្រើប្រាស់បណ្តាញសង្គមមានចំនួន

[៤៤] https://shortifyme.co/uW៥៥J (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤ )។

[៤៥] https://shortifyme.co/aDopl (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[៤៦] https://shortifyme.co/n១UQp (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤ )។

[៤៧] https://shortifyme.co/fWImg (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[៤៨] https://shortifyme.co/ml៦x២ (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤ )។

[៤៩] https://shortifyme.co/fLYZO (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

១២លាននាក់(៧១,៣%) ចំណែកការប្រើប្រាស់សេវាទូរសព្ទមានប្រមាណ២១.១៨លាននាក់ស្មើនឹង១២៥,៨% ប្រៀបធៀបនឹងចំនួនប្រជាជនកម្ពុជាសរុប។[៥០]

❖ **កត្តាកង្វះខាតនូវការយល់ដឹងអំពីការប្រើប្រាស់បច្ចេកវិទ្យា**

ស្របពេលដែល សម័យកាលកាន់តែជឿនលឿន បច្ចេកវិទ្យាក៏មានភាពរីកចម្រើន នាំឱ្យមានរូបភាពមួយដែលបង្កឱ្យមនុស្សទូទៅ មិនថានៅកម្ពុជាក្តី ឬនៅប្រទេសនានាក្នុងសាកលលោកក្តី មានភាពកង្វះខាតក្នុងការយល់ដឹងអំពីប្រព័ន្ធបច្ចេកវិទ្យា។[៥១] ភាពខ្វះខាតក្នុងការយល់ដឹងអំពីបច្ចេកវិទ្យាក្នុងនោះអាចមានដូចជាកត្តាបុគ្គលដែលប្រើប្រាស់ផ្ទាល់ កត្តាទំនើបកម្មនៃប្រព័ន្ធបច្ចេកវិទ្យា កត្តាសង្គមដើរពុំទាន់បរិបទនៃសម័យកាលទំនើបកម្មបច្ចេកវិទ្យា កត្តាសម័យកាលមានការរីកចម្រើនខ្ពស់លើសពីការរំពឹងទុក និងកត្តាផ្សេងៗជាអាទ៍។ ដូច្នេះដើម្បីចូលរួមកាត់បន្ថយភាពងាយរងគ្រោះនៃបទល្មើសបច្ចេកវិទ្យា ពលរដ្ឋគ្រប់រូបគួរស្វែងយល់អំពីបច្ចេកវិទ្យាហានិភ័យពាក់ព័ន្ធ ដោយធ្វើការអាន ស្តាប់ ទស្សនាវីដេអូ សិក្សាស្វែងយល់ លើអត្ថបទកាសែត អត្ថបទអប់រំ វីដេអូអប់រំ ព័ត៌មានពាក់ព័ន្ធផ្សេងៗ និងបន្តផ្សព្វផ្សាយអប់រំ ចែករំលែកជូនដល់សាច់ញាតិ បងប្អូន មិត្តភក្តិ ព្រមទាំងចូលរួមធ្វើសេចក្តីរាយការណ៍ជូនសមត្ថកិច្ចពាក់ព័ន្ធក្នុងករណីជួបប្រទះ ឬសង្ស័យថាជាបទល្មើសបច្ចេកវិទ្យា។[៥២]

❖ **កត្តាក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត**

ក្របខណ្ឌច្បាប់នៅកម្ពុជាមានក្រមព្រហ្មទណ្ឌ ដែលបានបញ្ញត្តិនៅក្នុងគន្ថីទី៣ បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ ក្នុងនោះមានមាតិកាទី២ ការប៉ះពាល់ដល់ទ្រព្យសម្បត្តិ ត្រង់ជំពូកទី២ដែលបញ្ញត្តិអំពី បទល្មើសក្នុងវិស័យព័ត៌មានវិទ្យា ដែលជាជំពូកចុងក្រោយនេះគន្ថីទី៣ផងដែរ។ ប៉ុន្តែបទបញ្ញត្តិនេះនៅមិនទាន់គ្រប់ជ្រុងជ្រោយនៅឡើយទេ និងមានលក្ខណៈមិនទាន់ជាក់លាក់នៅឡើយ ទាំងច្បាប់ពិសេស និងច្បាប់នីតិវិធី ដោយសារប្រទេសកម្ពុជាកំពុងស្ថិតនៅក្នុងស្ថានភាពអភិវឌ្ឍ ព្រមទាំងទំនើបកម្មនៃបច្ចេកវិទ្យាមានការអភិវឌ្ឍ និងរីកចម្រើនយ៉ាងលឿនពីមួយថ្ងៃទៅមួយថ្ងៃក្រោមរូបភាពថ្មីៗជាច្រើន ដោយឡែកទោះយ៉ាងណាក្តី រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ក្នុងការតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន ដើម្បីគ្រប់គ្រងទៅលើបញ្ហានេះផងដែរ។[៥៣]

---

[៥០] https://shorturl.at/jiFRI (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[៥១] https://gx.ax/d៧R (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[៥២] https://gx.ax/d៧R (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[៥៣] https://gx.ax/d៧R (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

❖ **និងកត្តាឧក្រិដ្ឋជនប្រើប្រាស់បច្ចេកទេសខ្ពស់ក្នុងការប្រព្រឹត្តបទល្មើស**

ឧក្រិដ្ឋជននៃបទល្មើសនេះ មានការប្រើប្រាស់វិធីសាស្ត្រ ឬបច្ចេកទេសខ្ពស់ តាមរយៈការប្រើប្រាស់រួមមានប្រព័ន្ធបច្ចេកវិទ្យា អ៊ីនធឺណែត មេរោគ ជាអាទ៍ ដែលជាមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើសក្នុងវិស័យព័ត៌មានវិទ្យា។[៥៤]

## ១.២ ក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា

ក្របខណ្ឌច្បាប់ដែលមានការពាក់ព័ន្ធបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា មានលក្ខណៈមិនទាន់ជាក់លាក់ និងគ្រប់ជ្រុងជ្រោយនៅឡើយទេ ដោយសារតែប្រទេសកម្ពុជាកំពុងស្ថិតនៅក្នុងស្ថានភាពកំពុងអភិវឌ្ឍ ក៏ដូចជាសង្គមមានភាពជឿនលឿនក្រោមរូបភាពថ្មីៗប្លែកៗ។ ខណៈពេលនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រសួង និងស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធនឹងបទល្មើសនេះ បានធ្វើការការពារ ទប់ស្កាត់ ផ្សព្វផ្សាយ បង្ការបង្ក្រាប និងជាពិសេសខិតខំធ្វើការក្នុងការតាក់តែងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងបញ្ហាទាំងនេះផងដែរ។ ដោយថ្មីៗនេះក្រសួង និងស្ថាប័នដែលមានសមត្ថកិច្ចលើបញ្ហានេះ បានធ្វើការពិគ្រោះយោបល់អំពីសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន ដើម្បីធ្វើការប្រយុទ្ធប្រឆាំង ទប់ស្កាត់ និងបង្ក្រាបបទល្មើសបច្ចេកវិទ្យាព័ត៌មាន។

ដូច្នេះដើម្បីមើលឱ្យឃើញអំពី ក្របខណ្ឌច្បាប់ពាក់ព័ន្ធបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា យើងនឹងធ្វើការសិក្សាស្រាវជ្រាវអំពី**ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា** (១.២.១) និង**សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន** (១.២.២)។

### ១.២.១ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

ក្របខណ្ឌច្បាប់នៅប្រទេសកម្ពុជា យើងសង្កេតឃើញថា មានក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលបានបញ្ញត្តិមាត្រាមួយចំនួនសម្រាប់អនុវត្តទៅលើបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជាផងដែរ។ បើទោះបីជាប្រទេសកម្ពុជាបច្ចុប្បន្ននេះ ពុំទាន់មានក្របខណ្ឌច្បាប់ពិសេសជាក់លាក់នៅឡើយទាំងច្បាប់ពិសេស និងច្បាប់នីតិវិធីដែលពាក់ព័ន្ធនឹងបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជាក្តី ក៏ប្រទេសកម្ពុជាមានលិខិតបទដ្ឋានគតិយុត្តសមល្មមនឹងដាក់ទោសជនប្រព្រឹត្តបទល្មើសបច្ចេកវិទ្យាបានដែរ។ តួយ៉ាងបទល្មើសក្នុងវិស័យព័ត៌មានវិទ្យា ត្រូវបានដាក់បញ្ចូលក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ បានបញ្ញត្តិ បទល្មើសក្នុងវិស័យព័ត៌មានវិទ្យាស្ថិតនៅក្នុងគន្ថីទី៣ "បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ" ក្នុងនោះមាតិកាទី២ "ការប៉ះពាល់

[៥៤] https://gx.ax/d៧R (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

ដល់ទ្រព្យសម្បត្តិ" ត្រង់ជំពូកទី២ដែលស្តីអំពី **បទល្មើសក្នុងវិស័យព័ត៌មានវិទ្យា** ដែលជាជំពូកចុងក្រោយនៃគន្ថីទី៣ផងដែរ។[55]

បទល្មើសក្នុងវិស័យព័ត៌មានវិទ្យាក្នុងនោះបានបញ្ញត្តិមាត្រាធំៗចំនួន៦ ដែលគូសបញ្ជាក់អំពីបទល្មើស និងទោស ដើម្បីអនុវត្តចំពោះបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជាដែលក្នុងនោះមានដូចតទៅៈ

- មាត្រា ៤២៧ បទចូលទៅដល់ ឬ ស្ថិតនៅនឹងប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ
- មាត្រា ៤២៨ បទបង្កើតជាឧបសគ្គដល់ដំណើរការនៃប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ
- មាត្រា ៤២៩ បទបញ្ចូល លុបបំបាត់ ឬ កែប្រែដោយទុច្ចរិតនូវទិន្នន័យ
- មាត្រា ៤៣០ បទចូលរួមក្នុងក្រុមប្រមូលផ្តុំ ឬ ក្នុងសន្និដ្ឋិភាពដើម្បីរៀបចំប្រព្រឹត្តបទល្មើស
- មាត្រា ៤៣១ ការប៉ុនប៉ង (រាល់ការប៉ុនប៉ងប្រព្រឹត្តបទល្មើសទាំងប៉ុន្មានខាងលើនេះក៏ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ)
- មាត្រា ៤៣២ ទោសបន្ថែមៈ ប្រភេទ និងរយៈពេល (បទល្មើសក្នុងវិស័យព័ត៌មានវិទ្យាមានទោសបន្ថែមដល់ទៅ១០ប្រភេទ)។

បទល្មើសក្នុងវិស័យព័ត៌មានវិទ្យា ត្រូវបានដាក់បញ្ចូលក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា តាំងពីឆ្នាំ២០០៩ បង្កប់ក្នុងគន្ថីទី៣ មាតិកាទី២ ត្រង់ជំពូកទី២ ដែលស្តីអំពី បទល្មើសក្នុងវិស័យព័ត៌មានវិទ្យា ដែលជាជំពូកចុងក្រោយនៃគន្ថីទី៣។ បទល្មើសក្នុងវិស័យព័ត៌មានវិទ្យាក្នុងនោះបានបញ្ញត្តិមាត្រាធំៗចំនួន៦ ដែលបញ្ជាក់ពីបទបញ្ញត្តិស្តីអំពីបទល្មើស និងទោស ដើម្បីធ្វើការអនុវត្តចំពោះបទល្មើសក្នុងវិស័យព័ត៌មានវិទ្យា។[56]

បទប្បញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជានៅមិនទាន់ជាក់លាក់ និងមិនទាន់មានភាពច្បាស់លាស់នៅឡើយ ទៀតសោតការប្រើប្រាស់ពាក្យពេចន៍ ដែលបញ្ញត្តិនៅត្រង់ជំពូកទី២ដែលស្តីអំពីបទល្មើសក្នុងវិស័យព័ត៌មានវិទ្យា នៅមិនទាន់មានភាពច្បាស់លាស់ ព្រមទាំងមិនទាន់មានការកំណត់នូវអត្ថន័យនៃពាក្យ ក៏ដូចជាផ្តល់នូវជានិយមន័យមិនទាន់ស៊ីជម្រៅនៅឡើយទេ។ ដូចនេះដើម្បីសិក្សាឱ្យបានស៊ីជម្រៅទៅលើក្របខណ្ឌច្បាប់ដែលពាក់ព័ន្ធបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា យើងនឹងធ្វើការសិក្សាស្រាយបញ្ជាក់នៅចំណុច (១.២.២) ខាងក្រោមនេះដូចតទៅ។

[៥៥] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

[៥៦] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

### ១.២.២ សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន

ប្រទេសកម្ពុជា បើទោះបីជាមានបទប្បញ្ញត្តិក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តមាត្រាមួយចំនួនដែលពាក់ព័ន្ធនឹងបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជាក្តី។ យើងធ្វើការសង្កេតឃើញថាបទប្បញ្ញត្តិដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា នៅមានលក្ខណៈមិនទាន់ជាក់លាក់នៅឡើយ។ យ៉ាងណាមិញ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មានដើម្បីធ្វើការប្រយុទ្ធប្រឆាំងបទល្មើសបច្ចេកវិទ្យាព័ត៌មាន។

ការប្រព្រឹត្តទៅនៃសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន ឃើញថាៈ

- ❖ នៅពាក់កណ្តាលឆ្នាំ២០១០ ទីស្តីការគណៈរដ្ឋមន្ត្រីបានបង្កើតក្រុមការងារមួយ ដើម្បីបំពេញការងារធ្វើការតាក់តែង សេចក្តីព្រាងច្បាប់ឧក្រិដ្ឋកម្មតាមបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) ដោយមានអ្នកជំនាញការខាងច្បាប់ឧក្រិដ្ឋកម្មតាមបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ពីក្រុមប្រឹក្សាអឺរ៉ុប គឺលោក Alexander Seger ប្រធានផ្នែកឧក្រិដ្ឋកម្មសេដ្ឋកិច្ចចូលរួមសហការ តាមស្មារតីនៃការធ្វើសេចក្តីព្រាងច្បាប់នេះមានគោលបំណងកំណត់វិធានការអប់រំ បង្ការ ទប់ស្កាត់ និងបង្ក្រាបការប្រព្រឹត្តបទល្មើសនានាតាមប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក៏ដូចជាធានាសុវត្ថិភាព និងការពារផលប្រយោជន៍ ស្របច្បាប់ក្នុងការប្រើប្រាស់ និងអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។[៥៧] ឧក្រិដ្ឋកម្ម និងបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន មានច្រើនប្រភេទ ហើយពាក់ព័ន្ធនឹងសមត្ថកិច្ចជាច្រើនរាប់ពីការភ្ជាប់ដោយខុសច្បាប់ទៅកាន់ប្រព័ន្ធកុំព្យូទ័រអ្នកដទៃ ការជ្រៀតជ្រែកទិន្នន័យ-ប្រព័ន្ធការផលិតឬចែកចាយរូបអាសអាភាសកុមារ ការឆបោក ការក្លែងបន្លំតាមរយៈកុំព្យូទ័រ ក៏ដូចជាបទល្មើសផ្សេងទៀត ដែលប៉ះពាល់ដល់ឯករាជ្យភាព អធិបតេយ្យភាព សន្តិសុខជាតិ។ល។[៥៨]
- ❖ នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ ក្រុមប្រឹក្សានីតិកម្ម ក្រសួងមហាផ្ទៃ បន្តកិច្ចប្រជុំពិភាក្សា និងពិនិត្យលើសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន។ កិច្ចប្រជុំនេះធ្វើឡើងដើម្បីសិក្សាបន្តទៅលើសេចក្តីព្រាងច្បាប់បទល្មើសបច្ចេកវិទ្យាព័ត៌មាន ក្នុងគោលបំណងធានាសុចរិតភាពនៃការប្រើប្រាស់ ការគ្រប់គ្រងប្រព័ន្ធកុំព្យូទ័រ ទិន្នន័យកុំព្យូទ័រ និងការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ព្រមទាំង

[៥៧] សេចក្តីបំភ្លឺទាក់ទងនឹងសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT), ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, លេខ៦៥៧ បទ, រាជធានីភ្នំពេញ ២៥ ឧសភា ២០១៥។

[៥៨] សេចក្តីបំភ្លឺទាក់ទងនឹងសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT), ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, លេខ៦៥៧ បទ, រាជធានីភ្នំពេញ ២៥ ឧសភា ២០១៥។

ការការពារសិទ្ធិសេរីភាពបុគ្គល ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបការប្រព្រឹត្តបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា។ ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះបទល្មើសបច្ចេកវិទ្យាព័ត៌មាន ដែលប្រព្រឹត្តនៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា ហើយដែលអំពើនោះធ្វើឱ្យប៉ះពាល់ដល់រូបវន្តបុគ្គល នីតិបុគ្គល សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ ឬផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា ដោយសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាននេះមាន៧ជំពូក ៤៨មាត្រា ហើយក្រុមការងារបានកំពុងតែប្រមូលធាតុផ្សំផ្សេងៗដែលពាក់ព័ន្ធ ដើម្បីដាក់ចូលទៅក្នុងសេចក្តីព្រាងច្បាប់នេះ ហើយខ្លឹមសារនៅក្នុងច្បាប់នេះក៏មានចែងអំពីការផ្តន្ទាទោសផងដែរ។[៥៩]

❖ ទីស្តីការក្រសួងមហាផ្ទៃ នារសៀលថ្ងៃអង្គារ ទី៤ ខែសីហា ឆ្នាំ២០២០ បានបន្តកិច្ចប្រជុំពិភាក្សា និងពិនិត្យលើសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន លើជំពូកទី០៤ មាត្រា១១ ស្តីពី ការអនុវត្តបទបញ្ញត្តិ។ ជាងនេះទៅទៀត ច្បាប់នេះមានវិសាលភាពអនុវត្ត ចំពោះបទល្មើសបច្ចេកវិទ្យាព័ត៌មានដែលប្រព្រឹត្តនៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា ហើយដែលអំពើនោះធ្វើឱ្យប៉ះពាល់ដល់រូបវន្តបុគ្គល នីតិបុគ្គល សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ ឬផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា សេចក្តីព្រាងច្បាប់ស្តីពី បទល្មើសបច្ចេកវិទ្យាព័ត៌មាននេះ មានគោលបំណងធានា សុចរិតភាពនៃការប្រើប្រាស់ ការគ្រប់គ្រងប្រព័ន្ធកុំព្យូទ័រ ទិន្នន័យកុំព្យូទ័រ និងការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងការការពារសិទ្ធិសេរីភាពបុគ្គល ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសបច្ចេកវិទ្យាព័ត៌មាន។ សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាននេះគឺមាន ៨ជំពូក និង៥០មាត្រា។ យ៉ាងណាមិញ កិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មានបានរៀបចំប្រជុំអន្តរក្រសួង និងអន្តរអគ្គនាយកដ្ឋានសរុបទាំងអស់៥២លើក។ ដោយឡែក កិច្ចប្រជុំក្នុងក្របខណ្ឌអគ្គនាយកដ្ឋានមានចំនួន៨លើក ហើយក្រុមការងារបាននឹងកំពុងតែប្រមូលធាតុផ្សំផ្សេងៗដែលពាក់ព័ន្ធ ដើម្បីដាក់ចូលទៅក្នុងសេចក្តីព្រាងច្បាប់នេះ ហើយខ្លឹមសារនៅក្នុងច្បាប់នេះ ក៏មានចែងអំពីការផ្តន្ទាទោសផងដែរ។[៦០]

❖ កិច្ចប្រជុំនាព្រឹកថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០ ក្រសួងមហាផ្ទៃបានបន្តពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន ដើម្បីឱ្យសេចក្តីព្រាងច្បាប់មានភាពកាន់តែសុក្រឹត្យភាព ដើម្បីការពារ បង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសបច្ចេកវិទ្យាព័ត៌មានសេចក្តីព្រាងច្បាប់

---

[៥៩] https://www.facebook.com/share/p/៥rZEDE៩wUUHmhv៤y/ (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[៦០] https://www.facebook.com/share/p/LdDtU៩៨EkHv៤yBto/ (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន ត្រូវបានតាក់តែងក្នុងឆ្នាំ២០១៦មកម្ល៉េះ ដោយសារតែវិស័យបច្ចេកវិទ្យាមានការរីកចម្រើន ក្នុងនោះក៏មានបទល្មើសឧក្រិដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាកើនឡើង ដូច្នេះហើយដោយសារតែមានការព្រួយបារម្ភពីបទល្មើសបច្ចេកវិទ្យានេះកើតឡើងធ្វើឱ្យប៉ះពាល់ដល់សន្តិសុខជាតិ ប៉ះពាល់ដល់សណ្តាប់ធ្នាប់សារធារណៈ ប៉ះពាល់ដល់ផលប្រយោជន៍ប្រជាពលរដ្ឋ ទើបក្រសួងមហាផ្ទៃបានរៀបចំនៅសេចក្តីព្រាងច្បាប់នេះឡើង ហើយក៏បានជួបប្រជុំពិភាក្សាជាបន្តបន្ទាប់ ចំនួន៦៧លើករួចមកហើយ ដោយមានទាំងប្រជុំអន្តរក្រសួង កិច្ចប្រជុំជាមួយនាយកដ្ឋានជំនាញរបស់ក្រសួងមហាផ្ទៃ ព្រមទាំងមានជំនួយឧបត្ថម្ភបច្ចេកទេសពីក្រសួងយុត្តិធម៌សហរដ្ឋអាមេរិកផងដែរ ហើយក្រុមការងារបានកំពុងតែប្រមូលធាតុផ្សំផ្សេងៗដែលពាក់ព័ន្ធដើម្បីដាក់ចូលទៅក្នុងសេចក្តីព្រាងច្បាប់ ហើយខ្លឹមសារនៅក្នុងសេចក្តីព្រាងច្បាប់ក៏មានចែងអំពីការផ្តន្ទាទោសផ្នែកព្រហ្មទណ្ឌផងដែរ។ យ៉ាងណាមិញ សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មានមាន៨ជំពូក និង៥០មាត្រា សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាននេះ មានគោលបំណងធានា សុចរិតភាព នៃការប្រើប្រាស់ ការគ្រប់គ្រងប្រព័ន្ធកុំព្យូទ័រ ទិន្នន័យកុំព្យូទ័រ និងការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងការការពារសិទ្ធិសេរីភាពបុគ្គល ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសបច្ចេកវិទ្យាព័ត៌មាន។ ជាងនេះទៅទៀតច្បាប់នេះមានវិសាលភាពអនុវត្តចំពោះបទល្មើសបច្ចេកវិទ្យាព័ត៌មានដែលប្រព្រឹត្តនៅក្នុង ឬនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលអំពើនោះធ្វើឱ្យប៉ះពាល់ដល់រូបវន្តបុគ្គល នីតិបុគ្គល សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ ឬផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា។[៦១]

- នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ ក្រសួងមហាផ្ទៃ បានបន្តបើកកិច្ចប្រជុំពិភាក្សា និងពិនិត្យលើសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន ដោយសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាននេះមានគោលបំណងធានា សុចរិតភាព នៃការប្រើប្រាស់ ការគ្រប់គ្រងប្រព័ន្ធកុំព្យូទ័រ ទិន្នន័យកុំព្យូទ័រ និងការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងការការពារសិទ្ធិសេរីភាពបុគ្គល ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសបច្ចេកវិទ្យាព័ត៌មាន។[៦២]
- នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃដឹកនាំកិច្ចប្រជុំស្តីពីសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន សេចក្តីព្រាងច្បាប់នេះត្រូវបានចងក្រង និងរៀបចំតាក់តែងឡើង តាំងពីឆ្នាំ២០១៦មកម្ល៉េះ ដោយក្រុមការងាររៀបចំច្បាប់នេះ បានធ្វើការសិក្សាស្រាវជ្រាវ

---

៦១ https://www.facebook.com/share/p/FEbbhhkjdee៨QCuZ/ (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

៦២ https://www.facebook.com/share/p/jB៩uq២GnXogJpRT៨/ (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

និងរៀបចំឡើងដោយមានការគាំទ្រពីស្ថាប័នជាតិផងដែរ។ សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាននេះ មានការចូលរួមពិភាក្សា និងផ្តល់យោបល់បន្ថែមពីក្រសួង និងស្ថាប័នដែលពាក់ព័ន្ធចំនួន៥ រួមមាន៖ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងព័ត៌មាន ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងយុត្តិធម៌។ សេចក្តីព្រាងច្បាប់នេះ មានគោលបំណងក្នុងការធានាសុចរិតនៃការប្រើប្រាស់ ការគ្រប់គ្រងប្រព័ន្ធកុំព្យូទ័រ ទិន្នន័យកុំព្យូទ័រ និងការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងការពារសិទ្ធិសេរីភាពរបស់បុគ្គលដោយកំណត់អំពីវិធានការបង្ការ ការទប់ស្កាត់ និងការបង្ក្រាបបទល្មើសបច្ចេកវិទ្យាព័ត៌មាន ក៏ប៉ុន្តែកត្តាដែលសំខាន់នោះដែលជាការចាំបាច់ត្រូវតែមានការចូលរួមពីបងប្អូនសំណាក់ប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរ។[៦៣]

- នារសៀលថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២២ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានពិភាក្សាការងារជាមួយឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឆែក ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដោយផ្តោតលើប្រធានបទជុំវិញវិស័យសន្តិសុខសាយប័រឆ្លៀតក្នុងឱកាសនោះដែរ ឯកឧត្តមរដ្ឋមន្ត្រី បានជម្រាបជូនបន្ថែមដល់ឯកឧត្តមឯកអគ្គរដ្ឋទូតអំពីសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មបច្ចេកវិទ្យាព័ត៌មាន សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ សេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខសាយប័រ ដែលជាកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួង និងរាជរដ្ឋាភិបាលក្នុងគោលដៅរក្សាសន្តិសុខក្នុងប្រព័ន្ធសាយប័រជូនដល់សង្គមជាតិកម្ពុជា។[៦៤]
- នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៤ ក្រសួងមហាផ្ទៃបានធ្វើការពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន ដោយពិភាក្សាលើការរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ឡើងដោយផ្អែកលើសន្ធិសញ្ញាទីក្រុង Budapest ឆ្នាំ២០០១ និងច្បាប់មួយចំនួនពីបណ្តាប្រទេសនានាជាមូលដ្ឋាន និងដោយមានកិច្ចសហការគាំទ្រពីស្ថានទូតសហរដ្ឋអាមេរិកប្រចាំព្រះរាជាណាចក្រកម្ពុជា ដោយមានលោក ថូម៉ាស ធូកាធី និងលោក អែនតូនី ដែលជាអ្នកជំនាញការច្បាប់នៃក្រសួងយុត្តិធម៌ សហរដ្ឋអាមេរិកមកជួយពិនិត្យ និងផ្តល់យោបល់កែសម្រួលសេចក្តីព្រាងច្បាប់នេះ គួរបញ្ជាក់ថាសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មានគឺមាន៩ជំពូក និង៥៥មាត្រា ដែលមានគោលបំណងក្នុងការការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ធានាសុចរិតភាពនៃការប្រើប្រាស់ ការគ្រប់គ្រងប្រព័ន្ធកុំព្យូទ័រ ទិន្នន័យកុំព្យូទ័រ ព្រមទាំងការពារសិទ្ធិសេរីភាពរបស់បុគ្គល ដោយកំណត់អំពីវិធានការបង្ការ ការទប់ស្កាត់ និងការបង្ក្រាបបទល្មើសបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងអនុវត្តរាល់សកម្មភាពពាក់ព័ន្ធនឹងបទល្មើស

---

[៦៣] https://www.facebook.com/share/p/Q២ជPd២Vy២YX២៥៧s៥/ (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[៦៤] Ministry of Post and Telecommunications (mptc.gov.kh) (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

បច្ចេកវិទ្យាព័ត៌មានដែលប្រព្រឹត្តនៅក្នុង ឬនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយសកម្មភាពទាំងនោះធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ឬផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជាលើសពីនេះសេចក្តីព្រាងច្បាប់នេះក៏ទទួលបានការចូលរួមផ្តល់យោបល់ពីក្រុមហ៊ុនធំៗចំនួន៤ផងទៀតពីសហរដ្ឋអាមេរិក ដូចជាក្រុមហ៊ុនហ្វេសបុក ក្រុមហ៊ុនហ្គោហ្គលក្រុមហ៊ុនអាម៉ាស្សូន។ បន្ទាប់មកបានរៀបចំកិច្ចប្រជុំអន្តរក្រសួងចំនួន៥រួមមាន ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងព័ត៌មាន ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យានិងនវានុវត្តន៍ និងក្រសួងយុត្តិធម៌ចំនួន៦លើក បន្ថែមពីលើកិច្ចពិភាក្សាពីលើក្រសួងស្ថាប័នដែលពាក់ព័ន្ធកន្លងមកមានចំនួន១២០លើក។ សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាននេះ គឺជាសក្ខីភាពនៃការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការបង្កើតក្របខណ្ឌច្បាប់មួយរឹងមាំ ដើម្បីប្រយុទ្ធប្រឆាំងបទល្មើសបច្ចេកវិទ្យាព័ត៌មាន ដែលជាប្រភេទបទល្មើសមិនប្រពៃណីក្នុងសម័យទំនើប និងធានាការពារសន្តិសុខជូនប្រជាពលរដ្ឋ។ ទោះជាយ៉ាងណាក៏ដោយ ការរៀបចំច្បាប់នេះ តម្រូវឱ្យមានសន្តិសុខ និងសេរីភាព និងមានសក្ខីភាពជាកិច្ចសហការជាតិ និងអន្តរជាតិ ទើបទាមទារឱ្យយើងទាំងអស់គ្នាប្រើប្រាស់ប្រាជ្ញាជំនាញបទពិសោធន៍ជាសមូហភាព។[៦៥]

ទៀតសោតថ្មីៗនេះ សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន ដែលក្រសួងមហាផ្ទៃប្រកាសថ្មីៗនេះ យើងឃើញថាមានការបែងចែកជា៩ជំពូក និង៥៥មាត្រា ដោយឡែកបទប្បញ្ញត្តិដែលយើងបានធ្វើការសិក្សាស្រាវជ្រាវស្វែងរកឃើញគឺមានត្រឹមតែ៦ជំពូករួមមានដូចជា៖ ជំពូកទី១ បទបញ្ញត្តិទូទៅ(ពីមាត្រា១ដល់មាត្រា៤), ជំពូកទី២ គណៈកម្មាធិការជាតិប្រឆាំងនឹងបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា(ពីមាត្រា៥ដល់មាត្រា១២), ជំពូកទី៣ នីតិវិធី(ពីមាត្រា១៣ដល់មាត្រា២០), ជំពូកទី៤ បទល្មើស(ពីមាត្រា២១ដល់មាត្រា៣៥), ជំពូកទី៥ ជំនួយផ្នែកច្បាប់ទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងបត្យាប័ន(ពីមាត្រា៣៦ដល់មាត្រា៣៨) និងជំពូកបញ្ចប់ អវសានប្បញ្ញត្តិ(ពីមាត្រា៣៩ដល់មាត្រា៤០) ជាមាត្រាចុងក្រោយនៃជំពូកទី៦នៃសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន។

[៦៥] https://nw.ax/ៈAl (ចូលទស្សនានៅថ្ងៃទី២៣ មីនា ២០២៤)។

## ១.៣ ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងលំហចំពោះបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា

យោងតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចំពោះការកំណត់ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជានៅក្នុងលំហ ចែកចេញជាពីរគឺ ករណីបទល្មើសដែលបានប្រព្រឹត្ត ឬ ចាត់ថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងករណីបទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

### ១.៣.១ បទល្មើសដែលបានប្រព្រឹត្ត ឬចាត់ថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា

យោងតាមមាត្រា២ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានកំណត់នៅក្នុងផែនទីខ្នាត ១/១០០ ០០០ ធ្វើនៅចន្លោះឆ្នាំ ១៩៣៣-១៩៥៩ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិនៅចន្លោះឆ្នាំ ១៩៦៣-១៩៦៩។[៦៦] ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសទាំងឡាយដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ដែនដីនៃព្រះរាជាណាចក្រកម្ពុជារួមបញ្ចូលទាំងលំហអាកាស និងសមុទ្រ ដែលមានចំណងចងភ្ជាប់នឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។[៦៧] ដូច្នេះ បទល្មើសត្រូវបានចាត់ថាប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជានៅពេល ដែលអំពើណាមួយនៃបទល្មើស នោះបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។[៦៨] តាមមាត្រា១៤ និង មាត្រា១៦ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ត្រូវបានចាត់ទុកថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាកាលបើ បទល្មើសត្រូវបានប្រព្រឹត្តៈ

- នៅក្នុងនាវាដែលមានសញ្ជាតិខ្មែរ ទោះបីជានាវានោះស្ថិតនៅទីណាក៏ដោយ ។
- នៅក្នុងអាកាសយានដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ទោះ បីជាអាកាសយាននោះស្ថិតនៅទីណាក៏ដោយ ។

ដូច្នេះ ការប្រព្រឹត្តបទល្មើសនៅលើនាវា ឬ អាកាសយានខាងលើត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ច្បាប់កម្ពុជា។[៦៩]

ក្រៅពីនេះ មាត្រា១៥ នៃក្រមព្រហ្មទណ្ឌក៏បានប្រគល់សមត្ថកិច្ចឱ្យច្បាប់កម្ពុជាជាបន្ថែមទៀត ចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្តនៅក្នុងនាវាបរទេស ហើយដែលអាជ្ញាធរកម្ពុជាបានទទួលការអនុញ្ញាតឱ្យពិនិត្យ

---

[៦៦] មាត្រា២ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា។

[៦៧] មាត្រា១២ក្រ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

[៦៨] មាត្រា១៣ក្រ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

[៦៩] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត, នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញៈ ធាងពុម្ពជោគជ័យ, ២០២២), ១៣១-១៣២។

មើល ឬឱ្យចាប់តាម អំណាចនៃកិច្ចព្រមព្រៀងអន្តរជាតិ។ បទល្មើសត្រូវចាត់ទុកថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាត្រូវស្ថិតក្រោមច្បាប់របស់កម្ពុជា។ នៅពេលដែលធាតុផ្សំនៃបទល្មើសទាំងអស់បានកើតឡើងនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ឬ ក៏នៅពេលដែលការផ្តើមគំនិត ឬការសមគំនិតបានកើតឡើងនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបុគ្គលគ្រប់រូបដែលជាអ្នកផ្តើមគំនិត ឬ អ្នកសមគំនិតនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលប្រព្រឹត្តនៅឯបរទេស ប្រសិនបើលក្ខខណ្ឌទាំងពីរដូចខាងក្រោមនេះ ត្រូវបានបំពេញៈ

- បទល្មើសត្រូវផ្តន្ទាទោសតាមច្បាប់កម្ពុជាផង និងតាមច្បាប់បរទេសផង និង
- អត្ថិភាពនៃបទល្មើស ត្រូវបានបញ្ជាក់ដោយសេចក្តីសម្រេចជាស្ថាពរ របស់តុលាការបរទេស។[៧០]

### ១.៣.២ បទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា

ក្នុងករណីដែលជនល្មើសជាពលរដ្ឋខ្មែរ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើ គ្រប់បទឧក្រិដ្ឋទាំងអស់ដែលប្រព្រឹត្តដោយជននេះ។ ប្រសិនបើជាបទមជ្ឈិមវិញ ច្បាប់កម្ពុជាត្រូវយកទៅអនុវត្តបាន យោងតាមមាត្រា១៩ នៃក្រមព្រហ្មទណ្ឌ លុះត្រាតែអំពើនោះត្រូវបានផ្តន្ទាទោស តាមច្បាប់នៃប្រទេសដែលបទល្មើសបាន កើតឡើងផងដែរ។[៧១] ម្យ៉ាងទៀត ច្បាប់កម្ពុជាត្រូវអនុវត្ត ទោះបីជាជនជាប់ចោទទទួល បានសញ្ជាតិខ្មែរ ក្រោយអំពើដែលចោទប្រកាន់ក៏ដោយ។ ក្នុងករណីដែលជនរងគ្រោះជាពលរដ្ឋខ្មែរ នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត ច្បាប់កម្ពុជាត្រូវយកទៅអនុវត្តលើគ្រប់បទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ទោះបីជា ជនល្មើសជាជនបរទេស ឬជាពលរដ្ឋខ្មែរក៏ដោយ។ ក្នុងករណីទាំងពីរខាងលើនេះ ការចោទប្រកាន់អាចធ្វើទៅបាន លុះត្រាតែមានបណ្តឹងរបស់ជនរងគ្រោះ ឬពីសិទ្ធិវន្ត (អ្នកមានសិទ្ធិ) ឬក៏បណ្តឹងបរិហារ (បណ្តឹងដែលមានបំណងលាតត្រដាងអត្ថិភាពនៃបទល្មើសណាមួយ) ជាផ្លូវការរបស់អាជ្ញាធរនៃប្រទេសដែលជាទីកន្លែងដែលអំពើនោះបានប្រព្រឹត្ត។ ការចោទប្រកាន់អាចប្រព្រឹត្តទៅបានតាមបណ្តឹងរបស់អង្គការអយ្យការតែប៉ុណ្ណោះ។

[៧០] មាត្រា១៧ក្រ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

[៧១] មាត្រា១៩ក្រ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

ក្រៅពីករណីដូចដែលបានរៀបរាប់ខាងលើ ច្បាប់កម្ពុជាក៏មានសមត្ថកិច្ច អនុវត្តដែរ ប្រសិនបើបទល្មើស នោះប៉ះពាល់ដោយផ្ទាល់ដល់អធិបតេយ្យជាតិរបស់កម្ពុជា ទោះបីជាត្រូវបានប្រព្រឹត្តនៅឯបរទេសក៏ដោយ យោងតាមមាត្រា២២ នៃក្រមព្រហ្មទណ្ឌ។[៧២]

ផ្អែកតាមក្រមព្រហ្មទណ្ឌ ករណីទាំងនោះមានដូចជា៖

- បទល្មើសប្រឆាំងនិងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា។
- បទល្មើសក្លែងត្រាផ្លូវការនៃព្រះរាជាណាចក្រកម្ពុជា។
- បទល្មើសក្លែងរូបិយវត្ថុ និងធនបត្រជាតិ ដែលមានតម្លៃស្របច្បាប់ នៅព្រះរាជាណាចក្រកម្ពុជា។
- បទល្មើសដែលប្រឆាំងនឹងភ្នាក់ងារទូត ឬ កុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា។
- បទល្មើសប្រឆាំងទីតាំងទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា។[៧៣]

---

[៧២] មាត្រា២២ក្រ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, ។

[៧៣] មាត្រា២២ក្រ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

# ជំពូកទី២
# បច្ចុប្បន្នភាពនៃបទល្មើស
# ក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា

# ជំពូកទី២

# បច្ចុប្បន្នភាពនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា

យោងតាមរបាយការណ៍ចេញផ្សាយដោយ Hootsuite នៅឆ្នាំ២០២០ បង្ហាញថា ព្រះរាជាណាចក្រកម្ពុជា មានការរីកចម្រើនយ៉ាងគួរឱ្យកត់សម្គាល់ក្នុងវិស័យព័ត៌មានវិទ្យា ក៏ដូចជាប្រព័ន្ធបច្ចេកវិទ្យាមានការអភិវឌ្ឍ យ៉ាងខ្លាំង។ ដោយឡែកយ៉ាងណាមិញ ទន្ទឹមនឹងការរីកចម្រើនទៅលើវិស័យនេះវាបានបង្កឱ្យមានផលវិជ្ជមាន និងផលអវិជ្ជមាន ហើយផលអវិជ្ជមាននេះហើយ ដែលធ្វើឱ្យជនឆ្មក់ឱកាសមួយចំនួនបានយកភាពរីកចម្រើននៃ ព័ត៌មានវិទ្យា ឬបច្ចេកវិទ្យាព័ត៌មាន ទាំងនោះប្រើប្រាស់ក្នុងផ្លូវមិនល្អដែលបង្កឱ្យមានជាបទល្មើសផ្សេងៗ ដែល ជាហេតុនាំឱ្យមានបញ្ហាចលាចលដល់សង្គម សណ្ដាប់ធ្នាប់សាធារណៈ ក៏ដូចជាដល់អ្នកប្រើប្រាស់ផ្សេងៗទៀត។ បច្ចុប្បន្ននេះប្រទេសកម្ពុជា ជាប្រទេសដែលកំពុងអភិវឌ្ឍ និងបន្តអភិវឌ្ឍជាបន្តបន្ទាប់ ទន្ទឹមនឹងនេះបញ្ហាបាន កើតឡើងជាបន្តបន្ទាប់ ក្នុងនោះគឺការកើតមានឡើងនូវបទល្មើសតាមបច្ចេកវិទ្យាព័ត៌មាននៅកម្ពុជា។ យើង សង្កេតឃើញថា មានករណីជាច្រើននៅកម្ពុជា ដែលជនឆ្លៀតឱកាសបានធ្វើសកម្មភាពទុច្ចរិតតាមរយៈការប្រើ ប្រាស់បច្ចេកវិទ្យា ឬប្រព័ន្ធបច្ចេកវិទ្យា ជាមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើស ដែលបង្កឱ្យកើតមានជា បទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា ហើយបានធ្វើឱ្យបងប្អូនប្រជាពលរដ្ឋក្លាយជាជនរងគ្រោះជាបន្ត បន្ទាប់ផងដែរ។

ដូច្នេះដើម្បីឱ្យយល់កាន់តែច្បាស់អំពី បច្ចុប្បន្នភាពនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា យើងនឹងធ្វើការសិក្សាទៅលើរួមមាន **បទល្មើសក្នុងវិស័យព័ត៌មានវិទ្យាដែលបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌ** (២.១) **អំពើថ្មីៗដែលជាផ្នែកនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា** (២.២) បន្ទាប់មកធ្វើការសិក្សាអំពី **ក្រសួង និង ស្ថាប័នមានសមត្ថកិច្ចលើបទល្មើសក្នុងវិស័យព័ត៌មានវិទ្យា** (២.៣) និង**នីតិវិធីនៃការដាក់ពាក្យបណ្ដឹង** (២.៤)។

## ២.១ បទល្មើសក្នុងវិស័យព័ត៌មានវិទ្យាបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

បទល្មើសក្នុងវិស័យព័ត៌មានវិទ្យា ដែលបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ជាប្រភេទ បទល្មើសមួយប្រភេទដែលមានស្ថានភាពនៃបទល្មើស ឬក៏រូបភាពនៃការប្រព្រឹត្តបទល្មើសខុសពីបទល្មើសផ្សេង ដោយហេតុតែបទល្មើសនេះ មានការប៉ះពាល់ទៅដល់ប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ ហើយការ ប៉ះពាល់ទៅដល់ប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យនេះ គឺជាកម្មវត្ថុនៃបទល្មើសដែលបានបង្កើតជាឧបសគ្គ ដល់ដំណើរការបច្ចេកទេសក្នុងវិស័យព័ត៌មានវិទ្យា និងប៉ះពាល់ដល់ឯកជនភាពក្នុងវិស័យព័ត៌មានវិទ្យាផងដែរ។ បទល្មើសនេះបានស្ដែងឱ្យឃើញក្រោមរូបភាពរួមមាន ការចូលទៅដល់ ឬការស្ថិតនៅ, ការបង្កើតជាឧបសគ្គ, ការបញ្ចូល ការលុបបំបាត់ ឬការកែប្រែ, ការចូលរួមប្រមូលផ្ដុំ ឬការចូលរួមក្នុងសន្និដ្ឋិភាពដើម្បីរៀបចំប្រព្រឹត្ត

បទល្មើស និងការប៉ុនប៉ង ដែលទាំងនេះហើយជាសកម្មភាពទុច្ចរិត ក្នុងការប្រព្រឹត្តអំពើដែលប៉ះពាល់ទៅដល់ប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ ដែលបង្កឱ្យមានជាបទល្មើសក្នុងវិស័យព័ត៌មានវិទ្យា។[74]

ដើម្បីឱ្យយល់កាន់តែជាក់លាក់ ទៅលើបទល្មើសក្នុងវិស័យព័ត៌មានវិទ្យាដែលបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឱ្យកាន់តែច្បាស់ ក្នុងផ្នែកនេះយើងនឹងធ្វើការសិក្សាអំពី **បទចូលទៅដល់ ឬ ស្ថិតនៅនឹងប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ** (២.១.១) ,**បទបង្កើតជាឧបសគ្គដល់ដំណើរការនៃប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ** (២.១.២) ,**បទបញ្ចូល លុបបំបាត់ ឬ កែប្រែដោយទុច្ចរិតនូវទិន្នន័យ** (២.១.៣) **បទចូលរួមក្នុងក្រុមប្រមូលផ្តុំ ឬ ក្នុងសន្និដ្ឋិភាពដើម្បីរៀបចំប្រព្រឹត្តបទល្មើស** (២.១.៤) ,**ការប៉ុនប៉ង** (២.១.៥) និង**ទោសបន្ថែម** (២.១.៦)។

### ២.១.១ បទចូលទៅដល់ ឬ ស្ថិតនៅនឹងប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ

យើងដឹងហើយថា ជាទ្រឹស្តីច្បាប់ព្រហ្មទណ្ឌ ឬជាគោលការណ៍ ដើម្បីកំណត់បទល្មើសជនណាម្នាក់ដែលបានប្រព្រឹត្ត ឬចាត់ទុកថាអំពើណាមួយនោះជាបទល្មើស ឱ្យបានច្បាស់លាស់យើងត្រូវដឹងថាធាតុផ្សំនៃបទល្មើសត្រូវតែមាន ៣ធាតុសំខាន់ៗ បើខ្វះធាតុផ្សំណាមួយនោះមិនអាចចាត់ទុកជាបទល្មើសបានឡើយដូចធាតុផ្សំរបស់បទល្មើសទូទៅផងដែរ ក្នុងនោះរួមមានដូចជាធាតុផ្សំទី១ធាតុនីត្យានុកូលឬធាតុច្បាប់ ធាតុផ្សំទី២ធាតុសត្យានុម័តឬធាតុសម្ភារៈ និងធាតុផ្សំទី៣ធាតុអត្តនោម័តឬធាតុចិត្តសាស្ត្រ។

- **ធាតុផ្សំនីត្យានុកូល ឬធាតុច្បាប់**

ជាទ្រឹស្តីច្បាប់ព្រហ្មទណ្ឌ ឬជាស្មារតីនៃច្បាប់ព្រហ្មទណ្ឌ "**មានបទល្មើស មានទោស កាលណាមានច្បាប់ចែង**"។ មាត្រា៤២៧ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បទចូលទៅដល់ ឬ ស្ថិតនៅនឹងប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ បញ្ញត្តិថា

"អំពើចូលទៅដល់ ឬ ស្ថិតនៅនឹងប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ ដោយទុច្ចរិត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជា ប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល។

កាលបើអំពើនោះជាហេតុបណ្តាលឱ្យមានការលុបបំបាត់ ឬ កែប្រែទិន្នន័យដែលមាននៅក្នុងប្រព័ន្ធ ឬ ឱ្យមានការខូចខាតនូវដំណើរការនៃប្រព័ន្ធ បទល្មើសនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល។"[៧៥]

[៧៤] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

[៧៥] មាត្រា៤២៧ក្រ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

❖ **ធាតុផ្សំសត្យានុម័ត ឬធាតុសម្ភារៈ**

សង្កេតឃើញថា បទចូលទៅដល់ ឬ ស្ថិតនៅនឹងប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ នៃមាត្រា ៤២៧ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ស្តែងឱ្យឃើញក្រោមរូបភាព២ និងមានការផ្តន្ទាទោស២ផ្សេងគ្នាផងដែរ អំពើក្នុងកថាខណ្ឌទី១ និងអំពើក្នុងការកថាខណ្ឌទី២នៃមាត្រា៤២៧ ជាអំពើដែលស្ថិតនៅក្នុងឈ្មោះបទល្មើសតែ១ គឺបទចូលទៅដល់ ឬ ស្ថិតនៅប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យនៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩។

ត្រង់កថាខណ្ឌទី១នៃមាត្រា៤២៧ ស្តែងឱ្យឃើញអំពីកត្តាសត្យានុម័ត ក្នុងនោះគឺសំដៅទៅលើ អំពើចូលទៅដល់ ឬស្ថិតនៅនឹងប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ ដែលនេះស្តែងឱ្យឃើញអំពើដែលជនល្មើសបានប្រព្រឹត្តបទល្មើសស្តែងចេញដោយតាមរយៈអំពើបង្កគ្រោះថ្នាក់ដល់សង្គម ក៏ដូចជាសណ្តាប់ធ្នាប់សាធារណៈ។ ម្យ៉ាងទៀត សកម្មភាពដែលកើតចេញនោះបង្កព្យសនកម្មដល់សង្គម គេអាចសង្កេតឃើញរួមមានដូចជា សកម្មភាព ពេលវេលា ទីកន្លែង ស្លាកស្នាម និងវត្ថុតាងទាំងឡាយណាដែលប្រព្រឹត្តបទល្មើស បង្កឱ្យមានចរិតលក្ខណៈគ្រោះថ្នាក់ដល់សង្គម និងសណ្តាប់ធ្នាប់សាធារណៈ។ ត្រង់កថាខណ្ឌទី១នៃមាត្រា៤២៧ដដែលនោះក៏បានស្តែងឱ្យឃើញអំពីកត្តាអត្តនោម័តផងដែរ ក្នុងនោះគឺសំដៅទៅលើ ដោយទុច្ចរិត ដែលនេះស្តែងឱ្យឃើញអំពីការលេចឡើងនូវកិរិយាផ្លូវចិត្តរបស់ជនល្មើស ចំពោះអំពើបង្កគ្រោះថ្នាក់ដល់សង្គមដែលគេបានប្រព្រឹត្ត។ យើងអាចមើលឃើញនូវកត្តាអត្តនោម័តបាន តាមរយៈកត្តាសត្យានុម័តដែលជនល្មើសបានប្រព្រឹត្ត ព្រោះកត្តាទាំងពីរនេះមានលក្ខណៈឆ្លុះបញ្ចាំងគ្នាផងដែរ។ ម្យ៉ាងទៀតជាការសម្គាល់នូវចរិតគ្រោះថ្នាក់ ឬទិដ្ឋភាពខាងក្នុងរបស់ជនល្មើសក្នុងការប្រព្រឹត្តបទល្មើសរួមមាន កំហុស គោលបំណង និងកត្តាជម្រុញឱ្យមានបទល្មើសកើតឡើង ចំណែកទណ្ឌកម្មព្រហ្មទណ្ឌចំពោះអំពើត្រង់កថាខណ្ឌទី១នៃមាត្រា៤២៧ មានការផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជា ប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល។[៣៦]

រីឯត្រង់កថាខណ្ឌទី២នៃមាត្រា៤២៧ បានស្តែងឱ្យឃើញអំពីកត្តាសត្យានុម័តខុសពី កថាខណ្ឌទី១នៃមាត្រា៤២៧ ដោយកត្តាសត្យានុម័តក្នុងកថាខណ្ឌទី២នៃមាត្រា៤២៧ ស្តែងឱ្យឃើញពាក្យ **"អំពើនោះ"**។ អំពើនោះគឺសំដៅទៅលើ **"អំពើចូលទៅដល់ ឬស្ថិតនៅនឹងប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យដោយទុច្ចរិត"** ហើយជាហេតុបណ្តាលឱ្យមានការលុបបំបាត់ ឬកែប្រែទិន្នន័យដែលមាននៅក្នុងប្រព័ន្ធ ឬឱ្យមានការខូចខាតនូវដំណើរការនៃប្រព័ន្ធ។ ចំណែកទណ្ឌកម្មព្រហ្មទណ្ឌចំពោះអំពើត្រង់កថាខណ្ឌទី២នៃមាត្រា៤២៧ មានការ

[៣៦] មាត្រា៤២៧, កថាខណ្ឌទី១ក្រ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

ផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល។[៧៧]

យើងធ្វើការសន្និដ្ឋានបានថា កត្តាសត្យានុម័តរវាងកថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃមាត្រា៤២៧ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មានលក្ខណៈខុសគ្នា ដោយហេតុថា កត្តាសត្យានុម័តត្រង់កថាខណ្ឌទី១នៃមាត្រា៤២៧ គឺគ្រាន់តែជា "**អំពើចូលទៅដល់ ឬស្ថិតនៅ ដោយទុច្ចរិត**" តែប៉ុណ្ណោះមិនទាន់ជាហេតុបណ្តាលឱ្យមានការលុបបំបាត់ ឬ កែប្រែទិន្នន័យដែលមាននៅក្នុងប្រព័ន្ធ ឬឱ្យមានការខូចខាតនូវដំណើរការនៃប្រព័ន្ធឡើយ។ ដោយឡែកកត្តាសត្យានុម័តត្រង់កថាខណ្ឌទី២នៃមាត្រា៤២៧ គឺជា "**អំពើចូលទៅដល់ ឬស្ថិតនៅដោយទុច្ចរិត ហើយបានបង្កជាហេតុបណ្តាលឱ្យមានការលុបបំបាត់ ឬ កែប្រែទិន្នន័យដែលមាននៅក្នុងប្រព័ន្ធឬឱ្យមានការខូចខាតនូវដំណើរការនៃប្រព័ន្ធ**" ត្រង់កថាខណ្ឌទី២នៃមាត្រា៤២៧ គឺកត្តាសត្យានុម័តនៃការប្រព្រឹត្តបទល្មើសមានលក្ខណៈធ្ងន់ធ្ងរជាង កត្តាសត្យានុម័តកថាខណ្ឌទី១នៃមាត្រា៤២៧។

- **ធាតុផ្សំអត្តនោម័ត ឬធាតុចិត្តសាស្ត្រ**

ត្រង់កថាខណ្ឌទី១ និងកថាខណ្ឌទី២នៃមាត្រា៤២៧ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដដែលនោះ ក៏បានស្តែងឱ្យឃើញអំពីកត្តាអត្តនោម័តផងដែរ ក្នុងនោះគឺសំដៅទៅលើ ដោយទុច្ចរិត ដែលនេះស្តែងឱ្យឃើញអំពីការលេចឡើងនូវកិរិយាផ្លូវចិត្តរបស់ជនល្មើស ចំពោះអំពើបង្កគ្រោះថ្នាក់ដល់សង្គមដែលគេបានប្រព្រឹត្ត។ យើងអាចមើលឃើញនូវកត្តាអត្តនោម័តបាន តាមរយៈកត្តាសត្យានុម័តដែលជនល្មើសបានប្រព្រឹត្ត ព្រោះកត្តាទាំងពីរនេះមានលក្ខណៈឆ្លុះបញ្ចាំងគ្នាផងដែរ។ ម្យ៉ាងទៀតជាការសម្គាល់នូវចរិកគ្រោះថ្នាក់ ឬទិដ្ឋភាពខាងក្នុងរបស់ជនល្មើសក្នុងការប្រព្រឹត្តបទល្មើសរួមមាន កំហុស គោលបំណង និងកត្តាជម្រុញឱ្យមានបទល្មើសកើតឡើង។ កត្តាអត្តនោម័ត ក្នុងកថាខណ្ឌទី១ នៃមាត្រា៤២៧ គឺចេតនាទុច្ចរិតនូវការចូល ឬ ការស្ថិតនៅ ដោយឡែក កត្តាអត្តនោម័ត ក្នុងកថាខណ្ឌទី២ នៃមាត្រា៤២៧ គឺចេតនាទុច្ចរិតនូវការចូល ឬ ការស្ថិតនៅ ហើយបានបង្កជាហេតុបណ្តាលឱ្យមានការលុបបំបាត់ ឬ កែប្រែទិន្នន័យដែលមាននៅក្នុងប្រព័ន្ធ ឬ ឱ្យមានការខូចខាតនូវដំណើរការនៃប្រព័ន្ធ។

សរុបមកវិញ យើងសង្កេតឃើញថាក្នុង មាត្រា៤២៧ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ បទចូលទៅដល់ ឬ ស្ថិតនៅនឹងប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ ស្តែងឱ្យឃើញមានអំពើក្រោមរូបភាព២ និងមានការផ្តន្ទាទោស២ផ្សេងគ្នាផងដែរ ក៏ប៉ុន្តែអំពើទាំង២នេះស្ថិតក្នុងឈ្មោះបទល្មើសតែ១ គឺ "**បទចូលទៅដល់ ឬ ស្ថិតនៅនឹងប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ**"។

[៧៧] មាត្រា៤២៧ កថាខណ្ឌទី២ក្រ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

### ២.១.២ បទបង្កើតជាឧបសគ្គដល់ដំណើរការនៃប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ

ដើម្បីកំណត់បទល្មើសជនណាម្នាក់ដែលបានប្រព្រឹត្ត ឬចាត់ទុកថាអំពើណាមួយនោះជាបទល្មើសឱ្យបានច្បាស់លាស់យើងត្រូវដឹងថា ធាតុផ្សំនៃបទល្មើសត្រូវតែមាន ៣ធាតុសំខាន់ៗដូចធាតុផ្សំរបស់បទល្មើសទូទៅផងដែរ ក្នុងនោះរួមមានដូចជាធាតុផ្សំទី១ ធាតុនីត្យានុកូលឬធាតុច្បាប់ ធាតុផ្សំទី២ ធាតុសត្យានុម័តឬធាតុសម្ភារៈ និងធាតុផ្សំទី៣ ធាតុអត្តនោម័តឬធាតុចិត្តសាស្ត្រ។

❖ **ធាតុផ្សំនីត្យានុកូល ឬធាតុច្បាប់**

មាត្រា៤២៨ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បទបង្កើតជាឧបសគ្គដល់ដំណើរការនៃប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ បញ្ញត្តិថា

"អំពើបង្កើតជាឧបសគ្គ ធ្វើឱ្យខូចដំណើរការនៃប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល។"[78]

❖ **ធាតុផ្សំសត្យានុម័ត ឬធាតុសម្ភារៈ**

សង្កេតឃើញថា បទបង្កើតជាឧបសគ្គដល់ដំណើរការនៃប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យនៃមាត្រា៤២៨ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ស្តែងឱ្យឃើញអំពីកត្តាសត្យានុម័តនោះគឺថា ជាអំពើបង្កើតជាឧបសគ្គ ធ្វើឱ្យខូចដំណើរការនៃប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ ដែលនេះស្តែងឱ្យឃើញអំពីអំពើដែលជនល្មើសបានប្រព្រឹត្តបទល្មើសស្តែងចេញ ដោយតាមរយៈការបង្កជាឧបសគ្គដល់ដំណើរការនៃប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ។

❖ **ធាតុផ្សំអត្តនោម័ត ឬធាតុចិត្តសាស្ត្រ**

ចំពោះ បទបង្កើតជាឧបសគ្គដល់ដំណើរការនៃប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ មាត្រា៤២៨ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានបង្ហាញឱ្យឃើញនូវចេតនាទុច្ចរិតក្នុងការប្រព្រឹត្តបទល្មើសផងដែរ។

### ២.១.៣ បទបញ្ចូល លុបបំបាត់ ឬ កែប្រែដោយទុច្ចរិតនូវទិន្នន័យ

ដើម្បីកំណត់បទល្មើសជនណាម្នាក់ដែលបានប្រព្រឹត្ត ឬចាត់ទុកថាអំពើណាមួយនោះជាបទល្មើសឱ្យបានច្បាស់លាស់យើងត្រូវដឹងថា ធាតុផ្សំនៃបទល្មើសត្រូវតែមាន ៣ធាតុសំខាន់ៗដូចធាតុផ្សំរបស់បទល្មើសទូទៅផងដែរ ក្នុងនោះរួមមានដូចជាធាតុផ្សំទី១ធាតុនីត្យានុកូលឬធាតុច្បាប់ ធាតុផ្សំទី២ ធាតុសត្យានុម័តឬធាតុសម្ភារៈ និងធាតុផ្សំទី៣ធាតុអត្តនោម័តឬធាតុចិត្តសាស្ត្រ។

[៧៨] មាត្រា៤២៨ក្រ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

❖ **ធាតុផ្សំនីត្យានុកូល ឬធាតុច្បាប់**

មាត្រា៤២៩ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បទបញ្ចូល លុបបំបាត់ ឬកែប្រែដោយទុច្ចរិតនូវទិន្នន័យ បញ្ញត្តិថា

"អំពើបញ្ចូល លុបបំបាត់ ឬ កែប្រែដោយទុច្ចរិតនូវទិន្នន័យទៅក្នុងប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្ត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល។"[៧៩]

❖ **ធាតុផ្សំសត្យានុម័ត ឬធាតុសម្ភារៈ**

សង្កេតឃើញថា បទបញ្ចូល លុបបំបាត់ ឬកែប្រែដោយទុច្ចរិតនូវទិន្នន័យ មាត្រា៤២៩ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ស្តែងឱ្យឃើញអំពីកត្តាសត្យានុម័តនោះគឺថា ជាអំពើបញ្ចូល លុបបំបាត់ ឬ កែប្រែនូវទិន្នន័យទៅក្នុងប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្ត ដែលនេះស្តែងឱ្យឃើញអំពី អំពើដែលជនល្មើសបានប្រព្រឹត្តបទល្មើស។

❖ **ធាតុផ្សំអត្តនោម័ត ឬធាតុចិត្តសាស្ត្រ**

ចំពោះ បទបញ្ចូល លុបបំបាត់ ឬ កែប្រែដោយទុច្ចរិតនូវទិន្នន័យ មាត្រា៤២៩ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានបង្ហាញឱ្យឃើញនូវចេតនាទុច្ចរិតក្នុងការប្រព្រឹត្តបទល្មើសផងដែរ។

### ២.១.៤ បទចូលរួមក្នុងក្រុមប្រមូលផ្តុំ ឬ ក្នុងសន្និដ្ឋិភាពដើម្បីរៀបចំប្រព្រឹត្តបទល្មើស

ដើម្បីកំណត់បទល្មើសជនណាម្នាក់ដែលបានប្រព្រឹត្ត ឬចាត់ទុកថាអំពើណាមួយនោះជាបទល្មើសឱ្យបានច្បាស់លាស់យើងត្រូវដឹងថា ធាតុផ្សំនៃបទល្មើសត្រូវតែមាន ៣ធាតុសំខាន់ៗដូចធាតុផ្សំរបស់បទល្មើសទូទៅផងដែរ ក្នុងនោះរួមមានដូចជាធាតុផ្សំទី១ធាតុនីត្យានុកូលឬធាតុច្បាប់ ធាតុផ្សំទី២ធាតុសត្យានុម័តឬធាតុសម្ភារៈ និងធាតុផ្សំទី៣ធាតុអត្តនោម័តឬធាតុចិត្តសាស្ត្រ។

❖ **ធាតុផ្សំនីត្យានុកូល ឬធាតុច្បាប់**

មាត្រា៤៣០ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បទចូលរួមក្នុងក្រុមប្រមូលផ្តុំ ឬ ក្នុងសន្និដ្ឋិភាពដើម្បីរៀបចំប្រព្រឹត្តបទល្មើស បញ្ញត្តិថា

[៧៩] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៤២៩។

"អំពើចូលរួមទៅក្នុងក្រុមប្រមូលផ្តុំ ឬទៅក្នុងសន្និដ្ឋិភាព ដែលបង្កើតឡើងដើម្បីរៀបចំប្រព្រឹត្ត បទល្មើសដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល។"[៨០]

❖ **ធាតុផ្សំសត្យានុម័ត ឬធាតុសម្ភារៈ**

សង្កេតឃើញថា បទចូលរួមក្នុងក្រុមប្រមូលផ្តុំ ឬក្នុងសន្និដ្ឋិភាពដើម្បីរៀបចំប្រព្រឹត្តបទល្មើស មាត្រា៤៣០ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ស្តែងឱ្យឃើញអំពីកត្តាសត្យានុម័តនោះគឺថា មានលក្ខណៈជាស្ថានទម្ងន់ទោស ដែលគឺជាការប្រមូលផ្តុំដែលបានបង្កើតឡើង ឬជាសន្និដ្ឋិភាពដែលបានធ្វើឡើង ដើម្បីត្រៀមរៀបចំ ឬ ប្រព្រឹត្តបទល្មើសដែលមានចែងក្នុងផ្នែកនេះ (បទល្មើសដែលមានចែងក្នុងផ្នែកនេះ គឺសំដៅទៅដល់បទល្មើសចាប់ពីមាត្រា៤២៧ ដល់ មាត្រា៤២៩)។

❖ **ធាតុផ្សំអត្តនោម័ត ឬធាតុចិត្តសាស្ត្រ**

ចំពោះ បទចូលរួមក្នុងក្រុមប្រមូលផ្តុំ ឬ ក្នុងសន្និដ្ឋិភាពដើម្បីរៀបចំប្រព្រឹត្តបទល្មើស មាត្រា៤៣០ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានបង្ហាញឱ្យឃើញនូវចេតនាទុច្ចរិតក្នុងការប្រព្រឹត្តបទល្មើសផងដែរ។

### ២.១.៥ ការប៉ុនប៉ង

យើងសង្កេតឃើញថា មាត្រា៤៣១ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ក៏បានបញ្ញត្តិអំពីការប៉ុនប៉ង ផងដែរក្នុងជំពូកទី២ បទល្មើសក្នុងវិស័យព័ត៌មានវិទ្យា មានន័យថា កាលណាបើជននោះបានលក្ខខណ្ឌនៃការប៉ុនប៉ងមាត្រា២៧។[៨១] ទៀតសោត ការប៉ុនប៉ងបានបញ្ញត្តិរួចជាស្រេចនៅមាត្រា៤៣១ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា នោះជននោះត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិម។[៨២]

### ២.១.៦ ទោសបន្ថែម : ប្រភេទ និងរយៈពេល

សង្កេតឃើញថា ជំពូកទី ២ បទល្មើសក្នុងវិស័យព័ត៌មានវិទ្យា ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ក៏បានចែងអំពីទោសបន្ថែមផងដែរ ត្រង់មាត្រា៤៣២ ចំពោះបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែម ដូចតទៅនេះ អាចត្រូវបានប្រកាស៖

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

---

[៨០] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៤៣០។

[៨១] មាត្រា២៧ក្រ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

[៨២] មាត្រា៤៣១ក្រ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត នៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៣-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើប្រាស់សម្រាប់ ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស។

៤-ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស។

៥-ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។

៦-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសនោះ បានប្រព្រឹត្ត។

៧-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង។

៨-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន។[៩៣]

## ២.២ អំពើថ្មីៗដែលជាផ្នែកនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា

បច្ចេកវិទ្យាក៏ជាមុខព្រួញយ៉ាងសំខាន់ ដែលបង្កឱ្យមានបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជាផងដែរ។ ដោយហេតុថា មានមនុស្សឆ្លៀតឱកាសមួយចំនួនបានបង្កឱ្យមានជាបទល្មើសផ្សេងៗ។ យើងសង្កេតឃើញថាមានបទល្មើសកើតឡើងតាមរយៈការប្រើប្រាស់បច្ចេកវិទ្យា ឬប្រព័ន្ធបច្ចេកវិទ្យាធ្វើជាមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើស ដែលបញ្ហានេះកំពុងកើតមានឡើងជាច្រើនករណី និងបានបង្កឱ្យប្រជាពលរដ្ឋរងគ្រោះជាបន្តបន្ទាប់នៅកម្ពុជា ដែលជាហេតុនាំឱ្យមានបញ្ហាដល់អ្នកប្រើប្រាស់ សណ្តាប់ធ្នាប់សាធារណៈ និងសង្គម។ ម្យ៉ាងវិញទៀតថ្មីៗនេះ យើងធ្វើការសង្កេតឃើញថា មានការកើតឡើងនូវឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាក្រោមរូបភាពថ្មីៗ និងមានលក្ខណៈទ្រង់ទ្រាយធំៗប្លែកៗជាច្រើន ដែលជាផ្នែកមួយនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យា។ ឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា គឺជាបទល្មើសដែលប្រព្រឹត្តនៅក្នុងបណ្តាញបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដូចជា ការលួចចូល ការក្លែងបន្លំ ឬការកែឯកសារ ការបញ្ចូលមេរោគ ការផ្ញើសារគំរាម

[៩៣] មាត្រា៤៣២ក្រ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

ឬការចាប់ជំរិត ឬធ្វើឱ្យប៉ះពាល់ដល់សិទ្ធិឯកជនភាព សេដ្ឋកិច្ច សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងប៉ះពាល់ដល់សង្គមជាតិផងដែរ។[៨៤]

ជាមូលដ្ឋានគ្រឹះ ជួយក្នុងការឈ្វេងយល់ទៅលើប្រធានបទនេះ ដើម្បីឱ្យយល់កាន់តែច្បាស់អំពីអំពើថ្មីៗដែលជាផ្នែកនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា។ នៅក្នុងផ្នែកនេះយើងនឹងធ្វើការសិក្សាស្រាវជ្រាវអំពី **បទល្មើសបច្ចេកវិទ្យាធំៗនៅកម្ពុជា** (២.២.១) និង**បទល្មើសបច្ចេកវិទ្យាកើតមាននាពេលបច្ចុប្បន្ននៅកម្ពុជា** (២.២.២)។

### ២.២.១ បទល្មើសបច្ចេកវិទ្យាធំៗនៅកម្ពុជា

បច្ចេកវិទ្យាឌីជីថល និងបណ្តាញអ៊ីនធឺណិត បានក្លាយជាចលករដ៏មានសក្តានុពលសម្រាប់មនុស្សក្នុងសកលលោកទាំងមូល។ ទន្ទឹមនឹងការរីកចម្រើននៃបច្ចេកវិទ្យាឌីជីថល បញ្ហាប្រឈមក៏បានកំពុងកើតឡើងជារៀងរាល់ថ្ងៃ ដោយជនខិលខូច ឬឧក្រិដ្ឋជន បានទាញយកនូវបច្ចេកវិទ្យាជាមធ្យោបាយក្នុងការប្រព្រឹត្តអំពើល្មើស តួយ៉ាងមាន ការវាយប្រហារតាមបណ្តាញអ៊ីនធឺណិត អំពើឆបោកប្រាក់ អំពើលួចយកនូវទិន្នន័យ អំពើក្លែងអត្តសញ្ញាណ និងអំពើស៊ើបការសម្ងាត់ផ្សេងៗ។[៨៥]

យោងតាមរបាយការណ៍របស់ ភ្នាក់ងារសន្តិសុខសាយប័រ និងហេដ្ឋារចនាសម្ព័ន្ធអាមេរិក(The US Cybersecurity and Infrastructure Security Agency) បានរាយការណ៍ថា បទល្មើសបច្ចេកវិទ្យាបានកើនឡើង៦២% នៅឆ្នាំ២០២២ ដោយបណ្តាបទល្មើសទាំងនោះកាន់តែមានភាពសាមញ្ញជាងមុន ដូចជាការជ្រៀតចូលប្រព័ន្ធ និងការឆបោក ដោយប្រើប្រាស់បច្ចេកទេសធម្មតាទៅលើគោលដៅនៃការវាយប្រហារ។

ខាងក្រោមនេះ គឺជាប្រភេទនៃការវាយប្រហារបច្ចេកវិទ្យាធំៗ ចំនួន៥ អំឡុងឆ្នាំ២០២២៖

- ការដាក់ផ្លាក់លួចយកនូវព័ត៌មាន (Phishing Attack)
- ការខលទូរសព្ទបញ្ឆោតលួចព័ត៌មាន (Vishing Attack)
- ការវាយប្រហារផ្អាកដំណើរការប្រព័ន្ធ (Distributed Denial of Service Attacks)
- ការលួចអត្តសញ្ញាណ (Identity Theft)
- មេរោគជម្រិតទារប្រាក់ (Ransomware Attacks)។[៨៦]

---

[៨៤] ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, *ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥*, (ភ្នំពេញ៖ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, ២០២១), លេខ១២ ,ទំព័រទី៩៨។

[៨៥] https://shortifyme.co/X៩១Yc (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[៨៦] https://nw.ax/Gf៤ (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

ជាថ្មីម្តងទៀត នាយកដ្ឋានព័ត៌មានវិទ្យាសូមធ្វើការក្រើនរំលឹកដល់បងប្អូនប្រជាពលរដ្ឋ សូមមេត្តាស្វែងយល់អំពីបច្ចេកវិទ្យាដែលខ្លួនកំពុងប្រើប្រាស់ តួយ៉ាងកម្មវិធីបណ្តាញសង្គម (Facebook, Telegram, Instagram, Messenger, WhatsApp) ឧបករណ៍បច្ចេកវិទ្យា (កុំព្យូទ័រ ទូរសព្ទ ទូរទស្សន៍ កាមេរ៉ាសុវត្ថិភាព។ល។) និងធ្វើការកំណត់នូវសុវត្ថិភាព (Security Settings) បន្ថែម។[៨៧]

**២.២.១.១ ការដាក់ឆ្នាក់លួចយកព័ត៌មាន** ( Phishing attack )

កន្លងមកក្រុមការងារបច្ចេកទេសនៃនាយកដ្ឋានព័ត៌មានវិទ្យាសង្កេតឃើញថា បណ្តាបទល្មើសបច្ចេកវិទ្យាមួយចំនួនធំ តួយ៉ាងការលួចគណនីអ៊ីនធឺណេត ការឆ្លងមេរោគ ការធ្វើចារកម្មជំនួញ ឬបុគ្គលភាគច្រើនកើតឡើងដោយការចាញ់បញ្ឆោតនៃបច្ចេកទេស Phishing ពីសំណាក់ឧក្រិដ្ឋជនបច្ចេកវិទ្យា។[៨៨] ឧក្រិដ្ឋជនប្រើប្រាស់កម្មវិធីបណ្តាញសង្គម ឬអ៊ីម៉ែល ក្នុងការបញ្ឆោតជនរងគ្រោះចូលទៅកាន់គេហទំព័រក្លែងបន្លំ និងលួចយកនូវព័ត៌មាន។[៨៩]

Phishing គឺបច្ចេកទេសឆបោកលួចយកព័ត៌មាន ដូចជា លេខ Credit Card ឬលេខសម្ងាត់គណនី ហើយពេលខ្លះឧក្រិដ្ឋជនក៏ប្រើប្រាស់វិធីសាស្ត្រមួយនេះ ដើម្បីចម្លងមេរោគទៅកាន់ម៉ាស៊ីនកុំព្យូទ័រ ឬទូរសព្ទដៃរបស់ជនរងគ្រោះផងដែរ។ ក្នុងប្រតិបត្តិការ Phishing ឧក្រិដ្ឋជនបានប្រើប្រាស់ វិស្វកម្មបណ្តាញសង្គម (Social Engineering) ជាជំនួយក្នុងបច្ចេកទេសឆបោករបស់ខ្លួន។ បច្ចេកទេសវិស្វកម្មបណ្តាញសង្គម (Social Engineering) ត្រូវបានប្រើប្រាស់ក្នុងគោលបំណងលួងលោម ធ្វើឱ្យជនរងគ្រោះជឿទុកចិត្ត និងផ្តល់ព័ត៌មាន បើកមើលសារអេឡិចត្រូនិក ចុចលើតំណភ្ជាប់ផ្សេងៗ ឬ ចុចលើ File មេរោគ ជាដើម។

ដើម្បីការពារខ្លួនពីបច្ចេកទេស Phishing អ្នកត្រូវអនុវត្តវិធីសាស្ត្រ ដូចខាងក្រោម៖

- បញ្ជាក់សារតា និងគោលបំណងនៃសារអេឡិចត្រូនិកមុនពេលឆ្លើយតប
- ធ្វើការពិនិត្យតំណភ្ជាប់ តើជាគេហទំព័រពិតប្រាកដ ឬក្លែងបន្លំ
- ត្រួតពិនិត្យឯកសារភ្ជាប់ (Attachment) មុនពេលទាញយក ឬចុច (Click)
- មិនត្រូវផ្តល់លេខសម្ងាត់ ឬលេខ Credit Card ឱ្យអ្នកដទៃ
- ត្រូវតម្លើងកម្មវិធីកម្ចាត់មេរោគ និងAnti-Phishing ក្នុងម៉ាស៊ីនកុំព្យូទ័រ ឬទូរសព្ទដៃរបស់លោកអ្នក។[៩០]

---

[៨៧] https://nw.ax/Gf៤ (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[៨៨] https://www.facebook.com/share/QtW9wwt៤L9njEif៤/ (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[៨៩] https://shorturl.at/BqrPB (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[៩០] https://www.facebook.com/share/QtW9wwt៤L9njEif៤/ (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

**២.២.១.២ ការខលទូរសព្ទបញ្ឆោតលួចព័ត៌មាន** ( Vishing attack )

ការខលទូរសព្ទបញ្ឆោតលួចព័ត៌មាន (Vishing Attack)៖ ឧក្រិដ្ឋជនធ្វើការខលចូលទូរសព្ទរបស់ជនរងគ្រោះ និងបានប្រើប្រាស់បច្ចេកទេសវិស្វកម្មបណ្តាញសង្គម (Social Engineering) ដើម្បីឆបោកជនរងគ្រោះលួចយកនូវព័ត៌មាន។[៩១]

**២.២.១.៣ ការវាយប្រហារផ្អាកដំណើរការប្រព័ន្ធ** ( Distributed attack )

ការវាយប្រហារផ្អាកដំណើរការប្រព័ន្ធ (Distributed Denial of Service Attacks)៖ ឧក្រិដ្ឋជនប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យា ដែលឆ្លងនូវមេរោគ និងបញ្ជាឧបករណ៍ទាំងនោះដើម្បីចូលរួមប្រតិបត្តិការវាយប្រហារផ្អាកដំណើរការប្រព័ន្ធ។[៩២]

**២.២.១.៤ ការលួចអត្តសញ្ញាណ** ( Identify theft )

ការលួចអត្តសញ្ញាណ (Identity Theft)៖ ឧក្រិដ្ឋជនលួចយកនូវអត្តសញ្ញាណជនរងគ្រោះ ពីកម្មវិធីបណ្តាញទំនាក់ទំនងសង្គម ការជ្រៀតចូលប្រព័ន្ធ ឬឧបករណ៍ប្រើប្រាស់របស់ជនរងគ្រោះ បន្ទាប់មកយកអត្តសញ្ញាណទាំងនោះទៅប្រើប្រាស់ ឬលក់ ឬចែកចាយលើទីផ្សារងងឹតដោយខុសច្បាប់។[៩៣]

**២.២.១.៥ មេរោគជម្រិតទារប្រាក់** ( Ransomware attacks )

មេរោគជម្រិតទារប្រាក់ (Ransomware Attacks)៖ ឧក្រិដ្ឋជនប្រើប្រាស់បច្ចេកទេស Phishing ឬជាការបង្កប់មេរោគក្នុងឯកសារ (File) ដែលបានបង្ហោះចែកចាយលើបណ្តាញអ៊ីនធឺណិត ដូចជាឯកសារកម្មវិធីឬ ឯកសារវីដេអូ ជាដើម។[៩៤]

## ២.២.២ បទល្មើសបច្ចេកវិទ្យាកើតមាននាពេលបច្ចុប្បន្ននៅកម្ពុជា

យោងតាមការសិក្សាស្រាវជ្រាវអំពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន នាយកដ្ឋានព័ត៌មានវិទ្យាបានធ្វើការរៀបរាប់អំពីនិន្នាការបទល្មើសបច្ចេកវិទ្យាធំៗទាំង០៥ ដែលកំពុងកើតមានក្នុងព្រះរាជាណាចក្រកម្ពុជា មានដូចខាងក្រោម[៩៥]៖

- ការបរិហារកេរ្តិ៍លើបណ្តាញផ្សព្វផ្សាយសង្គម[៩៦]

---

[៩១] https://shorturl.at/uMtWr (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[៩២] https://shorturl.at/Frmwx (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[៩៣] https://tinyurl.com/៤tzkknj២ (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[៩៤] https://tinyurl.com/៤tzkknj២ (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[៩៥] https://tinyurl.com/yu៥dvs៤r (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[៩៦] https://www.facebook.com/share/teT៤MeHfsDRAqVVD/ (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

- ព័ត៌មានមិនពិត[៩៧]
- ការជំរិត ឬគំរាមកំហែងដោយប្រើប្រាស់រូបភាព ឬវីដេអូអាសអាភាសរបស់ជនរងគ្រោះ និងគំរាមទារប្រាក់[៩៨]
- អំពើគំរាមកំហែង ឬយាយីប្រើមធ្យោបាយអ៊ីនធឺណែត[៩៩]
- អំពើឆបោកដោយប្រើប្រាស់មធ្យោបាយបច្ចេកវិទ្យា។[១០០]

**២.២.២.១ ការបរិហារកេរ្តិ៍លើបណ្តាញផ្សព្វផ្សាយសង្គម** ( Social Media Defamation )

ការបរិហារកេរ្តិ៍លើបណ្តាញផ្សព្វផ្សាយសង្គម គឺជាការចុះផ្សាយ ការចែករំលែក ខ្លឹមសារ អត្ថបទ រូបភាព វីដេអូ ប្រឌិតក្នុងចេតនាមួលបង្កាច់ ឬបង្ខូចប្រឆាំងនឹងបុគ្គល ក្រុមហ៊ុន ឬស្ថាប័ន ដោយប្រើប្រាស់មធ្យោបាយដូចខាងក្រោម៖

- បណ្តាញទំនាក់ទំនងសង្គម (Facebook Twitter Instagram ឬ YouTube ជាដើម)
- បណ្តាញផ្សព្វផ្សាយគេហទំព័រ (គេហទំព័រ វេទិការអេឡិចត្រូនិក ឬ Blog ជាដើម)
- កម្មវិធីផ្ញើសារអេឡិចត្រូនិក (Messenger WhatsApp Telegram Line ឬ WeChat ជាដើម)[១០១]

ភាគច្រើននៃអ្នកប្រព្រឹត្តិបទល្មើសខាងលើ តែងតែយល់ថា ការចុះផ្សាយ ឬការចែករំលែក ខ្លឹមសារ អត្ថបទ រូបភាព វីដេអូ ដែលបានបរិហារកេរ្តិ៍បុគ្គល ក្រុមហ៊ុន ឬស្ថាប័ន គឺជាសិទ្ធិក្នុងការបញ្ចេញមតិប៉ុន្តែពួកគេពុំបានស្វែងយល់អំពីប្រភព និងផ្ទៀងផ្ទាត់សច្ចៈភាពនៃព័ត៌មាន ដែលខ្លួនបានចែករំលែក ឬបង្ហោះនោះឡើយ។ ដូច្នេះដើម្បីចូលរួមបង្ការ ទប់ស្កាត់បទល្មើស "បរិហារកេរ្តិ៍លើបណ្តាញផ្សព្វផ្សាយសង្គម Social Media Defamation" គឺផ្តើមចេញពីបងប្អូនប្រជាពលរដ្ឋគ្រប់រូប ដោយប្រកាន់ខ្ជាប់នូវការចុះផ្សាយ ការបង្ហោះ អត្ថបទ រូបភាព វីដេអូ ដែលមានប្រភពច្បាស់លាស់ មានខ្លឹមសារស្ថាបនា និងប្រកបដោយសេចក្តីថ្លៃថ្នូរ។[១០២]

អំពើ "បរិហារកេរ្តិ៍លើបណ្តាញផ្សព្វផ្សាយសង្គម Social Media Defamation" បានចាត់ជាបទល្មើសដែលបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មានមាត្រាចំនួនពីរ អាស្រ័យទៅលើសកម្មភាពនៃការប្រព្រឹត្តអំពើនោះរួមមាន៖

---

[៩៧] https://www.facebook.com/share/p/rjUYcG៤៦៩oTMYhdZ/ (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[៩៨] https://www.facebook.com/share/p/uo១U៨YW៩EH៧RGGEp/ (ចូលទស្សនាថ្ងៃទី១៨ មេសា ២០២៤)។

[៩៩] https://www.facebook.com/share/p/VMSHHKHYkZ៨pJZFE/ (ចូលទស្សនាថ្ងៃទី១៨ មេសា ២០២៤)។

[១០០] https://tinyurl.com/៣២៤r៣sdp (ចូលទស្សនាថ្ងៃទី១៨ មេសា ២០២៤)។

[១០១] https://www.facebook.com/share/teT៤MeHfsDRAqVVD/ (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[១០២] https://www.facebook.com/share/teT៤MeHfsDRAqVVD/ (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

- មាត្រា ៣០៥ "បទបរិហារកេរ្តិ៍ជាសាធារណៈ" បានចែងថា៖ គ្រប់ការអះអាងបំផ្លើស ឬការទំលាក់កំហុសដោយអសុទ្ធចិត្តលើអំពើណាមួយ ដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស ឬកិត្តិស័ព្ទនៃបុគ្គល ឬនៃស្ថាប័ន គឺជាការបរិហារកេរ្តិ៍ និងត្រូវពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល។[១០៣]
- មាត្រា ៥០២ "បទប្រមាថ" បានចែងថា៖ ការប្រមាថ គឺជាវាចា កាយវិការ សំណេរ គំនូរ ឬវត្ថុដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរនៃបុគ្គល។ ការប្រមាថចំពោះអ្នករាជការសាធារណៈ ឬចំពោះពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតនៅក្នុងក្របខណ្ឌនៃមុខងារឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ថ្ងៃ ទៅ ៦ (ប្រាំមួយ) ថ្ងៃ និងពិន័យជាប្រាក់ពី ១.០០០ (មួយពាន់) រៀល ទៅ ១០០.០០០ (មួយសែន) រៀល។[១០៤]

### ២.២.២.២ ព័ត៌មានមិនពិត ( Fake News )

"ព័ត៌មានមិនពិត - Fake News" គឺជាប្រភេទព័ត៌មានមិនត្រឹមត្រូវ (Misinformation) ព័ត៌មានប្រឌិត (Disinformation) ឬបោកបញ្ឆោត (False Information) ដែលបានបោះពុម្ព ឬផ្សព្វផ្សាយលើបណ្តាញផ្សព្វផ្សាយសង្គម (Social Media) ដែលមានចេតនាបំផ្លាញ ឬធ្វើឲ្យខូចកិត្តិយសដល់អង្គភាព ក្រុមហ៊ុនឬបុគ្គល ដោយហេតុផលមនោគមន៍វិជ្ជា ការសងសឹក ផលប្រយោជន៍ហិរញ្ញវត្ថុ ឬផលចំណេញផ្នែកនយោបាយជាដើម។[១០៥] ក្នុងព្រះរាជាណាចក្រកម្ពុជា "ព័ត៌មានមិនពិត - Fake News" សង្កេតឃើញមាន ០៣ប្រភេទ ធំៗ គឺ៖

១- ព័ត៌មានតិះដៀល ឬប្រមាថ (Satire or Parody)៖ ជាប្រភេទអត្ថបទប្រើពាក្យកំប្លែងលេងសើច ការនិយាយបំផ្លើសឬការសើចចំអក ការរិះគន់ហែកហួរបុគ្គល ឬក្រុមមនុស្ស ជាពិសេសក្នុងបរិបទនយោបាយ និងលើប្រធានបទផ្សេងទៀត។ មកដល់បច្ចុប្បន្ន បច្ចេកទេស Deep Fake ត្រូវបានយកមកប្រើប្រាស់ក្នុងការរចនាជាវីដេអូ ឬសម្លេង បង្កើតជាព័ត៌មានតិះដៀល ឬប្រមាថខាងលើផងដែរ។[១០៦]

---

[១០៣] មាត្រា៣០៥ក្រ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

[១០៤] មាត្រា៥០២ក្រ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

[១០៥] https://www.facebook.com/share/p/rjUYcG៤៦៩oTMYhdZ/ (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[១០៦] https://www.facebook.com/share/p/rjUYcG៤៦៩oTMYhdZ/ (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

២- ព័ត៌មានមិនពិត (Misleading News)៖ ជាប្រភេទអត្ថបទដែលដកស្រង់ព័ត៌មាន ឬការស្រាវជ្រាវផ្សេងៗ មកបន្ថែមអត្ថន័យហួសការពិត និងមិនឆ្លុះបញ្ចាំងអំពីខ្លឹមសារដើម (Misinformation) ក្នុងគោលបំណងទាក់ទាញអ្នកទស្សនា។[១០៧]

៣- ព័ត៌មានបោកបញ្ឆោតដោយចេតនា (Clickbait)៖ ជាប្រភេទព័ត៌មានមិនពិត (Disinformation) ឬបោកបញ្ឆោត (False Information) ដែលបង្កើតឡើងដោយចេតនាដើម្បីរកលុយតាមរយៈចំនួននៃការចុច ឬចំនួនទស្សនា ឬជាការឃោសនាបង្កើតឲ្យមានការភ័ន្តច្រឡំលើអ្វីមួយ។[១០៨]

ដើម្បីចូលរួមប្រយុទ្ធប្រឆាំងនឹងព័ត៌មានមិនពិត និងដើម្បីសុខមាលភាពសង្គមជាតិ បងប្អូនប្រជាពលរដ្ឋអាចអនុវត្តវិធីសាស្ត្រមួយចំនួន ដើម្បីកំណត់សុក្រិតភាពនៃព័ត៌មាន ដូចសង្ខេបជូនខាងក្រោម៖

- អានខ្លឹមសារអត្ថបទ និងស្វែងយល់អំពីប្រភពនៃព័ត៌មាន (អ្នកនិពន្ធ គេហទំព័រ)
- ធ្វើការផ្ទៀងផ្ទាត់អត្ថបទ ពីប្រភពផ្សេងៗ
- ធ្វើការត្រួតពិនិត្យកាលបរិច្ឆេទអត្ថបទ
- ធ្វើការប្រឹក្សាយោបល់ជាមួយបងប្អូន ឬមិត្តភក្តិ មុននឹងផ្សព្វផ្សាយបន្ត
- ធ្វើការរាយការណ៍ព័ត៌មានមិនពិត (ឧទាហរណ៍ Report Post) ទៅកាន់ក្រុមហ៊ុនផ្សព្វផ្សាយសង្គម ឬរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ច។[១០៩]

មាត្រាចែងពាក់ព័ន្ធនឹងបទល្មើសផ្សព្វផ្សាយព័ត៌មានមិនពិត ក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា៖

- មាត្រា ៣០៥ "បទបរិហារកេរ្តិ៍ជាសាធារណៈ" បានចែងថា៖ គ្រប់ការអះអាងបំផ្លើស ឬការទំលាក់កំហុសដោយអសុទ្ធចិត្តលើអំពើណាមួយ ដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស ឬកិត្តិស័ព្ទនៃបុគ្គល ឬនៃស្ថាប័ន គឺជាការបរិហារកេរ្តិ៍ និងត្រូវពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល។[១១០]
- មាត្រា ៥០២ "បទប្រមាថ" បានចែងថា៖ ការប្រមាថ គឺជាវាចា កាយវិការ សំណេរ គំនូរ ឬវត្ថុដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរនៃបុគ្គល។ ការប្រមាថចំពោះអ្នករាជការសាធារណៈ ឬចំពោះពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត នៅក្នុងក្របខណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញ

[១០៧] https://www.facebook.com/share/p/rjUYcG៤៦៩oTMYhdZ/ (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[១០៨] https://www.facebook.com/share/p/rjUYcG៤៦៩oTMYhdZ/ (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[១០៩] https://www.facebook.com/share/p/rjUYcG៤៦៩oTMYhdZ/ (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[១១០] មាត្រា៣០៥ក្រ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

មុខងាររបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ថ្ងៃ ទៅ ៦ (ប្រាំមួយ) ថ្ងៃ និងពិន័យជាប្រាក់ពី ១.០០០ (មួយពាន់) រៀល ទៅ ១០០.០០០ (មួយសែន) រៀល។[១១១]

**២.២.២.៣ ការជំរិត ឬគំរាមកំហែងដោយប្រើប្រាស់រូបភាព ឬវីដេអូអាសអាភាសរបស់ជនរងគ្រោះ និងគំរាមទារប្រាក់**( Sex Extortion )

ការជំរិត ឬគំរាមកំហែងដោយប្រើប្រាស់រូបភាព ឬវីដេអូអាសអាភាសរបស់ជនរងគ្រោះ និងគំរាមទារប្រាក់ គឺជាអំពើបោកបញ្ឆោតលួចថតយករូបភាព ឬវីដេអូអាសអាភាសរបស់ជងរងគ្រោះ និងគំរាមទារប្រាក់។ បទល្មើសមួយចំនួនកើតឡើងពីសំណាក់ឧក្រិដ្ឋជនមានជាអង្គការចាត់តាំង ប៉ុន្តែមួយចំនួនកើតឡើងដោយដៃគូស្នេហាជាដើម។[១១២]

បទល្មើសលួចថតរូបភាព ឬវីដេអូអាសអាភាស និងគំរាមទារប្រាក់ (Sex Extortion)៖ ដើម្បីសម្រេចគោលបំណង ឧក្រិដ្ឋជនប្រើប្រាស់គ្រប់មធ្យោបាយដាក់ធ្លាក់បោកប្រាស់មនោសញ្ចេតនាជនរងគ្រោះ ក្នុងគោលបំណងអូសទាញរួមភេទតាមរយៈអនឡាញ បន្ទាប់មកលួចថតរូបភាព ឬវីដេអូជនរងគ្រោះ និងគំរាមទារប្រាក់ (ការបង់ប្រាក់ច្រើនដំណាក់កាលឥតឈប់ឈរ)។ បទល្មើសប្រភេទនេះ កំពុងកើតមានឡើងជាច្រើនករណី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងនោះជនរងគ្រោះភាគច្រើនជាស្ត្រី (សិស្សសាលា ឬឈ្នួញរកស៊ី) និងចំណែកបុរសភាគច្រើនជា បុគ្គលិកក្រុមហ៊ុន ដែលធ្លាក់ក្នុងការឆបោកពីសំណាក់ក្រុមឧក្រិដ្ឋជនក្រៅប្រទេស។ បើអ្នកក្លាយជាជនរងគ្រោះនៃបទល្មើសប្រភេទនេះ សូមធ្វើការរាយការណ៍ដល់មន្ត្រីដែលមានសមត្ថកិច្ច។[១១៣]

បច្ចុប្បន្ននេះ យើងសង្កេតឃើញថាមានករណីថតរូបភាព ឬវីដេអូអាសអាភាសគំរាមទារប្រាក់ (Sex Extortion) ជាច្រើនកំពុងកើតមានឡើងក្នុងព្រះរាជាណាចក្រកម្ពុជា ជនល្មើសបានប្រើប្រាស់មធ្យោបាយមួយចំនួនដូចខាងក្រោម៖

- មធ្យោបាយទី១៖ ប្រើប្រាស់នារីស្អាតៗ ដើម្បីទាក់ទាញជនរងគ្រោះ ធ្វើការសន្ទនាអនឡាញ ប្រើប្រាស់សកម្មភាពស្រើបស្រាល អូសទាញជនរងគ្រោះប្រព្រឹត្តសកម្មភាពរួមភេទ មុខកុំព្យូទ័រ ឬទូរសព្ទដៃ និងធ្វើការថតសកម្មភាពទាំងនោះ គំរាមទារប្រាក់។
- មធ្យោបាយទី២៖ ប្រើប្រាស់គេហទំព័រអាសអាភាស បញ្ចូលកម្មវិធីសន្ទនាអនឡាញ ឬផ្ទាំងបើកវីដេអូដែលបញ្ជា Webcam ដើម្បីលួចថតសកម្មភាពជនរងគ្រោះ និងធ្វើការគំរាមទារប្រាក់។

---

[១១១] មាត្រា៥០២ក្រ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

[១១២] https://www.facebook.com/share/p/n៣erVBh៨Rnfjesws/ (ចូលទស្សនាថ្ងៃទី២០ មិថុនា ២០២៤)។

[១១៣] https://www.facebook.com/share/p/uo១U៨YW៩EH៧RGGEp/ (ចូលទស្សនាថ្ងៃទី១៨ មេសា ២០២៤)។

- មធ្យោបាយទី៣៖ ប្រើប្រាស់មធ្យោបាយផ្សេងៗ ក្នុងការចម្លងមេរោគទៅកាន់ម៉ាស៊ីនកុំព្យូទ័រ ឬទូរសព្ទដៃ ប្រើប្រាស់ Webcam ថតសកម្មភាពផ្សេងៗ និងធ្វើការគំរាមទារប្រាក់។

ប្រសិនអ្នកជួបករណី ដូចជម្រាបជូនខាងលើ៖

១. អញ្ជើញជួបជាមួយមន្ត្រីជំនាញ ដើម្បីធ្វើការប្រឹក្សា ដាក់ពាក្យបណ្តឹង និងស្វែងរកជនល្មើស

២. ការបង់ប្រាក់មិនមែនជាមធ្យោបាយ ព្រោះអ្នកនឹងត្រូវបង់បន្តបន្ទាប់

៣. ធ្វើការបិទគណនីបណ្តាញសង្គមបណ្តោះអាសន្ន

៤. ប្រើប្រាស់កម្មវិធីកម្ចាត់មេរោគ ស្កេន និងសម្អាតមេរោគក្នុងម៉ាស៊ីនកុំព្យូទ័រ ឬទូរសព្ទដៃ

៥. ប្រើប្រាស់ Sticker បិទ Webcam នៅពេលមិនប្រើប្រាស់។[១១៤]

**២.២.២.៤ អំពើគំរាមកំហែង ឬយាយីប្រើមធ្យោបាយអ៊ីនធឺណែត** (Cyberbully/CyberHarassment)

អំពើគំរាមកំហែង ឬយាយីប្រើប្រាស់មធ្យោបាយអ៊ីនធើណេត (Cyberbully/CyberHarassment) ជាអំពើគំរាមកំហែង ឬយាយីទាំងឡាយ ដែលប្រើប្រាស់អ៊ីនធើណេតជាមធ្យោបាយ តួយ៉ាងដូចជា៖ បណ្តាញទំនាក់ទំនងសង្គម (Facebook, Twitter, Instagram) វេទិកាអេឡិចត្រូនិក (Online Forum) សារអេឡិចត្រូនិក (Email, Messenger) ឬគេហទំព័រ (Website, Blog)។[១១៥] បទល្មើសប្រភេទនេះកំពុងកើតឡើងគួរឱ្យកត់សម្គាល់ ក្នុងព្រះរាជាណាចក្រកម្ពុជា ពិសេសក្នុងចំណោមយុវវ័យ។ បទល្មើសនេះ ក៏អាចបង្កឱ្យជនរងគ្រោះកើតជំងឺផ្លូវចិត្ត ចាកឆ្ងាយពីសង្គម និងក្រុមគ្រួសារ ឬឈានដល់ធ្វើអត្តឃាត។[១១៦]

អំពើយាយី (Bully) បានកើតមានស្ទើរគ្រប់ទីកន្លែង តួយ៉ាងនៅសាលារៀន កន្លែងធ្វើការ ក្នុងសហគមន៍ ឬទីកន្លែងផ្សេងៗ ដែលប្រព្រឹត្តដោយបុគ្គល ឬក្រុមមនុស្ស គោលដៅដាក់សម្ពោធផ្លូវចិត្តដល់ជនរងគ្រោះ។ ដោយសារភាពរីកចម្រើនផ្នែកបច្ចេកវិទ្យា អំពើយាយីបានពង្រីកវិសាលភាព ដោយប្រើប្រាស់បច្ចេកវិទ្យា និងអ៊ីនធឺណេតជាមធ្យោបាយផ្តោតលើជនរងគ្រោះ។[១១៧]

តាមរយៈរបាយការណ៍របស់ អង្គការមូលនិធិសម្រាប់កុមារអន្តរជាតិរបស់អង្គការសហប្រជាជាតិ (UNICEF) បានបង្ហាញថាយុវជនកម្ពុជាដែលមានអាយុចន្លោះពី ១៥ឆ្នាំ ដល់ ២៥ឆ្នាំ ប្រមាណ៨៥.៧% កំពុងជួបបញ្ហានៃការយាយីដោយប្រើប្រាស់បច្ចេកវិទ្យា និងអ៊ីនធឺណេត ក្នុងពេលដែលចំនួនអ្នកប្រើប្រាស់អ៊ីនធឺណេតនៅកម្ពុជាមានប្រមាណ៩.៧ លាននាក់ (៦០%នៃចំនួនប្រជាជនសរុប)។ លើសពីនេះក្នុងរបាយ

---

[១១៤] https://www.facebook.com/share/TzKp៧LAJ៥pvsP២VE/ (ចូលទស្សនាថ្ងៃទី១៨ មេសា ២០២៤)។

[១១៥] https://www.facebook.com/share/p/VMSHHKHYkZ៨pJZFE/ (ចូលទស្សនាថ្ងៃទី១៨ មេសា ២០២៤)។

[១១៦] https://www.facebook.com/share/p/VMSHHKHYkZ៨pJZFE/ (ចូលទស្សនាថ្ងៃទី១៨ មេសា ២០២៤)។

[១១៧] https://www.facebook.com/share/bKqdRQFRm៣mrkAfF/ (ចូលទស្សនាថ្ងៃទី១៨ មេសា ២០២៤)។

ការណ៍ស្រាវជ្រាវរបស់ "Cambodia Education" បង្ហាញពីស្ថិតិនៃផលប៉ះពាល់កើតឡើងដោយអំពើយាយី (Bully) ដូចខាងក្រោម៖

- កុមារ និងយុវជនកម្ពុជាប្រមាណ ១៦០០០០នាក់ បានបោះបង់ការសិក្សា
- ក្នុងនោះមានយុវជនថ្នាក់វិទ្យាល័យ ប្រមាណ ១៤% បានព្យាយាមធ្វើអត្តឃាត
- ការចាកចេញពីផ្ទះ ចូលរួមសង្គមងងឹត ពេស្យាចារ និងអំពើល្មើសច្បាប់ផ្សេងៗ
- លើសពីនេះមានផលប៉ះពាល់ជាច្រើនទៀត ដែលកើតឡើងដោយអំពីយាយីនេះ។

ដើម្បីចូលរួមប្រយុទ្ធប្រឆាំងអំពើយាយីដូចបានរៀបរាប់ខាងលើ ក្រៅពីស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល អាណាព្យាបាល គណៈគ្រប់គ្រងសាលា និងសាស្ត្រាចារ្យ គឺជាបុគ្គលសំខាន់ទាមទារក្នុងការចូលរួមប្រយុទ្ធប្រឆាំងអំពើយាយីមកលើកុមារ និងយុវជន ដែលជាធនធានមនុស្សសម្រាប់សង្គមជាតិ៖

១- អាណាព្យាបាល៖ គឺជាបុគ្គលសំខាន់ក្នុងដំណើរការពារ និងទប់ស្កាត់អំពើយាយី ដោយអនុវត្តនូវវិធីសាស្ត្រដូចខាងក្រោម៖

- ធ្វើការអប់រំបុត្រធីតាខ្លួនអំពីអំពើយាយី និងផលប៉ះពាល់
- លើកទឹកចិត្តបុត្រធីតា ក្នុងការរាយការណ៍ជូនគណៈគ្រប់គ្រងសាលា អាណាព្យាបាល ពេលជួប ឬបានឃើញនូវអំពើយាយីមកលើខ្លួន ឬមិត្តរួមថ្នាក់
- ណែនាំបុត្រធីតា ឱ្យចេះលើកទឹកចិត្តមិត្តរួមថ្នាក់ដែលរងគ្រោះដោយអំពើយាយី
- ធ្វើការសង្កេត ស្វែងយល់ និងលើកទឹកចិត្តបុត្រធីតា របស់ខ្លួន និងធ្វើការរាយការណ៍ជូនគណៈគ្រប់គ្រងសាលា នៅពេលរកឃើញអំពើយាយីផ្សេងៗ

២- គណៈគ្រប់គ្រងសាលា និងសាស្ត្រាចារ្យ៖ ក្នុងនាមជាមជ្ឈមណ្ឌលផ្តល់ការអប់រំ ក្នុងដំណើរការពារ និងទប់ស្កាត់អំពើយាយី ដោយអនុវត្តនូវវិធីសាស្ត្រដូចខាងក្រោម៖

- បង្កើតនូវបទបញ្ញត្តិ បទបញ្ជាផ្ទៃក្នុង ស្តីពីអំពើយាយី
- ធ្វើការបញ្ជ្រាបចំណេះដឹងដល់កុមារ និងយុវជន ដោយបង្ហាញអំពីទោសទណ្ឌ និងផលប៉ះពាល់នៃអំពើយាយី
- ធ្វើការអង្កេត និងស្រាវជ្រាវ នៅពេលជួបនូវករណីយាយីផ្សេងៗ
- សហការផ្តល់ដំណឹងដល់អាណាព្យាបាល នៅពេលដែលបុត្រធីតារបស់ពួកគាត់ ជួបនូវបញ្ហានៃអំពើយាយី ឬជាអ្នកប្រព្រឹត្តអំពើយាយីផ្សេងៗ។[១១៨]

[១១៨] https://www.facebook.com/share/bKqdRQFRmmmrkAfF/ (ចូលទស្សនាថ្ងៃទី១៨ មេសា ២០២៤)។

**២.២.២.៥ អំពើឆបោកដោយប្រើប្រាស់មធ្យោបាយបច្ចេកវិទ្យា** (Money Scam)

សកម្មភាពឆបោកប្រាក់តាមប្រព័ន្ធបច្ចេកវិទ្យា ពិសេសលើបណ្តាញទំនាក់ទំនងសង្គម ជាច្រើនករណីបន្តកើតមានឡើងក្នុងព្រះរាជាណាចក្រកម្ពុជា។ អំពើឆបោកប្រាក់ប្រើប្រាស់មធ្យោបាយបច្ចេកវិទ្យា (Money Scam) ជាការលួងលោមឆបោកជនរងគ្រោះថានឹងឲ្យរបស់មានតម្លៃ ឬប្រាក់ដល់ជនរងគ្រោះ និងតម្រូវជនរងគ្រោះបង់ប្រាក់មួយចំនួនដើម្បីសម្រួលនីតិវិធី សេវាដឹកជញ្ជូន ឬសេវាពន្ធ ប៉ុន្តែពុំមានរបស់ ឬប្រាក់បានប្រគល់ជូនជនរងគ្រោះដូចការសន្យានោះឡើយ។ ដើម្បីសម្រេចគម្រោងឆបោក ដំបូងឧក្រិដ្ឋជនបានស្វែងរកលេខទូរសព្ទ ឬអ៊ីម៉ែលរបស់ជនរងគ្រោះលើបណ្តាញទំនាក់ទំនងសង្គម គេហទំព័រទិញលក់ ឬគេហទំព័រស្វែងរកការងារជាដើម។ បន្ទាប់មកឧក្រិដ្ឋជនធ្វើការទាក់ទងទៅកាន់ជនរងគ្រោះ ដោយប្រើប្រាស់បច្ចេកទេសឆបោកមួយចំនួនដូចខាងក្រោម(មានច្រើនជាងនេះ)៖

១-ប្រាប់ជនរងគ្រោះថាទទួលបានកេរមរតកពីសេដ្ឋីក្រៅប្រទេស នូវទឹកប្រាក់រាប់លានដុល្លារអាមេរិក និងតម្រូវប្រាក់កក់ដើម្បីរត់ការឯកសារ ឬផ្ទេរប្រាក់។

២-ប្រាប់ជនរងគ្រោះថាឈ្នះរង្វាន់ធំពីកម្មវិធីឆ្នោតផ្សេងៗដែលមានទំហំទឹកប្រាក់រាប់ម៉ឺនដុល្លារអាមេរិក និងតម្រូវប្រាក់កក់ដើម្បីរត់ការឯកសារ ឬផ្ទេរប្រាក់។

៣-ប្រាប់ជនរងគ្រោះថាខ្លួនមានឧបករណ៍ និងក្រដាសបោះពុម្ពប្រាក់ និងតម្រូវប្រាក់កក់ដើម្បីបញ្ជូនឧបករណ៍ទាំងនោះទៅឱ្យជនរងគ្រោះ។

៤-ប្រាប់ជនរងគ្រោះថាឈ្នះរង្វាន់ទទួលបានសិទ្ធិរស់នៅក្រៅប្រទេស និងតម្រូវប្រាក់កក់ដើម្បីរត់ការឯកសារ។

៥-ប្រាប់ជនរងគ្រោះថាទទួលបានការងារក្រៅប្រទេស និងតម្រូវប្រាក់កក់ដើម្បីរត់ការឯកសារ។

៦-ដាក់លក់ ឬដេញថ្លៃទំនិញអនឡាញដែលមានតម្លៃថោកជាងតម្លៃទីផ្សារ និងតម្រូវជនរងគ្រោះទូទាត់ប្រាក់មុនបញ្ជូនទំនិញ។

៧-ប្រាប់ជនរងគ្រោះថាពួកគេបានគ្រប់គ្រងកុំព្យូទ័រ ឬទូរសព្ទដៃ និងបានថតសកម្មភាពអាក្រាតកាយជនរងគ្រោះ និងតម្រូវជនរងគ្រោះបង់ប្រាក់ជាថ្នូរនឹងការលុបរូបភាព ឬវីដេអូទាំងនោះ។

៨-ប្រាប់ជនរងគ្រោះថានឹងទទួលបានប្រាក់ចំណេញទ្វេដង (Money-Flipping) ប្រសិនជនរងគ្រោះបណ្តាក់ទុនជាមួយខ្លួន។

៩-បន្លំគណនីបណ្តាញទំនាក់ទំនងសង្គម ជាបុរស ឬនារីស្អាតៗ ប្រើប្រាស់មនោសញ្ចេតនាឆបោកប្រាក់ពីជនរងគ្រោះ (Romantic Scam)។

រាល់ឧបាយកលដូចរៀបរាប់ខាងលើ បន្ទាប់ពីទទួលបានប្រាក់ពីជនរងគ្រោះ ឧក្រិដ្ឋជនពុំបានធ្វើតាមការសន្យា ផ្ទុយទៅវិញ ពួកគេព្យាយាមប្រើប្រាស់ហេតុផលផ្សេងៗ ដើម្បីទទួលបានប្រាក់ជាបន្តបន្ទាប់ពីជនរងគ្រោះនាយកដ្ឋានព័ត៌មានវិទ្យាសូមក្រើនរំលឹកបងប្អូន មេត្តាពិចារណា កុំឱ្យក្លាយខ្លួនជាជនរងគ្រោះ និងធ្វើសេចក្តីរាយការណ៍ ឬដាក់ពាក្យបណ្តឹងដល់អាជ្ញាធរមានសមត្ថកិច្ច នៅពេលជួបប្រទះបទល្មើសខាងលើ។[១១៩]

## ២.៣ ក្រសួង និងស្ថាប័នមានសមត្ថកិច្ចលើបទល្មើសក្នុងវិស័យព័ត៌មានវិទ្យា

យើងឃើញថាចំពោះបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា ក្រសួងដែលមានសមត្ថកិច្ចនោះគឺក្រសួងមហាផ្ទៃ។ យោងតាមមាត្រា១ ព្រះរាជក្រម នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ "ត្រូវបានបង្កើតក្រសួងមហាផ្ទៃ ចំណុះឱ្យរាជរដ្ឋាភិបាលកម្ពុជា"។[១២០]

### ២.៣.១ ក្រសួងមហាផ្ទៃ

ក្រសួងមហាផ្ទៃ មានសមត្ថកិច្ចដឹកនាំគ្រប់គ្រងរដ្ឋបាលដែនដីគ្រប់ថ្នាក់លើវិស័យរដ្ឋបាលដឹកនាំគ្រប់គ្រងនគរបាលជាតិ ការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងការពារសុវត្ថិភាពជូនប្រជាពលរដ្ឋក្នុងព្រះរាជាណាចក្រកម្ពុជា។[១២១] ក្រសួងមហាផ្ទៃ មានបេសកកម្មដឹកនាំ គ្រប់គ្រងរដ្ឋបាលដែនដីគ្រប់ថ្នាក់លើវិស័យនយោបាយរដ្ឋបាល គ្រប់គ្រងកងកម្លាំងនគរបាលជាតិលើវិស័យសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមក្នុងព្រះរាជាណាចក្រកម្ពុជា។[១២២]

ក្រសួងមហាផ្ទៃ មានតួនាទី ភារកិច្ចៈ

- បញ្ជា ដឹកនាំ កងកម្លាំងនគរបាលជាតិ គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានីខេត្ត ព្រមទាំងសហការសម្របសម្រួលជាមួយសមត្ថកិច្ចពាក់ព័ន្ធដទៃទៀត ក្នុងការថែរក្សាការពារសន្តិសុខជាតិ ពង្រឹងសណ្តាប់ធ្នាប់សាធារណៈ និងធានាសុវត្ថិភាពសង្គមក្នុងព្រះរាជាណាចក្រកម្ពុជា
- ទទួលអនុវត្តភារកិច្ច និងសិទ្ធិផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ឱ្យ។ល។[១២៣]

ទៀតសោត រចនាសម្ព័ន្ធនៃក្រសួងមហាផ្ទៃឃើញថាមានស្ថាប័នជំនាញជាច្រើន។ ដោយឡែកយើងនឹងលើកយកស្ថាប័នជំនាញធំៗចំនួនពីរដែលសំខាន់ ក៏ដូចជាពាក់ព័ន្ធក្នុងការអនុវត្តទៅលើ បទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជាផងដែរ។ ដូច្នេះ ដើម្បីមើលឱ្យឃើញអំពីស្ថាប័នជំនាញទៅលើបទល្មើសក្នុងវិស័យ

---

[១១៩] https://tinyurl.com/៣២៨r៣sdp (ចូលទស្សនាថ្ងៃទី១៨ មេសា ២០២៤)។

[១២០] ច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ, ព្រះរាជក្រម នស/រកម/០១៩៦/០៨, ២៤ មករា ១៩៩៦, មាត្រា១។

[១២១] ច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ, ព្រះរាជក្រម នស/រកម/០១៩៦/០៨, ២៤ មករា ១៩៩៦, មាត្រា២។

[១២២] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ, លេខ១០៩អនក្រ.បក,១៩ សីហា ២០១៥, មាត្រា៤។

[១២៣] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ, លេខ១០៩អនក្រ.បក,១៩ សីហា ២០១៥, មាត្រា៥។

ព័ត៌មានវិទ្យា ក្នុងផ្នែកនេះយើងនឹងធ្វើការសិក្សាចែកចេញជា ពីរ រួមមាន **អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ** (២.៣.១.១) និង**នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា** (២.៣.១.២)។

**២.៣.១.១ អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ**

អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយការអប់រំ ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ២៧៩ អនក្រ.បកចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ត្រូវបានបង្កើត និងកែសម្រួលរចនាសម្ព័ន្ធឡើងវិញព្រមទាំងកំណត់តួនាទីភារកិច្ចនៅក្នុងអនុក្រឹត្យនេះផងដែរ។[១២៤] អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ មានតួនាទីភារកិច្ចធ្វើជាសេនាធិការជូនក្រសួងមហាផ្ទៃក្នុងការដឹកនាំ គ្រប់គ្រង សម្របសម្រួល គោលនយោបាយ អភិបាលកិច្ច ហេដ្ឋារចនាសម្ព័ន្ធ សុវត្ថិភាព បច្ចេកវិទ្យាឌីជីថល ការងារបណ្តុះបណ្តាល ស្រាវជ្រាវ នវានុវត្តន៍ និងផ្សព្វផ្សាយការអប់រំពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាឌីជីថល។[១២៥]

អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំមានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- សហការរៀបចំសេចក្តីព្រាងច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្ត ដើម្បីធានាដល់ការគ្រប់គ្រង ការអភិវឌ្ឍ ការការពារសន្តិសុខ និងការទប់ស្កាត់បទល្មើសបច្ចេកវិទ្យា
- រៀបចំ គ្រប់គ្រង តាមដាន និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាឌីជីថលរបស់ក្រសួងមហាផ្ទៃ
- សហការបណ្តុះបណ្តាល និងផ្សព្វផ្សាយបញ្ជ្រាបចំណេះដឹង អំពីបច្ចេកវិទ្យាឌីជីថល សន្តិសុខសាយប័រ សម្រាប់អង្គភាពចំណុះក្រសួងមហាផ្ទៃទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឬស្ថាប័នពាក់ព័ន្ធផ្សេងទៀត
- សហការជាមួយនឹងអង្គភាពពាក់ព័ន្ធក្នុងការចាត់វិធានការដោះស្រាយ និងឆ្លើយតបលើបញ្ហាសន្តិសុខសាយប័រ ការវាយប្រហារប្រព័ន្ធព័ត៌មាន និងបច្ចេកវិទ្យាឌីជីថល
- សហការជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីរួមចំណែកក្នុងការបង្ការ ទប់ស្កាត់បទល្មើសបច្ចេកវិទ្យា ។ល។[១២៦]

---

[១២៤] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ នៃក្រសួងមហាផ្ទៃ, លេខ ៣០៣អនក្រ.បក, ៣ តុលា ២០២៣, មាត្រា១។

[១២៥] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ នៃក្រសួងមហាផ្ទៃ, លេខ ៣០៣អនក្រ.បក, ៣ តុលា ២០២៣, មាត្រា២។

[១២៦] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ នៃក្រសួងមហាផ្ទៃ, លេខ៣០៣ អនក្រ.បក, ៣ តុលា ២០២៣, មាត្រា៣។

ដូចនេះដើម្បីធ្វើការសិក្សាស្រាវជ្រាវឱ្យបានកាន់តែស៊ីជម្រៅ យើងនឹងធ្វើការសិក្សាបន្ថែមទៀតនៅចំណុច (២.៣.១.២) ខាងក្រោមនេះដូចតទៅ។

**២.៣.១.២ នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា**

នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា បង្កើតឡើងតាមរយៈអនុក្រឹត្យលេខ១០៩ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ។[១២៧] យោងតាមអនុក្រឹត្យលេខ១០៩ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា ជានាយកដ្ឋានចំណុះអគ្គស្នងការនគរបាលជាតិនៃក្រសួងមហាផ្ទៃ មានតួនាទីជាសេនាធិការក្នុងការសិក្សារៀបចំគោលការណ៍ គោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាពលើការបង្ការ ទប់ស្កាត់ សំដៅរួមចំណែកការពារសន្តិសុខជាតិ រក្សាសណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គម។[១២៨]

នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យាមានភារកិច្ចដូចខាងក្រោម៖

- សិក្សារៀបចំគោលការណ៍ វិធានការ យុទ្ធសាស្ត្រ និងផែនការសកម្មភាពលើការបង្ការ ទប់ស្កាត់ ស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបបទល្មើសបច្ចេកវិទ្យា
- ស៊ើបអង្កេត និងចាត់វិធានការតាមច្បាប់ចំពោះសកម្មភាពញុះញ៉ង់ ជេរប្រមាថ រើសអើងពូជសាសន៍ បង្កចលាចលក្នុងសង្គម តាមប្រព័ន្ធអ៊ីនធឺណិត
- ស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបការជ្រៀតជ្រែកចូល និងបំផ្លិចបំផ្លាញប្រព័ន្ធព័ត៌មានវិទ្យា ការបង្កើតមេរោគកុំព្យូទ័របំផ្លាញឯកសារ ឬបង្កការរំខានដល់ដំណើរការប្រព័ន្ធបច្ចេកវិទ្យា និងការធ្វើចារកម្មទិន្នន័យ
- ស្រាវជ្រាវស៊ើបអង្កេត និងបង្ក្រាបការបើកល្បែងស៊ីសងខុសច្បាប់ តាមប្រព័ន្ធអ៊ីនធឺណិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ស្រាវជ្រាវស៊ើបអង្កេត និងបង្ក្រាបបទល្មើសក្លែងបន្លំលួចប្រាក់តាមប្រព័ន្ធធនាគារ
- សហការជាមួយបណ្តាស្ថាប័នរដ្ឋ និងឯកជន ដែលផ្គត់ផ្គង់សេវាបច្ចេកវិទ្យា និងទូរគមនាគមន៍គ្រប់ប្រភេទដើម្បីគ្រប់គ្រងលិខិតបទដ្ឋានជួល ជាវសេវាទូរគមនាគមន៍បម្រើឱ្យការស្រាវជ្រាវ ស៊ើបអង្កេត ប្រមូលភស្តុតាង និងបង្ក្រាបបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា ដែលធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម។ល។[១២៩]

---

[១២៧] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ, លេខ១០៩អនក្រ.បក, ១៩ សីហា ២០១៥, មាត្រា២៩។
[១២៨] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ, លេខ១០៩អនក្រ.បក, ១៩ សីហា ២០១៥, ចំណុចទី៥.៦,មាត្រា២៩។
[១២៩] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ, លេខ១០៩អនក្រ.បក, ១៩ សីហា ២០១៥, ចំណុចទី៥.៦,មាត្រា២៩។

## ២.៤ នីតិវិធីនៃការដាក់ពាក្យបណ្តឹង

ចំពោះនីតិវិធីនៃការដាក់ពាក្យបណ្តឹងទៅលើបទល្មើសដែលបានកើតឡើង តាមរយៈការប្រើប្រាស់បច្ចេកវិទ្យា ឬប្រព័ន្ធបច្ចេកវិទ្យា ឬប្រព័ន្ធប្រតិបត្តិការបច្ចេកវិទ្យា ជាមធ្យោបាយក្នុងការបោកបញ្ឆោតតាមរយៈអនឡាញ (Online) ឬបទល្មើសបច្ចេកវិទ្យាផ្សេងៗទៀតនោះ នាពេលថ្មីៗនេះប្រសិនបើក្នុងករណីដែលអ្នកប្រើប្រាស់ត្រូវបានរងគ្រោះអាចធ្វើការដាក់ពាក្យបណ្តឹងបានដោយផ្ទាល់ ឬ តាមរយៈអនឡាញ (Online)។

### ២.៤.១ ការដាក់ពាក្យបណ្តឹងដោយផ្ទាល់

ប្រសិនបើលោកអ្នកជួបប្រទះបញ្ហាដូចជា ការលួច(hack) យក Facebook Account ឬការបោកប្រាស់តាមប្រព័ន្ធបណ្តាញសង្គមផ្សេងៗ លោកអ្នកអាចមកដាក់ពាក្យបណ្តឹងនៅ នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា នៅក្រសួងមហាផ្ទៃ មហាវិថីព្រះនរោត្តម ខណ្ឌចំការមន អគារ L។[១៣០]

### ២.៤.២ ការដាក់ពាក្យបណ្តឹងតាមប្រព័ន្ធអនឡាញ

នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យាបានបង្ហាញពីការដាក់ពាក្យបណ្តឹងតាមរយៈអនឡាញ (Online) ក្នុងករណីត្រូវបានទទួលរងការបោកបញ្ឆោតតាមរយៈអនឡាញ (Online) ឬទូរសព្ទ (ការលួចយកគណនីបណ្តាញសង្គម ដើម្បីយកទៅធ្វើការបោកប្រាស់ ការបោកបញ្ឆោតតាមរយៈការផ្ទេរលុយ) ឬបទល្មើសបច្ចេកវិទ្យាផ្សេងៗទៀតនោះ អាចដាក់ពាក្យបណ្តឹងតាមវិធីដូចខាងក្រោម៖

១.ដាក់ពាក្យបណ្តឹងតាមប្រព័ន្ធអនឡាញ (Online) ដោយធ្វើការទាញយកពាក្យគំរូនៃបណ្តឹងតាមរយៈតំណភ្ជាប់ (https://bit.ly/ACCPKH) ដើម្បីធ្វើការបំពេញពាក្យបណ្តឹង ឬសេចក្តីរាយការណ៍។

២.ភ្ជាប់មកនូវជាមួយអត្តសញ្ញាណប័ណ្ណ ឬសំបុត្រកំណើត ឬលិខិតឆ្លងដែន ព្រមទាំងថតរូបផ្ទាល់ជាមួយឯកសារណាមួយ

៣.សូមភ្ជាប់មកនូវរូបភាព Screenshot នៃការបោកបញ្ឆោត។[១៣១]

បន្ទាប់ពីបានប្រមូលឯកសារទាំងបី អាចផ្ញើមកនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យាតាមរយៈ Messenger ឬដោយផ្ញើមកតាមរយៈ Email : accd.police@cyber.police.gov.kh របស់នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា។[១៣២]

---

[១៣០] https://www.youtube.com/watch?v=៩fumHrPmGIY (ចូលទស្សនានៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤)។

[១៣១] https://www.youtube.com/watch?v=VNrjhb២wGAQ&t=៥៩s (ចូលទស្សនានៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤)។

[១៣២] https://www.youtube.com/watch?v=VNrjhb២wGAQ&t=៥៩s (ចូលទស្សនានៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤)។

# ជំពូកទី៣
# ផលប៉ះពាល់ ការទប់ស្កាត់ និងវិធានការ
# ចំពោះបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា

# ជំពូកទី៣
# ផលប៉ះពាល់ ការទប់ស្កាត់ និងវិធានការ ចំពោះបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា

ការកើតឡើងនូវបទល្មើសក្នុងវិស័យព័ត៌មានវិទ្យា ឬបទល្មើសដែលកើតឡើងដោយការប្រើប្រាស់បច្ចេកវិទ្យា ឬប្រព័ន្ធបច្ចេកវិទ្យា ធ្វើជាមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើសដែលជាផ្នែកមួយនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យា នៅតែបន្តកើតឡើងមកទល់ពេលបច្ចុប្បន្ននេះ ក្រោមរូបភាពថ្មីៗ និងមានលក្ខណៈទ្រង់ទ្រាយដ៏ធំប្លែកៗជាច្រើន គ្រប់ទម្រង់ដែលនេះជាកត្តាមួយដែលបង្កឱ្យមានផលប៉ះពាល់ជាច្រើនដល់សណ្តាប់ធ្នាប់សាធារណៈ ក៏ដូចជាបង្កនូវភាពអសន្តិសុខក្នុងប្រទេសជាតិផងដែរ។ ដោយឡែករាជរដ្ឋាភិបាលបានខិតខំយ៉ាងខ្លាំងក្នុងការទប់ស្កាត់ និងបានដាក់ចេញនូវវិធានការមួយចំនួនក្នុងការប្រយុទ្ធប្រឆាំងនឹងបទល្មើសក្នុងវិស័យព័ត៌មានវិទ្យា។

ដូចនេះដើម្បីសិក្សាឱ្យយល់កាន់តែច្បាស់អំពីផលប៉ះពាល់ ក៏ដូចជាការទប់ស្កាត់ចំពោះបទល្មើស និងវិធានការចំពោះបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា ក្នុងផ្នែកនេះយើងនឹងធ្វើការសម្រាយចេញជាបីគឺ **ផលប៉ះពាល់នៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា** (៣.១) **ការទប់ស្កាត់ចំពោះបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា** (៣.២) និង**ការដាក់ចេញនូវវិធានការរបស់រាជរដ្ឋាភិបាលកម្ពុជា** (៣.៣) នឹងធ្វើការសម្រាយបញ្ជាក់ដូចតទៅ។

## ៣.១ ផលប៉ះពាល់នៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា

យើងឃើញថា បទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជាបានបង្កឱ្យមានផលប៉ះពាល់ជាច្រើន ជាពិសេសនោះគឺបង្កឱ្យមានផលប៉ះពាល់ដល់សិទ្ធិឯកជនភាព ដែលនេះជាផលប៉ះពាល់មួយដែលចម្បងនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យា ដោយឡែកនោះយើងសង្កេតឃើញថា បានបង្កឱ្យមានផលប៉ះពាល់មួយចំនួនទៀតគឺផលប៉ះពាល់ចំពោះបុគ្គលផ្ទាល់ និងការប្រើប្រាស់សម្រាប់ជីវភាពប្រចាំថ្ងៃ និងផលប៉ះពាល់ចំពោះសន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈផងដែរ ដូចនេះដើម្បីឱ្យយល់កាន់តែច្បាស់អំពីផលប៉ះពាល់ក្នុងផ្នែកនេះយើងនឹងធ្វើការសម្រាយបញ្ជាក់ដូចតទៅ។

### ៣.១.១ ផលប៉ះពាល់ចំពោះបុគ្គលផ្ទាល់ និងការប្រើប្រាស់ជីវភាពប្រចាំថ្ងៃ

យើងឃើញថាមាន បទល្មើសដែលកើតឡើងដោយតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាជាមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើស បានបន្តកើតឡើងជាច្រើន និងក្រោមរូបភាពថ្មីៗក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា កត្តា

ទាំងនេះហើយដែលជាកត្តាមួយបង្កឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះបុគ្គលផ្ទាល់ និងការប្រើប្រាស់សម្រាប់ជីវភាពប្រចាំថ្ងៃ ដោយក្នុងនោះរួមមានដូចតទៅ៖

- **ឯកជនភាព**៖ ជាស្ថានភាពមួយដែលមានលក្ខណៈធ្ងន់ធ្ងរព្រោះប៉ះពាល់ដល់សិទ្ធិឯកជនភាព។
- **ការបាត់បង់ផ្នែកហិរញ្ញវត្ថុ**៖ ផលប៉ះពាល់ទូទៅដែលបង្កឱ្យបុគ្គលត្រូវបានបាត់បង់ផ្នែកហិរញ្ញវត្ថុ។ ជនល្មើសតែងតែប្រើវិធីសាស្ត្រផ្សេងៗដូចជាការបន្លំ ការលួចចូល និងរូបភាពផ្សេងទៀត ដើម្បីទទួលបានព័ត៌មានហិរញ្ញវត្ថុរបស់បុគ្គលម្នាក់ៗ ដូចជាលេខកាតឥណទាន ព័ត៌មានលម្អិតគណនីធនាគារ និងពាក្យសម្ងាត់។ នេះអាចបណ្តាលឱ្យបាត់បង់ប្រាក់តាមរយៈប្រតិបត្តិការដែលគ្មានការអនុញ្ញាត។[១៣៣]
- **ការលួចអត្តសញ្ញាណ**៖ ការលួចអត្តសញ្ញាណគឺជាផលវិបាកដ៏សំខាន់មួយទៀត ដែលបង្កឱ្យបុគ្គលងាយរងគ្រោះ។ ជនល្មើសអាចប្រើប្រាស់ព័ត៌មានដែលខ្លួនបានលួចយកដោយគ្មានអនុញ្ញាត ដូចជាលេខអត្តសញ្ញាណប័ណ្ណ លេខកុងធនាគារ និងផ្សេងទៀត ដើម្បីបើកគណនីថ្មី ដកប្រាក់កម្ចី និងប្រព្រឹត្តការក្លែងបន្លំប្រភេទផ្សេងៗទៀត។ នេះអាចបណ្តាលឱ្យមានការខាតបង់ផ្នែកហិរញ្ញវត្ថុមួយផ្នែក និងធ្វើឱ្យមានភាពស្មុគស្មាញលើផ្នែកច្បាប់ផងដែរ។[១៣៤]
- **ផលប៉ះពាល់ដល់ផ្នែកផ្លូវចិត្ត**៖ បន្ថែមពីលើការបាត់បង់ហិរញ្ញវត្ថុ និងការលួចយកអត្តសញ្ញាណ ជនល្មើសអាចបង្កឱ្យជនរងគ្រោះមានផលប៉ះពាល់ដល់ផ្លូវចិត្តផងដែរ។ ជនដែលរងគ្រោះអាចមានអារម្មណ៍ថាមានការបំពានសិទ្ធិឯកជន និងរំលោភលើសិទ្ធិឯកជនភាព ដែលនាំឱ្យមានការភ័យខ្លាច និងមានការព្រួយបារម្ភ។[១៣៥]
- **ការបាត់បង់កេរ្តិ៍ឈ្មោះ**៖ ជនល្មើសអាចបង្កការខូចខាតដល់ផ្នែកកេរ្តិ៍ឈ្មោះបុគ្គលផងដែរ។ ជនល្មើសអាចប្រើព័ត៌មានដែលលួចដើម្បីបង្ហោះខ្លឹមសារអាម៉ាស់ ឬបំផ្លាញខ្លឹមសារលើប្រព័ន្ធអនឡាញ ដែលនាំឱ្យបាត់បង់ភាពជឿជាក់ និងទំនុកចិត្តដល់បុគ្គលដែលត្រូវបានរងគ្រោះ។ ផលប៉ះពាល់នៃការខូចខាតកេរ្តិ៍ឈ្មោះអាចជាការខូចខាតធ្ងន់ធ្ងរ ជាពិសេសនៅក្នុងការបំពេញវិជ្ជាជីវៈ ដែលនាំឱ្យមានការបាត់បង់ការងារ ឬពិបាកក្នុងការស្វែងរកការងារធ្វើផងដែរ។[១៣៦]

---

[១៣៣] https://tinyurl.com/pvkh៥ery (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[១៣៤] https://tinyurl.com/pvkh៥ery (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[១៣៥] https://tinyurl.com/pvkh៥ery (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[១៣៦] https://tinyurl.com/pvkh៥ery (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

### ៣.១.២ ផលប៉ះពាល់ចំពោះសង្គមជាតិ

បទល្មើសក្នុងវិស័យព័ត៌មានវិទ្យា បានបង្កឱ្យមានផលប៉ះពាល់ជាច្រើនដល់ផ្នែកសន្តិសុខ និង សណ្តាប់ធ្នាប់សាធារណៈផងដែរក្នុងនោះមានដូចជា៖

- បានបង្កឱ្យមានជាបទល្មើសជាច្រើនក្នុងសង្គម តាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាជាមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើស ក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា។
- បានបង្កឱ្យមានភាពអសន្តិសុខក្នុងសង្គម និងសណ្តាប់ធ្នាប់សាធារណៈនៅកម្ពុជា។
- បានធ្វើឱ្យបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជាមានលក្ខណៈស្មុគស្មាញក្នុងការដោះស្រាយ ក៏ដូចជាពិបាកក្នុងការទប់ស្កាត់។
- និងបានធ្វើឱ្យបទល្មើសក្នុងវិស័យព័ត៌មានវិទ្យាមានការវិវត្តក្រោមរូបភាពថ្មីៗ ដែលជាហេតុបង្កឱ្យមានភាពអសន្តិសុខក្នុងសង្គម និងសណ្តាប់ធ្នាប់សាធារណៈផងដែរ។ល។

## ៣.២ ការទប់ស្កាត់ចំពោះបទល្មើសក្នុងវិស័យព័ត៌មានវិទ្យា

ការទប់ស្កាត់ចំពោះបទល្មើសក្នុងវិស័យព័ត៌មានវិទ្យា ដើម្បីការពារខ្លួនពីបទល្មើសក្នុងវិស័យព័ត៌មានវិទ្យា ក៏ដូចជាស្វែងយល់អំពីហានិភ័យនានានៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យា ត្រូវមានការចូលរួមពីកត្តាពីរយ៉ាង ក្នុងនោះមានដូចជា**បុគ្គលដែលប្រើប្រាស់ដោយផ្ទាល់** (៣.២.១) និង**ក្រសួងនិងស្ថាប័នដែលមានសមត្ថកិច្ច** (៣.២.២)។

### ៣.២.១ បុគ្គលដែលប្រើប្រាស់ផ្ទាល់

ចំពោះបុគ្គលដែលប្រើប្រាស់ដោយផ្ទាល់ ចំពោះការទប់ស្កាត់ដើម្បីការពារខ្លួនពីបទល្មើសក្នុងវិស័យព័ត៌មានវិទ្យា ឬបទល្មើសដែលកើតឡើងតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាជាមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើស បុគ្គលដែលប្រើប្រាស់ដោយផ្ទាល់ត្រូវមានការប្រុងប្រយ័ត្ន និងស្វែងយល់អំពីហានិភ័យនានានៃបច្ចេកវិទ្យា និងគួរផ្តើមពីវិធីសាស្ត្រក្នុងការទប់ស្កាត់ដូចខាងក្រោមរួមមាន៖

- ធ្វើការអាន ស្តាប់ ទស្សនាវីដេអូ សិក្សា ស្វែងយល់ លើអត្ថបទកាសែត អត្ថបទអប់រំ វីដេអូអប់រំ ព័ត៌មានពាក់ព័ន្ធផ្សេងៗ។
- បន្តផ្សព្វផ្សាយអប់រំ ចែករំលែកជូនដល់សាច់ញាតិ បងប្អូន មិត្តភក្តិ ព្រមទាំងចូលរួមធ្វើសេចក្តីរាយការណ៍ជូនសមត្ថកិច្ចពាក់ព័ន្ធ ក្នុងករណីជួបប្រទះ ឬសង្ស័យថាជាបទល្មើសបច្ចេកវិទ្យា។
- មានការប្រើប្រាស់បណ្តាញសង្គមឱ្យបានត្រឹមត្រូវ។
- ការត្រួតពិនិត្យលក្ខណៈឧបករណ៍បច្ចេកវិទ្យាព័ត៌មានជាប្រចាំ។

- កំណត់លេខសម្ងាត់នៅលើឧបករណ៍ឱ្យបានរឹងមាំ។
- ធ្វើបច្ចុប្បន្នភាពនៃកម្មវិធី ឬទិន្នន័យ និងប្រព័ន្ធប្រតិបត្តិការការរក្សាកម្មវិធីរបស់អ្នកឱ្យមានទំនើបកម្ម។
- ប្រើកម្មវិធីប្រយុទ្ធប្រឆាំងនឹងមេរោគ។
- ប្រើពាក្យសម្ងាត់ឱ្យមានលក្ខណៈរឹងមាំ។
- ជៀសវាងការប្រើបណ្ដាញ Wi-Fi សាធារណៈ និងបណ្ដាញឯកជននិម្មិត (VPN)។
- កុំបើកឯកសារភ្ជាប់ក្នុងអ៊ីមែលឥតបានការ ដែលធ្វើឱ្យឆ្លងមេរោគ បាត់បង់ទិន្នន័យ ដោយការវាយប្រហារដោយមេរោគ។
- កុំចុចលើតំណភ្ជាប់ក្នុងអ៊ីម៉ែល SPAM ឬគេហទំព័រដែលមិនគួរឱ្យទុកចិត្ត។
- និងតាមដានរបាយការណ៍ធនាគាររបស់អ្នក គឺជាការសម្គាល់ថាអ្នកបានក្លាយជាជនរងគ្រោះនៃបទល្មើសបច្ចេកវិទ្យាយ៉ាងឆាប់រហ័សគឺជារឿងសំខាន់។[១៣៧]

### ៣.២.២ ក្រសួង និងស្ថាប័នដែលមានសមត្ថកិច្ច

ដោយឡែក ក្រសួង និងស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការប្រយុទ្ធប្រឆាំងនឹងបទល្មើសក្នុងវិស័យព័ត៌មានវិទ្យា ដោយក្រសួង និងស្ថាប័នដែលពាក់ព័ន្ធបានចូលរួមទប់ស្កាត់ដូចជា៖

- សិក្សារៀបចំគោលការណ៍ វិធានការ យុទ្ធសាស្ត្រ និងផែនការសកម្មភាពលើការបង្ការ ទប់ស្កាត់ ស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបបទល្មើសបច្ចេកវិទ្យា។
- ផ្សព្វផ្សាយ និងបញ្ជ្រាបចំណេះដឹងអំពីវិធានការក្នុងការទប់ស្កាត់ ការការពារ និងបង្ក្រាបចំពោះបទល្មើសបច្ចេកវិទ្យា។
- បណ្ដុះបណ្ដាល និងបង្កើនសមត្ថភាពមន្ត្រីជំនាញឱ្យមានបច្ចេកទេសខ្ពស់ក្នុងការការពារ ទប់ស្កាត់ បង្ក្រាប និងប្រយុទ្ធប្រឆាំងនឹងបទល្មើសបច្ចេកវិទ្យា។[១៣៨]
- ត្រូវមានកិច្ចសហការ និងកិច្ចសហប្រតិបត្តិការ គ្រប់បណ្ដាក្រសួង និងស្ថាប័នដែលពាក់ព័ន្ធជាពិសេសនោះដូចជា ក្រសួងយុត្តិធម៌ ក្រសួងសាធារណការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងពាណិជ្ជកម្ម និងបណ្ដាក្រសួង ស្ថាប័ន ឬគ្រឹះស្ថានពាក់ព័ន្ធផ្សេងៗទៀត។

---

[១៣៧] What is Cybercrime? How to protect yourself, 'Google', https://www.kaspersky.com/resource-center/threats/what-is-cybercrime (ចូលទស្សនានៅថ្ងៃទី១៥ មីនា ២០២៤)។

[១៣៨] https://www.youtube.com/watch?v=oG8sCfF-DNKk&list=PPSV (ចូលទស្សនានៅថ្ងៃទី២៩ សីហា ២០២៤)។

- ត្រូវមានកិច្ចសហការ និងកិច្ចសហប្រតិបត្តិការឱ្យបានល្អជាមួយស្ថាប័ន ជាពិសេសខាងធនាគារ ក្រុមហ៊ុនទូរសព្ទជាដើម ដើម្បីសហការក្នុងការផ្ដល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក និងទាន់ហេតុការណ៍ជូនប្រជាពលរដ្ឋ។[១៣៩]
- ត្រូវមានកិច្ចសហការ និងកិច្ចសហប្រតិបត្តិការ ជាមួយ ជាតិ អាស៊ាន និងអន្តរជាតិក្នុងការការទប់ស្កាត់ ការការពារ បង្ក្រាប និងប្រយុទ្ធប្រឆាំងចំពោះបទល្មើសបច្ចេកវិទ្យា។[១៤០]

## ៣.៣ ការដាក់ចេញនូវវិធានការរបស់រាជរដ្ឋាភិបាលកម្ពុជា

ដោយឡែករាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវវិធានការធំៗចំនួនបីដែលមានគោលបំណងក្នុងការការពារ ការទប់ស្កាត់ ការបង្ក្រាប និងការប្រយុទ្ធប្រឆាំងចំពោះបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជាស្របពេលដែលបច្ចុប្បន្នភាព កំពុងមានការកកើតឡើងនូវបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជាផងដែរ។ ដោយក្នុងនោះគឺមានវិធានការធំៗដូចជា**ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥**[១៤១] (៣.៣.១) **គោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២២-២០២៥**[១៤២] (៣.៣.២) និងចុងក្រោយ**យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា**[១៤៣] (៣.៣.៣)។

### ៣.៣.១ ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥

ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ បានដាក់ចេញនូវចក្ខុវិស័យវែងឆ្ងាយ ក្នុងការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលរស់រវើក តាមរយៈការរៀបចំមូលដ្ឋានគ្រឹះជំរុញការទទួលយក និងការធ្វើបរិវត្តកម្មឌីជីថល ដោយផ្អែកលើគន្លង "**ប្រក្រតីភាពថ្មី**"។ បន្ថែមពីការរៀបចំមូលដ្ឋានគ្រឹះ ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ បានកសាងទំនុកចិត្ត និងភាពជឿជាក់លើប្រព័ន្ធឌីជីថល ដែលជាគន្លឹះដ៏សំខាន់ សម្រាប់ការអភិវឌ្ឍ និងកសាងសេដ្ឋកិច្ច និងសង្គមឌីជីថល តាមរយៈការកសាងក្របខណ្ឌច្បាប់ និងសន្តិសុខសាយប័រ ត្រូវបានគិតគូរដោយឈរលើគោលការណ៍ចំនួនពីររួមមាន៖

---

[១៣៩] https://www.youtube.com/watch?v=oGsCfF-DNKk&list=PPSV (ចូលទស្សនានៅថ្ងៃទី២៩ សីហា ២០២៤)។

[១៤០] https://www.youtube.com/watch?v=oGsCfF-DNKk&list=PPSV (ចូលទស្សនានៅថ្ងៃទី២៩ សីហា ២០២៤)។

[១៤១] ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, *ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥*, (ភ្នំពេញ៖ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, ២០២១)។

[១៤២] ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, *គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥*, (ភ្នំពេញ៖ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ២០២២)។

[១៤៣] រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៧ នៃរដ្ឋសភា, *យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៧ នៃរដ្ឋសភា*, (ភ្នំពេញ៖ រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៧ នៃរដ្ឋសភា, ២០២៣)។

- ការរៀបចំក្របខណ្ឌច្បាប់
- និងការពង្រឹងការគ្រប់គ្រងសន្តិសុខសាយប័រ។

**វិធានការគោលនយោបាយផ្នែកក្របខណ្ឌច្បាប់**

- កសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដែលនៅសេសសល់ ជាអាទិ៍ ដែលរួមមាន ច្បាប់ស្តីពីការការពារទិន្នន័យ និងឯកជនភាព ច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន។ល។[១៤៤]
- ធ្វើវិសោធនកម្ម ឬកែសម្រួល បន្តរៀបចំ និងអនុវត្តនូវច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យសន្តិសុខសាយប័រ ដើម្បីឆ្លើយតបទៅនឹងបរិការណ៍ថ្មី និងស្ថានភាពជាក់ស្តែង។ល។

**វិធានការគោលនយោបាយផ្នែកសន្តិសុខសាយប័រ**

- បន្តកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងរៀបចំគោលនយោបាយ ឬយុទ្ធសាស្ត្រស្តីពីសន្តិសុខសាយប័រ។
- រៀបចំយុទ្ធសាស្ត្រ និងគោលការណ៍ណែនាំ ដើម្បីលើកកម្ពស់ការយល់ដឹងពីបញ្ហាសន្តិសុខសាយប័រតាមកម្រិត។ល។[១៤៥]

### ៣.៣.២ គោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២២-២០៣៥

រាជរដ្ឋាភិបាលបានដាក់ចេញនូវ គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ ដោយផ្តោតលើចក្ខុវិស័យ **ការកសាងរដ្ឋាភិបាលឌីជីថលដើម្បីលើកកម្ពស់គុណភាពជីវិត និងទំនុកចិត្តប្រជាពលរដ្ឋ តាមរយៈការបម្រើសេវាសាធារណៈឱ្យកាន់តែល្អប្រសើរ** ដោយក្នុងនោះរាជរដ្ឋាភិបាលបាននឹងកំពុងរៀបចំ **សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន** ក្នុងគោលដៅបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសបច្ចេកវិទ្យាព័ត៌មាន ដើម្បីកំណត់គោលការណ៍ និងយន្តការក្នុងការបង្ក្រាប គ្រប់គ្រង និងឆ្លើយតបចំពោះការគំរាមកំហែងសន្តិសុខឌីជីថល ក្នុងគោលបំណងធានាដល់សាធារណៈជនគ្រប់រូបនូវសិទ្ធិសេរីភាពក្នុងការទទួលបានព័ត៌មានពីស្ថាប័នសាធារណៈ ស្របតាមស្មារតីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។[១៤៦]

---

[១៤៤] ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, *ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥*, (ភ្នំពេញ៖ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, ២០២១), ៣៦។

[១៤៥] ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, *ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥*, (ភ្នំពេញ៖ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, ២០២១), ៣៧។

[១៤៦] រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៧ នៃរដ្ឋសភា, *យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៧ នៃរដ្ឋសភា*, (ភ្នំពេញ៖ រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៧ នៃរដ្ឋសភា, ២០២៣), ៩។

### ៣.៣.៣ យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា

សម្រាប់យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា ស្របតាមចលនាការណ៍នៃការធ្វើបរិវត្តកម្មឌីជីថល អាទិភាព **"បច្ចេកវិទ្យា"** ត្រូវបានផ្តោតជាសំខាន់ក្នុងបញ្ចកោណទី ៥ ជាពិសេស ក្នុងការកសាង និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដែលមាននៅក្នុងមុំទី ៣ និងមានភាពប្រទាក់ក្រឡាយ៉ាងស្អិតរមួត ក្នុងគ្រប់មុំនៃបញ្ចកោណទាំងបួនផ្សេងទៀត។[១៤៧] **បញ្ចកោណទី៥ ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល** រាជរដ្ឋាភិបាល បានចាត់ទុកបច្ចេកវិទ្យាឌីជីថលជាកាតាលីករថ្មីដ៏មានសារៈសំខាន់ ដែលមានសក្តានុពល និងកាលានុវត្តភាព ក្នុងការជំរុញកំណើនផលិតភាពសេដ្ឋកិច្ច និងសង្គម ក្នុងទិសដៅនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវក្របខណ្ឌ**គោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥** និង**គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥** ក្នុងន័យនេះ រាជរដ្ឋាភិបាលផ្តោតលើអាទិភាពចំនួន ៥ រួមមាន៖ (១).ការកសាងរដ្ឋាភិបាលឌីជីថល និងពលរដ្ឋឌីជីថល (២).ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ធុរកិច្ចឌីជីថល ពាណិជ្ជកម្មតាមប្រព័ន្ធអាឡិចត្រូនិក និងប្រព័ន្ធនវានុវត្តឌីជីថល (៣).ការកសាង និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល (៤).ការកសាងភាពជឿទុកចិត្តលើប្រព័ន្ធឌីជីថល និង (៥).ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុផងដែរ។[១៤៨] សម្រាប់យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ នីតិកាលទី៧ នៃរដ្ឋសភា គោលដៅជាយុទ្ធសាស្ត្រ គឺការបន្តការពារឱ្យបានជាដាច់ខាត នូវសន្តិភាព, ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ដែលកត្តាទាំងនេះ ជាបុរេលក្ខខណ្ឌមិនអាចខ្វះបាន សម្រាប់ក្នុងការអភិវឌ្ឍប្រទេសជាតិ។ ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ **ការពង្រឹង ការអនុវត្តច្បាប់ និងការកសាងសមត្ថភាព ដើម្បីទប់ស្កាត់បទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា ប្រកបដោយប្រសិទ្ធភាពខ្ពស់**។ល។[១៤៩] ការកសាងភាពជឿទុកចិត្តលើប្រព័ន្ធឌីជីថល ក្នុងគោលដៅជាយុទ្ធសាស្ត្រ គឺការកសាងភាពទុកចិត្តលើប្រព័ន្ធឌីជីថល និងការលើកកម្ពស់ការយល់ដឹងអំពីសន្តិសុខឌីជីថលដើម្បីជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ឱ្យបានទូលំទូលាយ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា រាជរដ្ឋាភិបាលផ្តោតលើអាទិភាពលើរួមមាន៖

---

[១៤៧] រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៧ នៃរដ្ឋសភា, *យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៧ នៃរដ្ឋសភា*, (ភ្នំពេញ៖ រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៧ នៃរដ្ឋសភា, ២០២៣), ៣២។

[១៤៨] រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៧ នៃរដ្ឋសភា, *យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៧ នៃរដ្ឋសភា*, (ភ្នំពេញ៖ រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៧ នៃរដ្ឋសភា, ២០២៣), ៨៤។

[១៤៩] រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៧ នៃរដ្ឋសភា, *យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៧ នៃរដ្ឋសភា*, (ភ្នំពេញ៖ រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៧ នៃរដ្ឋសភា, ២០២៣), ៤៥។

ទី១-ការបន្តកសាង និងពន្លឿន ការរៀបចំ និងការអនុម័តសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធ។

ទី២-ការបង្កើតគណៈកម្មាធិការសន្តិសុខឌីជីថល និងមជ្ឈមណ្ឌលសន្តិសុខឌីជីថលជាតិ និងការបង្កើន ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធសន្តិសុខឌីជីថល។

ទី៣-ការរៀបចំវិធានការអនុវត្ត ឬវិធានប្រតិបត្តិ ,ស្តង់ដារ ,ក្របខណ្ឌបច្ចេកទេស ,គោលការណ៍ណែនាំ ក្រុមប្រតិបត្តិ និងនីតិវិធីនៃការឆ្លើយតបដើម្បីជាមូលដ្ឋាន សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធ សន្តិសុខឌីជីថល។

ទី៤-ការរៀបចំក្របខណ្ឌវាយតម្លៃឡើងវិញនូវចន្លោះប្រហោង និងពង្រឹងប្រព័ន្ធសន្តិសុខឌីជីថល សម្រាប់ហេដ្ឋារចនាសម្ព័ន្ធចាំបាច់។

ទី៥-ការបណ្តុះបណ្តាល និងការបង្កើនការអភិវឌ្ឍ ជំនាញសន្តិសុខឌីជីថល និងការលើកកម្ពស់ ការយល់ដឹងអំពីបញ្ហាសន្តិសុខឌីជីថល ដើម្បីបញ្ជ្រាបការយល់ដឹងជាសាធារណៈ អំពីបញ្ហាសន្តិសុខឌីជីថល និងកិច្ចការពារខ្លួន និង**ការប្រយុទ្ធប្រឆាំងបទល្មើសបច្ចេកវិទ្យាព័ត៌មាន។**

ទី៦-ការបង្កើតយន្តការនៃកិច្ចសហការ និងកិច្ចសហប្រតិបត្តិការជាមួយនឹងស្ថាប័នពាក់ព័ន្ធ ទាំងរដ្ឋ វិស័យឯកជន និងប្រជាជន ដើម្បីចូលរួមរាយការណ៍ ទប់ស្កាត់ បំពាក់សុវត្ថិភាពក្នុងប្រព័ន្ធឌីជីថល និង ឈានឆ្ពោះទៅដល់ការបង្ក្រាបទាន់ពេលនូវបទល្មើសបច្ចេកវិទ្យាព័ត៌មាន។

ទី៧-ការបង្កើតក្របខណ្ឌកិច្ចសហប្រតិបត្តិការ ទាំងក្នុងតំបន់ និងជាសកល ក្នុងការចែករំលែកព័ត៌មាន និងការគ្រប់គ្រងហានិភ័យពាក់ព័ន្ធនឹងសន្តិសុខឌីជីថល ក្នុងបរិការណ៍តំបន់ និងសកល។[៥០]

---

[៥០] រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៧ នៃរដ្ឋសភា, *យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៧ នៃរដ្ឋសភា*, (ភ្នំពេញ៖ រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៧ នៃរដ្ឋសភា, ២០២៣), ៩៤។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងកាត់តាមការបកស្រាយ ក៏ដូចជាតាមរយៈការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីអំពី **បច្ចុប្បន្នភាពនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា** រួចមកយើងធ្វើការសង្កេតឃើញថា បទល្មើសក្នុងវិស័យព័ត៌មានវិទ្យា គឺជាប្រភេទបទល្មើសមួយប្រភេទដែលមិនបង្ករបួសស្នាមខាងក្រៅទេ ផ្ទុយមកវិញបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានេះបានបង្កព្យសនកម្មយ៉ាងធ្ងន់ធ្ងរទៅដល់សិទ្ធិឯកជនភាពយ៉ាងខ្លាំង និងបង្កផលប៉ះពាល់យ៉ាងខ្លាំងដល់សង្គមជាតិផងដែរ។

បទល្មើសក្នុងវិស័យព័ត៌មានវិទ្យាដែលបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចាប់ពីមាត្រា៤២៧ ដល់មាត្រា៤៣២ ជាប្រភេទបទល្មើសមួយប្រភេទដែលមានស្ថានភាពនៃបទល្មើសខុសពីបទល្មើសផ្សេងៗ ដោយហេតុតែបទល្មើសនេះ មានការប៉ះពាល់ទៅដល់ប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ ហើយការប៉ះពាល់បែបនេះជាកម្មវត្ថុនៃបទល្មើសដែលបានបង្កជាឧបសគ្គដល់ដំណើរការបច្ចេកទេសក្នុងវិស័យព័ត៌មានវិទ្យា។ បន្ថែមពីនេះ ក៏មានអំពើថ្មីៗដែលជាផ្នែកនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា គឺបទល្មើសបច្ចេកវិទ្យា បានលេចឡើងក្រោមរូបភាពជាច្រើនដូចជា ព័ត៌មានមិនពិត, អំពើឆបោកដោយប្រើប្រាស់បច្ចេកវិទ្យា, ការបរិហារកេរ្តិ៍លើបណ្តាញផ្សព្វផ្សាយសង្គម ជាអាទិ៍។ បើទោះបីជាប្រទេសកម្ពុជាបច្ចុប្បន្ននេះពុំទាន់មានក្របខណ្ឌច្បាប់ពិសេសជាក់លាក់នៅឡើយ ទាំងច្បាប់ពិសេស និងច្បាប់នីតិវិធីដែលពាក់ព័ន្ធនឹងបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជាក្តី ក៏ប្រទេសកម្ពុជាមានលិខិតបទដ្ឋានគតិយុត្តសមល្មមនឹងដាក់ទោសជនប្រព្រឹត្តបទល្មើសបច្ចេកវិទ្យាបានដែរ។ លើសពីនេះ កម្ពុជាបានព្យាយាមខិតខំប្រឹងប្រែងដោះស្រាយរាល់បញ្ហាទាំងអស់ ដោយស្ថាប័នជំនាញបានធ្វើការការពារ ទប់ស្កាត់ ផ្សព្វផ្សាយ បង្ការ បង្ក្រាប និងជាពិសេសតាក់តែងនូវលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងបទល្មើសក្នុងវិស័យព័ត៌មានវិទ្យាផងដែរ។ ដោយថ្មីៗនេះ ស្ថាប័នដែលមានសមត្ថកិច្ចលើបញ្ហានេះបានធ្វើការពិគ្រោះយោបល់អំពីសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន ដើម្បីធ្វើការប្រយុទ្ធប្រឆាំងបទល្មើសបច្ចេកវិទ្យាព័ត៌មាន។ គួរបញ្ជាក់ផងដែរថាច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន គឺមាន៩ជំពូកនិង៥៥មាត្រា ដែលមានគោលបំណង ធានាសុចរិតភាពនៃការប្រើប្រាស់ ការគ្រប់គ្រងប្រព័ន្ធកុំព្យូទ័រ ទិន្នន័យកុំព្យូទ័រ និងការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងការពារសិទ្ធិសេរីភាពរបស់បុគ្គល ដោយកំណត់អំពីវិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាប បទល្មើសបច្ចេកវិទ្យាព័ត៌មាន ច្បាប់នេះមានវិសាលភាពអនុវត្តរាល់សកម្មភាពទាំងអស់ដែលពាក់ព័ន្ធនឹងបទល្មើសបច្ចេកវិទ្យាព័ត៌មានដែលប្រព្រឹត្តនៅក្នុង ឬនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ស្របពេលគ្នានេះដែររាជរដ្ឋាភិបាលកម្ពុជាក៏បានដាក់ចេញវិធានការចំនួនបីដែលមានគោលបំណងក្នុងការការការពារ ការទប់ស្កាត់ ការបង្ក្រាប និងការប្រយុទ្ធប្រឆាំងចំពោះបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា។ ស្របពេលដែលបច្ចុប្បន្ន

កំពុងមានការកកើតឡើងនូវបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជាផងដែរដោយ ក្នុងនោះគឺមានវិធានការធំៗដូចជាក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥, គោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២២-២០២៥, និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា។

សរុបសេចក្ដីមក បទល្មើសក្នុងវិស័យព័ត៌មានវិទ្យា ឬការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាជាមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើស ពិតជាបានបង្កព្យសនកម្មយ៉ាងធ្ងន់ធ្ងរទៅដល់សិទ្ធិឯកជនភាព និងបង្កផលប៉ះពាល់យ៉ាងខ្លាំងដល់សង្គមជាតិ។ ដូច្នេះ ដើម្បីចូលរួមទប់ស្កាត់ ការពារ និងប្រយុទ្ធប្រឆាំងបទល្មើសប្រភេទនេះត្រូវតែមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាផ្ទាល់ ក្រសួងឬស្ថាប័នគ្រប់លំដាប់ជាន់ថ្នាក់ និងរាជរដ្ឋាភិបាលផងដែរ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានសិក្សា និងធ្វើការស្រាវជ្រាវទៅលើប្រធានបទ **បច្ចុប្បន្នភាពនៃបទល្មើសក្នុងវិស័យព័ត៌មានវិទ្យានៅកម្ពុជា** រួចមក ក្រុមយើងខ្ញុំយល់ឃើញថា បទល្មើសក្នុងវិស័យព័ត៌មានវិទ្យា ឬការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាជាមធ្យោយបាយក្នុងការប្រព្រឹត្តបទល្មើស បានកើតឡើងជាច្រើន ក្រោមរូបភាពថ្មីៗ ជាពិសេសមានការវិវត្តថ្មីៗប្លែកៗជានិច្ច។ ទន្ទឹមនឹងនេះ សម័យកាលកាន់តែជឿនលឿន បច្ចេកវិទ្យាក៏មានភាពរីកចម្រើន ការកើតមានឡើងនូវបទល្មើសក៏ថ្មីផងដែរ ជាពិសេសនោះគឺការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាជាមធ្យោបាយនៅក្នុងការប្រព្រឹត្តបទល្មើស។ ថ្វីត្បិតតែបទល្មើសប្រភេទនេះមិនបានបង្កឱ្យមានរបួសស្នាមខាងក្រៅក៏ពិតមែន ប៉ុន្តែវាបានបង្កឱ្យមានព្យសនកម្មយ៉ាងធ្ងន់ធ្ងរទៅដល់សិទ្ធិឯកជនភាព សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសង្គមជាតិ។

ហេតុដូចនេះ ដោយសារតែមើលឃើញពីបញ្ហា និងផលប៉ះពាល់ដែលបានបង្កមកពីបទល្មើសក្នុងវិស័យព័ត៌មានវិទ្យា ឬការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាជាមធ្យោយបាយក្នុងការប្រព្រឹត្តបទល្មើស យើងខ្ញុំទាំងពីរនាក់សូមគោរពអនុញ្ញាតលើកឡើងជូនជាមតិយោបល់មួយចំនួន ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើនេះដូចតទៅៈ

- ប្រជាពលរដ្ឋត្រូវចូលរួមអាន ស្តាប់ ទស្សនាវីដេអូ សិក្សា ស្វែងយល់ លើអត្ថបទកាសែត អត្ថបទអប់រំ វីដេអូអប់រំ ព័ត៌មានពាក់ព័ន្ធផ្សេងបន្តផ្សព្វផ្សាយអប់រំ ចែករំលែកជូនដល់សាច់ញាតិ បងប្អូន មិត្តភក្តិ ព្រមទាំងចូលរួមធ្វើសេចក្តីរាយការណ៍ជូនសមត្ថកិច្ចពាក់ព័ន្ធ ក្នុងករណីជួបប្រទះ ឬសង្ស័យថាជាបទល្មើសបច្ចេកវិទ្យាមានការប្រើប្រាស់បណ្តាញសង្គមឱ្យបានត្រឹមត្រូវ ជាពិសេសសូមប្រជាពលរដ្ឋកុំយកប្រព័ន្ធបច្ចេកវិទ្យាប្រើប្រាស់ក្នុងផ្លូវមិនល្អ ដែលជាហេតុនៃការប្រព្រឹត្តបទល្មើសក្នុងសង្គមជាតិ។
- ចំពោះមន្ត្រីដែលមានសមត្ថកិច្ចត្រូវបន្តផ្សព្វផ្សាយ និងបញ្ជ្រាបចំណេះដឹងអំពីវិធានការក្នុងការទប់ស្កាត់ ការការពារ និងបង្ក្រាបចំពោះបទល្មើសបច្ចេកវិទ្យា ជាពិសេសត្រូវបង្កើន និងអភិវឌ្ឍសមត្ថភាពរបស់ខ្លួនឱ្យមានបច្ចេកទេសខ្ពស់ក្នុងការការពារ ទប់ស្កាត់ បង្ក្រាប និងប្រយុទ្ធប្រឆាំងនឹងបទល្មើសបច្ចេកវិទ្យា។
- ក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចត្រូវបន្តកិច្ចសហការ និងកិច្ចសហប្រតិបត្តិការឱ្យបានល្អជាមួយស្ថាប័នជាតិ និងអន្តរជាតិ និងស្នើសុំឱ្យបង្កើតការិយាល័យប្រឆាំងបទល្មើសបច្ចេកវិទ្យានៅថ្នាក់ក្រោមជាតិគ្រប់បណ្តាខេត្ត ជាពិសេសសូមជម្រុញលើកទឹកចិត្តឱ្យក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចពន្លឿនការបន្តកសាង ការរៀបចំ និងការអនុម័តនូវសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតពាក់ព័ន្ធបទល្មើសបច្ចេកវិទ្យាព័ត៌មាន។

# ឯកសារយោង

# ឯកសារយោង

## ១. ឯកសារយោងជាលិខិតបទដ្ឋានគតិយុត្ត


- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។
- ច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ, ព្រះរាជក្រម នស/រកម/០១៩៦/០៨, ២៤ មករា ១៩៩៦។
- អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ, លេខ១០៩អនក្រ.បក, ១៩ សីហា ២០១៥។
- អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំនៃក្រសួងមហាផ្ទៃ, លេខ៣០៣អនក្រ.បក, ៣ តុលា ២០២៣។
- ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ.២០២១. *ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥.* ភ្នំពេញ៖ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ។
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍.២០២២. *គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥.* ភ្នំពេញ៖ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។
- រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា.២០២៣. *យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១.* ភ្នំពេញ៖ រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា។
- សេចក្តីបំភ្លឺទាក់ទងនឹងសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT), លេខ២៦៥៧បទ, ២៥ ឧសភា ២០១៥។


## ២. ឯកសារយោងជាសៀវភៅនៃនិពន្ធ


- រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត.២០២២. *នីតិព្រហ្មទណ្ឌទូទៅ.* ភ្នំពេញ៖ រោងពុម្ពជោគជ័យ។
- THOMAS J. HOLT និង ADAM M. BOSSLER. *CYBERCRIME IN PROGRESS* [ដំណើរការនៃបទល្មើសបច្ចេកវិទ្យា]. New York: Routledge, 2016។


## ៣. ឯកសារជាគេហទំព័រ


- ក្រសួងមហាផ្ទៃ https://www.interior.gov.kh/
- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ https://mptc.gov.kh/
- ក្រសួងមហាផ្ទៃ https://www.facebook.com/ministry.interior
- អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ https://www.facebook.com/DTM.MOI/photos?_rdc=1&_rdr
- នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា https://www.facebook.com/anti.cyber.crime.department?_rdc=1&_rdr

- គេហទំព័រសារព័ត៌មានFRESH NEWS https://www.freshnewsasia.com/index.php/en/?ref=1
- គេហទំព័រ https://www.linkedin.com/pulse/impact-cybercrime-individuals-businesses-society-join-welance/
- THEGCNPNEWS https://www.youtube.com/watch?v=VNrjhb2wGAQ&t=59s
- BTV NEWS https://www.youtube.com/watch?v=o8sCfF-DNKk&list=PPSV
- Blue TV Cambodia https://www.youtube.com/watch?v=9fumHrPmGIY
- គេហទំព័រ https://www.kaspersky.com/resource-center/threats/what-is-cybercrime

# បញ្ជីឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធគតិយុត្ត

ឧបសម្ព័ន្ធទី១៖ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

ឧបសម្ព័ន្ធទី២៖ ច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

ឧបសម្ព័ន្ធទី៣៖ អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

ឧបសម្ព័ន្ធទី៤៖ អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ

ឧបសម្ព័ន្ធទី៥៖ ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា២០២១-២០៣៥

ឧបសម្ព័ន្ធទី៦៖ គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥

ឧបសម្ព័ន្ធទី៧៖ យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ នីតិកាលទី ៧ នៃរដ្ឋសភា

ឧបសម្ព័ន្ធទី៨៖ សេចក្តីបំភ្លឺទាក់ទងនឹងសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT)

## ២. ឧបសម្ព័ន្ធរូបភាព

ឧបសម្ព័ន្ធទី១៖ នីតិព្រហ្មទណ្ឌទូទៅ

ឧបសម្ព័ន្ធទី២៖ CYBERCRIME IN PROGRESS

ឧបសម្ព័ន្ធទី៣៖ សេចក្តីរាយការណ៍

ឧបសម្ព័ន្ធទី៤៖ គំរូពាក្យបណ្តឹង

ឧបសម្ព័ន្ធទី៥៖ ទំនើបកម្ម កំណើន និងកង្វះការយល់ដឹង នៃការប្រើប្រាស់បច្ចេកវិទ្យា បង្កឱ្យលេចឡើងនូវបទល្មើសថ្មីប្លែក

# ឧបសម្ព័ន្ធគតិយុត្ត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២៤ លេខ០៥ ត្រីមាសទី០១ ឆ្នាំ២០២៤

# រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច បទបញ្ជា សារាចរ ប្រកាស

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៣០៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅ
## នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ នៃក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៣៩ អនក្រ.បក ចុះថ្ងៃ២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៩ មាត្រា១០ មាត្រា៤២ និងមាត្រា៤៥ នៃអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១._**

អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ២៧៩ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ត្រូវបានបង្កើត និងកែសម្រួលរចនាសម្ព័ន្ធឡើងវិញ ព្រមទាំងកំណត់តួនាទីភារកិច្ចនៅក្នុងអនុក្រឹត្យនេះ។

## ជំពូកទី២

## តួនាទីភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា២._**

អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ មានតួនាទីភារកិច្ចធ្វើជាសេនាធិការជូនក្រសួងមហាផ្ទៃ ក្នុងការដឹកនាំ គ្រប់គ្រង សម្របសម្រួលគោលនយោបាយ អភិបាលកិច្ច ហេដ្ឋារចនាសម្ព័ន្ធ សុវត្ថិភាព បច្ចេកវិទ្យាឌីជីថល ការងារបណ្តុះបណ្តាល ស្រាវជ្រាវ នវានុវត្តន៍ និងផ្សព្វផ្សាយអប់រំ ពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាឌីជីថល លើកលែងតែវិស័យបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មានវិទ្យាពាក់ព័ន្ធនឹងវិស័យសន្តិសុខជាតិ និងវិស័យដែលស្ថិតក្រោមសមត្ថកិច្ចនៃមជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មាន។

**មាត្រា៣._**

អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- សហការរៀបចំសេចក្តីព្រាងច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្ត ដើម្បីជានាដល់ការគ្រប់គ្រង ការអភិវឌ្ឍ ការការពារសន្តិសុខ និងការទប់ស្កាត់បទល្មើសបច្ចេកវិទ្យា
- រៀបចំ គ្រប់គ្រង តាមដាន និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាឌីជីថលរបស់ក្រសួងមហាផ្ទៃ
- សហការ សម្របសម្រួល និងដឹកនាំអនុវត្តគម្រោងបច្ចេកវិទ្យាឌីជីថល សម្រាប់ការផ្តល់សេវាសាធារណៈ ការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធឌីជីថល ប្រព័ន្ធការងាររដ្ឋបាល និងជំនាញ ដើម្បីជំរុញការធ្វើទំនើបកម្ម និងបរិវត្តកម្មឌីជីថលក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ
- រៀបចំបទដ្ឋានបច្ចេកទេសនៃសម្ភារបច្ចេកវិទ្យា ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់ឱ្យអង្គភាព និងភាគីពាក់ព័ន្ធយកទៅអនុវត្ត
- សហការ ត្រួតពិនិត្យ វាយតម្លៃ លើការងារផ្គត់ផ្គង់ និងបំពាក់សម្ភារឧបករណ៍បច្ចេកទេស ព្រមទាំងប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- សហការ វាយតម្លៃ កំណត់អាទិភាព និងលើកយោបល់គម្រោងវិនិយោគវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន របស់ក្រសួងមហាផ្ទៃ និងអង្គភាពក្រោមចំណុះ
- ទទួលខុសត្រូវលើការអភិវឌ្ឍ ការធ្វើទំនើបកម្ម និងការថែទាំប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា និងមជ្ឈមណ្ឌលទិន្នន័យនៅទីស្តីការក្រសួងមហាផ្ទៃ
- គ្រប់គ្រង តភ្ជាប់ និងចែករំលែកផ្លាស់ប្តូរទិន្នន័យឌីជីថលក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ និងសេវាបច្ចេកវិទ្យា ដើម្បីឱ្យស្របតាមច្បាប់ បទដ្ឋានគតិយុត្ត និងគោលការណ៍សុវត្ថិភាពបច្ចេកវិទ្យា

- ផ្សព្វផ្សាយច្បាប់ និងនូវរាល់បទបញ្ញា សារាចរ គោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃ
- បង្កើតកម្មវិធីស្វែងយល់ពីជំនាញនាទីសិល្បៈ អប់រំ កីឡា និងល្បែងកំសាន្តចូលរួមលើកកម្ពស់វិស័យវប្បធម៌ជាតិ ដើម្បីទទួលបានប្រជាប្រិយភាព
- រៀបចំគម្រោងផែនការផ្សព្វផ្សាយព័ត៌មានរយៈពេលវែង-ខ្លី ស្របតាមសភាពការណ៍វិវឌ្ឍន៍នៅក្នុងប្រទេស និងសកលលោក
- អនុវត្តតាមការប្រគល់ភារកិច្ចពីអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីល និងផ្សព្វផ្សាយអប់រំ ដើម្បីធ្វើការទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធ ស្វែងរកប្រភពព័ត៌មាន ដើម្បីផ្សព្វផ្សាយឱ្យបានទាន់ពេលវេលា
- ស្វែងរកដៃគូក្រុមហ៊ុនវិនិយោគនៅក្នុង ឬក្រៅប្រទេស ដើម្បីសហប្រតិបត្តិការលើការងារអភិវឌ្ឍន៍ បច្ចេកទេស និងដំណើរការធ្វើអាជីវកម្ម តាមដំណាក់កាលនីមួយៗ។ ការធ្វើអាជីវកម្មត្រូវមានកិច្ចសន្យាច្បាស់លាស់ដោយស្ថានីយ៍វិទ្យុ និងទូរទស្សន៍ ទទួលខុសត្រូវលើខ្លឹមសារនយោបាយ និងវិជ្ជាជីវៈ។ ចំពោះប្រភពមូលធនសម្រាប់ដំណើរការធ្វើអាជីវកម្ម គឺមិនស្ថិតក្នុងប្រភពផ្គត់ផ្គង់ពីថវិកាជាតិឡើយ
- ធ្វើកិច្ចសហការជាមួយស្ថានីយ៍ និងទូរទស្សន៍នានា ដើម្បីផ្លាស់ប្តូរបទពិសោធន៍ ពង្រីកបច្ចេកវិទ្យា បង្កើនគុណភាពផ្សព្វផ្សាយព័ត៌មានឱ្យកាន់តែទូលំទូលាយ
- កសាងគម្រោងផែនការបំពាក់ និងគ្រប់គ្រងថែរក្សា ឧបករណ៍ មធ្យោបាយ និងសម្ភារបច្ចេកទេស របស់អង្គភាព ដើម្បីធានាបានប្រសិទ្ធភាពការងារ
- កសាងគម្រោងផែនការបើកវគ្គបណ្តុះបណ្តាល ហ្វឹកហ្វឺន និងបំប៉នដល់មន្ត្រី បុគ្គលិក ដើម្បីបង្កើនកម្រិតយល់ដឹងពីសកម្មភាពថតរូបភាព ចុះយកព័ត៌មាន តែងនិពន្ធអត្ថបទតាមមុខវិជ្ជាជីវៈសារព័ត៌មាន
- ធ្វើការងារគ្រប់គ្រងឯកសារ ការងារបុគ្គលិក កស្តុភារ និងគណនេយ្យរបស់ស្ថានីយ៍វិទ្យុ និងទូរទស្សន៍មហាផ្ទៃ តាមការកំណត់របស់ក្រសួង
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់ស្ថានីយ៍វិទ្យុ និងទូរទស្សន៍មហាផ្ទៃ តាមការកំណត់ជូនអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ
- អនុវត្តភារកិច្ច និងសិទ្ធិផ្សេងៗទៀតដែលអគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ ប្រគល់ឱ្យ។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**មាត្រា១៥.**_

មាត្រា១៤ មាត្រា៦៧ និងមាត្រា៧១ នៃអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ អនុក្រឹត្យលេខ ២៧៩ អនក្រ.បក

ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការបង្កើតអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា១៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៤ រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែតុលា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ....៣០៣....អនក្រ.បក ចុះថ្ងៃទី..៣...ខែ....តុលា......ឆ្នាំ២០២៣

ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ នៃក្រសួងមហាផ្ទៃ

## អង្គការលេខរបស់អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ

**អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ**

- នាយកដ្ឋានរដ្ឋបាល-សរុប
- នាយកដ្ឋានបណ្តុះបណ្តាល និងអភិបាលកិច្ចបច្ចេកវិទ្យាឌីជីថល
- នាយកដ្ឋានអភិវឌ្ឍកម្មវិធី និងនវានុវត្តន៍ឌីជីថល
- នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- នាយកដ្ឋានការពារសុវត្ថិភាពបច្ចេកវិទ្យាឌីជីថល
- នាយកដ្ឋានផ្សព្វផ្សាយអប់រំ
- ស្ថានីយ៍វិទ្យុ និងទូរទស្សន៍មហាផ្ទៃ (ថ្នាក់ស្មើនាយកដ្ឋាន)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# ក្របខណ្ឌគោលនយោបាយ
# សេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា
# ២០២១-២០៣៥

ខែ ឧសភា ឆ្នាំ ២០២១

*“កសាងសេដ្ឋកិច្ច និង សង្គមឌីជីថលរស់រវើក តាមរយៈការរៀបចំមូលដ្ឋានគ្រឹះជំរុញការទទួលយក និង បរិវត្តកម្មឌីជីថលនៅក្នុងគ្រប់តួអង្គសង្គម ទាំងរដ្ឋ ទាំងពលរដ្ឋ និង ទាំងធុរជន ដើម្បីជំរុញសន្ទុះកំណើនសេដ្ឋកិច្ចថ្មី និង លើកកម្ពស់សុខុមាលភាពសង្គម តាមគន្លងប្រក្រតីភាពថ្មី”*

**រៀបចំដោយ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ**
**ខែ ឧសភា ឆ្នាំ ២០២១**

# បុព្វកថា

ចាប់ពីចុងទសវត្សរ៍ឆ្នាំ ១៩៨០ និងដើមទសវត្សរ៍ឆ្នាំ ១៩៩០, កម្ពុជាបានដាក់ចេញនូវការកែទម្រង់មូលដ្ឋានគ្រឹះសេដ្ឋកិច្ច ដោយបែរឆ្ពោះទៅរកសេដ្ឋកិច្ចទីផ្សារ និង ការបើកចំហពាណិជ្ជកម្មអន្តរជាតិ ។ គោលនយោបាយសេដ្ឋកិច្ចនេះ នាំមកនូវការផ្លាស់ប្តូរទាំងស្រុងនូវជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាគ្រប់ស្រទាប់វណ្ណៈ និងសម្រេចបានវឌ្ឍនភាពនៅគ្រប់វិស័យរហូតមកដល់បច្ចុប្បន្ននេះ ។ នៅជិតចុងបញ្ចប់នៃទសវត្សរ៍ឆ្នាំ ១៩៩០, កម្ពុជាខិតខំសម្រេចបាននូវសន្តិភាពពេញលេញបរិបូណ៌ តាមរយៈ **"នយោបាយឈ្នះ-ឈ្នះ"** ។ សរុបមក, ក្នុងរយៈពេលជិតបីទសវត្សរ៍កន្លងមក, រាជរដ្ឋាភិបាល សម្រេចបានសុខសន្តិភាពពេញលេញ, បូរណភាពទឹកដី, សាមគ្គីភាពជាតិ និងស្ថិរភាពនយោបាយ និងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ ។ មូលដ្ឋានគ្រឹះដ៏រឹងមាំនេះ បានរួមចំណែកដ៏សំខាន់ក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង អភិវឌ្ឍវិស័យឯកជនឱ្យកាន់តែរស់រវើក តាមរយៈការលើកកម្ពស់បរិយាកាសធុរកិច្ច និង វិនិយោគ ដែលជាប្រភពនៃការបង្កើតការងារក្នុងគ្រប់វិស័យ និង ជាចលករជំរុញសេដ្ឋកិច្ចសម្រេចបានកំណើនល្អប្រសើរ ក្នុងអត្រាជាមធ្យមប្រចាំឆ្នាំ ៧ ភាគរយ និងជាពិសេសបានប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប ក្នុងឆ្នាំ ២០១៥ ។ នៅពេលបិទបញ្ចប់សតវត្សរ៍ទី ២០, ការសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់នេះ បានផ្តល់ឱកាសឱ្យកម្ពុជា បង្កើនការវិនិយោគសាធារណៈ, ការអភិវឌ្ឍធនធានមនុស្ស និងកិច្ចគាំពារសង្គម និងបានកាត់បន្ថយអត្រានៃភាពក្រីក្រជាបន្តបន្ទាប់ឈានទៅបង្រួមវិសមភាពសង្គមឱ្យកាន់តែតូចគួរឱ្យកត់សម្គាល់។

កម្ពុជាបានចាប់ផ្តើមទំព័រសតវត្សរ៍ទី ២១ ជាមួយនឹងសមិទ្ធកម្មដ៏ត្រចះត្រចង់ និងការប្រែមុខមាត់ថ្មី ប្រកបដោយក្តីសង្ឃឹម ។ ប្រការនេះបាននិងកំពុងលើកទឹកចិត្តរាជរដ្ឋាភិបាលក្នុងការបន្តបង្កើនកិច្ចខិតខំប្រឹងប្រែង សំដៅធានាជវភាពនៃកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព, រឹងមាំ និង ធន់នឹងវិបត្តិ ក្នុងរយៈពេលមធ្យមខាងមុខ ស្របតាមគន្លងមាគ៌ាអភិវឌ្ឍន៍កន្លងមក ព្រមទាំងបានដាក់ចេញនូវ **"ចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០"** ដែលជាមាគ៌ាក្នុងការបង្កើតនូវចន្ទល់កំណើនសេដ្ឋកិច្ចកម្ពុជាថ្មីៗ ជំនួសឱ្យចន្ទល់ចាស់ ដែលមានសញ្ញាថមថយជាបណ្តើរៗ សម្រាប់រៀបចំនូវម៉ូដែលកំណើនថ្មី ដែលមានភាពឆ្លើយតប នឹងភាពធន់ខ្ពស់ទៅនឹងការផ្លាស់ប្តូរនិម្មាបនកម្មសេដ្ឋកិច្ច និង ពាណិជ្ជកម្មអន្តរជាតិនាពេលអនាគត ។

ជាអកុសល ការចាប់ផ្តើមនៃទសវត្សរ៍ទី ៣ នៃសតវត្សរ៍ទី ២១, កម្ពុជាមិនខុសពីប្រទេសដទៃទៀត និងពិភពលោកទាំងមូល, កំពុងរងនូវផលប៉ះពាល់ធ្ងន់ធ្ងរបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលមិនត្រឹមតែបានឆក់យកជីវិតប្រជាជនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដាក់សម្ពាធលើប្រភពកំណើន និង បង្កើតជាបច្ច័យអវិជ្ជមានដល់សកម្មភាពសេដ្ឋកិច្ច និង បញ្ហាជារចនាសម្ព័ន្ធដែលកំពុងប្រឈមស្រាប់ក្នុងរយៈពេលមធ្យមខាងមុខ និង ប៉ះទង្គិចដល់គន្លងអភិវឌ្ឍន៍រយៈពេលវែង ។ ទ្វេគ្រោះនេះតម្រូវឱ្យកម្ពុជាគិតគូរ និង រៀបចំម៉ូដែលកំណើនសេដ្ឋកិច្ចថ្មី ដែលមានភាពឆ្លើយតបនឹងភាពធន់ខ្ពស់ទៅនឹងការផ្លាស់ប្តូរនិម្មាបនកម្មសេដ្ឋកិច្ច និង ពាណិជ្ជកម្មអន្តរជាតិនាពេលអនាគតផង ជាពិសេសការស្តារឡើងវិញនូវសេដ្ឋកិច្ចក្រោយវិបត្តិជំងឺកូវីដ-១៩ ។ ទន្ទឹមនឹងស្ថានភាពដ៏ស្រួចស្រាល់នេះ, រាជរដ្ឋាភិបាលបានសម្លឹងមើលឃើញកាលានុវត្តភាព និង វិសាលភាពនៃផលប្រយោជន៍សេដ្ឋកិច្ចក្នុងវិស័យឌីជីថល ដែលមិនត្រឹមតែអាចប្រែក្លាយទៅជាប្រភពកំណើនសេដ្ឋកិច្ចថ្មីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចជួយជំរុញបង្កើនផលិតភាពនៃវិស័យផ្សេងទៀតផងដែរ ។ ជាក់ស្តែងនៅក្នុងស្ថានភាពពេលនេះ, ជាជាងពេលណាៗផ្សេងទៀត, បច្ចេកវិទ្យាឌីជីថលដើរតួកាន់តែ

សំខាន់ក្នុងការបង្កើនផលិតភាព, ការជំរុញ ពិពិធកម្មសេដ្ឋកិច្ច និង ការបង្កើតការងារ សំដៅជំរុញវឌ្ឍនភាពសង្គមឱ្យកាន់តែរីកចម្រើនថែមទៀត ។

**"ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥"** បានដាក់ចេញនូវចក្ខុវិស័យវែងឆ្ងាយ ក្នុងការកសាងសេដ្ឋកិច្ច និង សង្គមឌីជីថលរស់រវើក តាមរយៈការរៀបចំមូលដ្ឋានគ្រឹះជំរុញការទទួលយក និង ការធ្វើបរិវត្តកម្មឌីជីថល នៅក្នុងគ្រប់តួអង្គសង្គម ទាំងរដ្ឋ, ពលរដ្ឋ និង ធុរជន ដើម្បីជំរុញសម្ទុះកំណើនសេដ្ឋកិច្ចថ្មី និង លើកកម្ពស់សុខុមាលភាពសង្គម ដោយផ្អែកលើគន្លង **"ប្រក្រតីភាពថ្មី"** ។ សម្រាប់កម្ពុជា, ការធ្វើបរិវត្តកម្មឌីជីថល គឺជាការចាប់យក និង ការទាញយកផលប្រយោជន៍ជាអតិបរមាពីការរីកចម្រើននៃបច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន និង បច្ចេកវិទ្យាឌីជីថល ដើម្បីបង្កើនផលិតភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច ព្រមទាំងជំរុញកំណើនសេដ្ឋកិច្ចជាតិ និង កសាង សង្គមស៊ីវិល័យដែលពលរដ្ឋឌីជីថល អាចទទួលបាននូវផលប្រយោជន៍ពីការប្រើប្រាស់សេវាឌីជីថលប្រកបដោយបរិយាប័ន្ន, ភាពជឿទុកចិត្ត និង សុវត្ថិភាពខ្ពស់ ហើយដំណាលគ្នានេះក៏រក្សាឱ្យបាននូវ អត្តសញ្ញាណ និង វប្បធម៌ជាតិ ។ ខ្ញុំមានជំនឿចិត្តដ៏មុតមាំថា កម្ពុជាត្រូវខិតខំសម្រេច **"បរិវត្តកម្មឌីជីថល"** ឱ្យខាងតែបាន ទើបអាចប្រែក្លាយសេដ្ឋកិច្ច-សង្គមកម្ពុជា ទៅកាន់កម្រិតអភិវឌ្ឍន៍មួយខ្ពស់ឡើងជាលំដាប់បាន ។ ក្នុងន័យនេះ, ក្រសួង-ស្ថាប័នទទួលបន្ទុកអនុវត្តត្រូវសហការគ្នាជាធ្លុងមួយ ដោយមានការសម្របសម្រួល និងការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរស្ថាប័នក្នុងស្មារតីបុរេសកម្ម និងអន្តរសកម្មបំផុត ដើម្បីធានាបាននូវការសម្រេចបាននូវគោលបំណងគោលនយោបាយគន្លឹះដែលបានកំណត់ ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា, ខ្ញុំសូមកោតសរសើរ និង វាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ជាប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ** ដែលបានដឹកនាំគណៈកម្មាធិការអន្តរក្រសួង និង **ឯកឧត្តម វង្សី វិស្សុត រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និង ជារដ្ឋលេខាធិការប្រចាំការនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** ដែលបានដឹកនាំផ្ទាល់រៀបចំសេចក្តីព្រាងក្របខណ្ឌគោលនយោបាយនេះ រហូតដល់សម្រេចបាននូវសមិទ្ធផលជាក្របខណ្ឌគោលនយោបាយនេះឡើង ។ ទន្ទឹមនេះ, ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាអនុប្រធាន ព្រមទាំងសមាជិក និង សមាជិកានៃគណៈកម្មាធិការអន្តរក្រសួង និង ក្រុមការងារបច្ចេកទេសរៀបចំក្របខណ្ឌគោលនយោបាយនេះ ចំពោះការចូលរួមយ៉ាងសកម្ម និង ប្រកបដោយការទទួលខុសត្រូវខ្ពស់ ។

ថ្ងៃ ចន្ទ ១៤ រោច ខែ ពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

(Transportation Navigation System) ក្នុងន័យធានាបាននូវប្រសិទ្ធភាព, ភាពទាន់ពេលវេលា និង សុវត្ថិភាពនៃប្រព័ន្ធដឹកជញ្ជូន,

- កសាងយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្សនៅក្នុងវិស័យឡូហ្សីស្ទិក ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យនេះ នៅដំណាក់កាលបន្ទាប់, និង
- បន្តជំរុញ និង លើកកម្ពស់ការអនុវត្តវិធានការកិច្ចសម្រួលពាណិជ្ជកម្ម ដែលមានចែងក្នុង យុទ្ធសាស្ត្រកំណែទម្រង់ និង ទំនើបកម្មគយ ព្រមទាំងយុទ្ធសាស្ត្រផ្សេងៗ ដែលពាក់ព័ន្ធ ។

ជាមួយគ្នានេះ ដោយហេតុថា ការអភិវឌ្ឍវិស័យដឹកជញ្ជូនគោលដៅចុងក្រោយស្ថិតនៅដំណាក់កាលនៃការចាប់ផ្តើម, ការអភិវឌ្ឍ និង ការពង្រឹងបន្ថែមនៃវិស័យនេះ ចាំបាច់ត្រូវផ្តោតលើការដាក់ចេញ និង ការអនុវត្តនូវវិធានការដាក់លាក់ ដូចខាងក្រោម៖

- រៀបចំកសាងផែនការយុទ្ធសាស្ត្រជំរុញ និង អភិវឌ្ឍវិស័យដឹកជញ្ជូន និង ការចែកបញ្ញើគោលដៅចុងក្រោយ ក្នុងន័យបង្កើតប្រព័ន្ធអេកូឡូស៊ី និង យន្តការដាក់លាក់ នៅក្នុងវិស័យ នេះ ដោយឈរលើគោលការណ៍ប្រសិទ្ធភាព, នវានុវត្តន៍, ចីរភាពបរិស្ថាន, ភាពធន់នឹងវិបត្តិ និង អន្តរទំនាក់ទំនង,
- កសាងស្តង់ដានៃអាសយដ្ឋាន និង កែលម្អប្រព័ន្ធកូដប្រៃសណីយ៍ ព្រមទាំងដាក់ឱ្យអនុវត្ត និង ចែករំលែកក្នុងទម្រង់ឌីជីថលដល់គ្រប់ភាគីពាក់ព័ន្ធឱ្យបានទូលំទូលាយ តាមការកំណត់ក្នុងផែនការមេឡូហ្សីស្ទិកជាតិ,
- កសាងផែនការយុទ្ធសាស្ត្រសម្រាប់កែទម្រង់ និង ធ្វើទំនើបកម្មប្រព័ន្ធប្រៃសណីយ៍ ដើម្បីធានាបាននូវសេវាប្រៃសណីយ៍ ដែលមានថ្លៃសមរម្យ, ទាន់ពេលវេលា និង វិសាលភាពធំទូលាយ, និង
- ធ្វើវិសោធនកម្ម ឬ កែសម្រួលច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការដឹកជញ្ជូនការចែកចាយបញ្ញើ និង ភស្តុភារកម្មប្រៃសណីយ៍នៅក្នុងស្រុក ក្នុងន័យធ្វើសេរីភាវូបនីយកម្មសេវានេះ ។

### ៣.៤.២. ការកសាងទំនុកចិត្ត និង ភាពជឿជាក់លើប្រព័ន្ធឌីជីថល

ភាពជឿទុកចិត្ត គឺជាគន្លឹះសំខាន់ សម្រាប់ការអភិវឌ្ឍ និង កសាងសេដ្ឋកិច្ច និង សង្គមឌីជីថល តាមរយៈការកសាងក្របខណ្ឌច្បាប់ និង ការលើកកម្ពស់ការយល់ដឹងអំពីសន្តិសុខសាយប័រ ។ ការរៀបចំ និង អនុវត្តនូវវិធានការគោលនយោបាយនៃក្របខណ្ឌច្បាប់ និង សន្តិសុខសាយប័រ ត្រូវបានគិតគូរដោយឈរលើគោលការណ៍ចំនួន ២ ដែលរួមមាន៖ (១). ការរៀបចំក្របខណ្ឌច្បាប់ និង (២). ការពង្រឹងការគ្រប់គ្រងសន្តិសុខសាយប័រ ។

#### ក. វិធានការគោលនយោបាយផ្នែកក្របខណ្ឌច្បាប់

ច្បាប់ និង លិខិតបទដ្ឋានគតិយុត្តសម្រាប់សេដ្ឋកិច្ច និង សង្គមឌីជីថល ត្រូវមានវិសាលភាពពេញលេញគ្រប់ជ្រុងជ្រោយ និង មានតួនាទីចូលរួមបង្កើតលក្ខខណ្ឌអំណោយផលសម្រាប់កសាងប្រព័ន្ធអេកូឡូស៊ីនៃសេដ្ឋកិច្ច និង សង្គមឌីជីថល និង បណ្តុះភាពជឿទុកចិត្តឱ្យមានការចូលរួមពីតួអង្គពាក់ព័ន្ធ ។ យ៉ាងណាមិញ

ការរឹតបន្តឹងនឹងត្រូវធ្វើឡើងក្នុងទម្រង់ស្រាល (Light Touch Approach) ដើម្បីលើកស្ទួយការចូលរួមក្នុងប្រព័ន្ធ និង ជំរុញឱ្យសេដ្ឋកិច្ច និង សង្គមឌីជីថលចាប់ផ្ដើមដំណើរការ និង លូតលាស់យ៉ាងសន្សឹមៗ ជាមុនសិន តាមរយៈការដាក់ចេញ និង ការអនុវត្តនូវវិធានការដាក់លាក់ ដូចខាងក្រោម៖

- កសាងច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដែលនៅសេសសល់ ជាអាទិ៍ ច្បាប់ស្ដីពីការការពារទិន្នន័យ និង ឯកជនភាព (Data Protection and Privacy Law), ច្បាប់ស្ដីពីព័ត៌មានសាធារណៈ (Public Information Law), ច្បាប់ស្ដីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន, ច្បាប់ស្ដីពីអាថ៌កំបាំងពាណិជ្ជកម្ម និង ព័ត៌មានដែលមិនអាចបង្ហាញចេញ, ក្រមសីលធម៌អ្នកប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក,
- ធ្វើវិសោធនកម្ម ឬ កែសម្រួល, បន្តរៀបចំ និង អនុវត្តនូវច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យសន្តិសុខសាយប័រ ដើម្បីឆ្លើយតបទៅនឹងបរិការណ៍ថ្មី និង ស្ថានភាពជាក់ស្ដែង,
- រៀបចំផែនការកសាងសមត្ថភាពរបស់អ្នករៀបចំ និង តាក់តែងច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងមន្ត្រីជំនាញ ឱ្យមានចំណេះដឹងឌីជីថល, និង
- លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីវប្បធម៌នៃការគោរពច្បាប់ជាធរមាន តួយ៉ាងច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង ច្បាប់ស្ដីពីការការពារអ្នកប្រើប្រាស់ ។

### ខ. វិធានការគោលនយោបាយផ្នែកសន្តិសុខសាយប័រ

ប្រសិទ្ធភាពនៃការគ្រប់គ្រងសន្តិសុខសាយប័រ នឹងជួយដល់ការកាត់បន្ថយហានិភ័យជាអតិបរមាក្នុងការប្រើប្រាស់ប្រព័ន្ធឌីជីថល, ផ្ដល់បរិយាកាសអំណោយផលដល់ការរីកចម្រើនយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ចឌីជីថល និង ធានាបាននូវសង្គមឌីជីថលមួយដែលមានសុវត្ថិភាព និង សន្តិសុខខ្ពស់ ។ បន្ថែមពីនេះ ការយល់ដឹងពីបញ្ហាពាក់ព័ន្ធនឹងឌីជីថល ជាពិសេសបញ្ហាសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត គឺជាកត្តាកំណត់ដ៏សំខាន់ ដើម្បីជំរុញ និង លើកទឹកចិត្តការចូលរួមពីអ្នកប្រើប្រាស់ សំដៅបង្កើនការប្រើប្រាស់ និង ការទទួលយកឌីជីថលឱ្យកាន់តែច្រើនឡើង ។ ក្នុងន័យនេះ ការកសាងសេដ្ឋកិច្ច និង សង្គមឌីជីថល ប្រកបដោយសន្តិសុខ និង សុវត្ថិភាព នឹងសម្រេចបាន តាមរយៈការដាក់ចេញ និង ការអនុវត្តនូវវិធានការដាក់លាក់ ដូចខាងក្រោម៖

- បន្តកសាងច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និង រៀបចំគោលនយោបាយ ឬយុទ្ធសាស្ត្រស្ដីពីសន្តិសុខសាយប័រ,
- រៀបចំ និង វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងសន្តិសុខសាយប័រថ្នាក់ជាតិ ក្រោមគណៈកម្មាធិការថ្នាក់ជាតិ ដើម្បីពិនិត្យ និង តាមដានជាប្រចាំ នូវហានិភ័យ ដែលកើតមាន នៅក្នុងប្រទេស, តំបន់ និង សកល,
- បង្កើតយន្តការស្ថាប័ន នៅតាមក្រសួង-ស្ថាប័ន ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ តួយ៉ាង មជ្ឈមណ្ឌលសម្រាប់ការឆ្លើយតបទៅនឹងឧប្បត្តិហេតុសន្តិសុខកុំព្យូទ័រ និង អ៊ីនធឺណិត (Center for Computer

and Internet Incident Response) ដើម្បីគ្រប់គ្រង និង ជាបង្គោលក្នុងការផ្លាស់ប្តូរព័ត៌មានពីបញ្ហា និង ហានិភ័យផ្សេងៗ,

- រៀបចំស្តង់ដា ក្របខណ្ឌបច្ចេកទេស និង នីតិវិធីនៃការឆ្លើយតប ដើម្បីជាមូលដ្ឋានសម្រាប់ការអនុវត្តក្នុងការរៀបចំអភិវឌ្ឍប្រព័ន្ធ និង ហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដែលមានភាពធន់នឹងការវាយប្រហារ,
- រៀបចំយុទ្ធសាស្ត្រ និង គោលការណ៍ណែនាំ ដើម្បីលើកកម្ពស់ការយល់ដឹងពីបញ្ហាសន្តិសុខសាយប័រតាមកម្រិត,
- លើកកម្ពស់ការអភិវឌ្ឍជំនាញសន្តិសុខសាយប័រ ជាអាទិ៍ ការផ្តល់ការទទួលស្គាល់ជាផ្លូវការ (Accreditation) សម្រាប់អ្នកជំនាញសន្តិសុខសាយប័រ, ការបណ្តុះបណ្តាលជំនាញបច្ចេកទេសផ្នែកសន្តិសុខសាយប័រ, និង
- រៀបចំក្របខណ្ឌសហប្រតិបត្តិការក្នុងក្របខណ្ឌទ្វេភាគី និង ពហុភាគី និង បង្កើតកិច្ចសហប្រតិបត្តិការជាមួយនឹងអង្គការអន្តរជាតិ ឬ សមាគម និង វិស័យឯកជន ដែលធ្វើការពាក់ព័ន្ធនឹងសន្តិសុខសាយប័រ ដើម្បីចែករំលែកព័ត៌មាន, បទពិសោធ និង ឧត្តមានុវត្តន៍ ។

### ៣.៤.៣. ការកសាងពលរដ្ឋឌីជីថល

ចំណេះដឹង, ជំនាញ និង ទេពកោសល្យ ជាផ្នែកមួយដ៏សំខាន់ ជាពិសេសក្នុងដំណាក់កាលនៃការចាប់យកឌីជីថល និង ការជំរុញការធ្វើបរិវត្តកម្មឌីជីថល ទាំងផ្នែកសេដ្ឋកិច្ច សង្គម និង វប្បធម៌ ។ ដូច្នេះ ក្របខណ្ឌគោលនយោបាយនេះ ផ្តោតទៅលើការអភិវឌ្ឍជំនាញឌីជីថល ទាំងវិស័យសាធារណៈ និង វិស័យឯកជន នៅគ្រប់កម្រិត និង គ្រប់ស្រទាប់ ព្រមទាំងការប្រមូលផ្តុំនូវទេពកោសល្យឌីជីថល និង ការជំរុញពលរដ្ឋឌីជីថល ។

#### ក. វិធានការគោលនយោបាយផ្នែកអ្នកដឹកនាំឌីជីថល

ក្នុងនិន្នាការនៃការធ្វើឌីជីថលូបនីយកម្មសំដៅទៅបរិវត្តកម្មឌីជីថល ការអភិវឌ្ឍធនធានមនុស្សកម្ពុជាក្លាយជាអ្នកដឹកនាំឌីជីថលតម្រូវឱ្យមានការយកចិត្តទុកដាក់លើការអភិវឌ្ឍសមត្ថភាព ទាំងនៅក្នុងវិស័យសាធារណៈ និង វិស័យឯកជន ។ នៅក្នុងបរិការណ៍កម្ពុជា រាជរដ្ឋាភិបាលជាតួអង្គសំខាន់ឈានមុខក្នុងការត្រួសត្រាយផ្លូវក្នុងដំណើរឆ្ពោះទៅកាន់បរិវត្តកម្មឌីជីថលនាពេលខាងមុខ ។ ការបង្កើតរដ្ឋាភិបាលឌីជីថលឱ្យលេចចេញជារូបរាង ត្រូវការជាចាំបាច់នូវការអភិវឌ្ឍសមត្ថភាពនៃអ្នកដឹកនាំឌីជីថលនៅក្នុងវិស័យសាធារណៈជាចម្បង ដោយការដាក់ចេញ និង ការអនុវត្តនូវវិធានការដាក់លាក់ ដូចខាងក្រោម៖

- រៀបចំក្របខណ្ឌរួមស្តីពីការលើកកម្ពស់អក្ខរកម្មឌីជីថល ក្នុងចំណោមអ្នកដឹកនាំ និង មន្ត្រីនៅតាមក្រសួង-ស្ថាប័នរដ្ឋ ដែលរួមបញ្ចូលទាំងការបណ្តុះបណ្តាលជំនាញ និង ការកសាងភាពជាអ្នកដឹកនាំឌីជីថល,
- រៀបចំក្របខណ្ឌត្រួតពិនិត្យ និង វាយតម្លៃការអភិវឌ្ឍធនធានមនុស្សឌីជីថលនៅតាមក្រសួង-ស្ថាប័ន

| | | | |
|---|---|---|---|
| ១០ | Cloud (computing) Technology | បច្ចេកវិទ្យាក្លោដ | បច្ចេកវិទ្យានៃហេដ្ឋារចនាសម្ព័ន្ធសម្រាប់ផ្តល់សេវាកម្ម ផ្ទុកទិន្នន័យ និង ធនធានគណនា សម្រាប់ប្រតិបត្តិការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានតាមប្រព័ន្ធអ៊ីនធឺណិត ។ |
| ១១ | Cloud-Based Service | សេវាកម្មក្លោដ | សេវាកម្មនៃការប្រើប្រាស់កម្មវិធីសុស្វវែរដែលប្រតិបត្តិការលើបច្ចេកវិទ្យាក្លោដ ។ |
| ១២ | Cybercrime | ឧក្រិដ្ឋកម្មសាយប័រ | បទល្មើស ដែលប្រព្រឹត្តនៅក្នុងបណ្តាញបច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន ដូចជា ការចូលលួច ក្លែងបន្លំ ឬ កែឯកសារ ការបញ្ចូលមេរោគ ការផ្ញើសារគំរាមកំហែង ឬចាប់ជំរិត ឬ ការធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសេដ្ឋកិច្ច និង សង្គមជាតិ ។ |
| ១៣ | Cybersecurity | សន្តិសុខសាយប័រ | ការអនុវត្តនៃការទប់ស្កាត់ ការឆ្លើយតប និង ការការពារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន រួមទាំង ហេដ្ឋារចនាសម្ព័ន្ធបណ្តាញ ប្រព័ន្ធប្រតិបត្តិការ និង កម្មវិធី ពីការជ្រៀតចូល និង ការវាយប្រហារគ្រប់រូបភាព ជាពិសេសតាមប្រព័ន្ធអ៊ីនធឺណិត ។ |
| ១៤ | Data | ទិន្នន័យ | បណ្តុំលេខ អក្សរ និមិត្តសញ្ញា សារ រូបភាព សំឡេង វីដេអូ ព័ត៌មាន ឬ កម្មវិធីអេឡិចត្រូនិក ដែលត្រូវបានរៀបចំក្នុងទម្រង់សមស្របសម្រាប់ប្រើប្រាស់ក្នុងមូលដ្ឋានទិន្នន័យ ឬប្រព័ន្ធអេឡិចត្រូនិក ។ |
| ១៥ | Data Center | មជ្ឈមណ្ឌលទិន្នន័យ | ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ផ្តល់សេវាកម្ម ផ្ទុកទិន្នន័យ និង ធនធានគណនា សម្រាប់ប្រតិបត្តិការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ។ |
| ១៦ | Data Infrastructure | ហេដ្ឋារចនាសម្ព័ន្ធទិន្នន័យ | ហេដ្ឋារចនាសម្ព័ន្ធឌីជីថលដើម្បីផ្ទុក បំប្លែង និង វិភាគទិន្នន័យដើម្បីជំរុញឱ្យមានការផ្លាស់ប្តូរ និង ការប្រើប្រាស់ទិន្នន័យ ។ |
| ១៧ | Data Privacy (Information Privacy) | ឯកជនភាពនៃទិន្នន័យផ្ទាល់ខ្លួន | នីតិវិធីដែលធានាថាទិន្នន័យរបស់រូបវន្តបុគ្គល និង នីតិបុគ្គលដែលទទួលបានការយល់ព្រមឱ្យកត់ត្រាដោយនីតិបុគ្គលណាមួយក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមិនត្រូវបានចែករំលែក លួចយក ឬ យកទៅប្រើប្រាស់ដោយគ្មានការអនុញ្ញាតពីម្ចាស់ទិន្នន័យ ។ |
| ១៨ | Database | មូលដ្ឋានទិន្នន័យ | បណ្តុំទិន្នន័យដែលមានទំនាក់ទំនងគ្នាបង្កើតឡើងក្នុងគោលបំណងងាយស្រួលគ្រប់គ្រង និង ស្វែងរក ។ |
| ១៩ | Data-Driven Governance | អភិបាលកិច្ចដោយផ្អែកលើទិន្នន័យ | អភិបាលកិច្ចដោយប្រើប្រាស់ទិន្នន័យដើម្បីនាំឱ្យមានការសម្រេចចិត្តជាគោលនយោបាយ កំណត់គោលដៅ ផ្លាស់ប្តូរវិធានការគោលនយោបាយ និង តាមដានការអនុវត្តគោលនយោបាយក្នុងន័យបង្កើនតម្លាភាព ។ |

| | | | |
|---|---|---|---|
| ២០ | Digital Technology | បច្ចេកវិទ្យាឌីជីថល | បច្ចេកវិទ្យាដែលប្រើប្រាស់ឧបករណ៍អេឡិចត្រូនិក ឧបករណ៍ឆ្លាត ប្រព័ន្ធទូរគមនាគមន៍ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង ធនធានគណនា សម្រាប់បង្កើត ផ្ទុក បំប្លែង និង វិភាគទិន្នន័យ ។ |
| ២១ | Digital Adaptation | ការសម្របឌីជីថល | សមត្ថភាពរបស់មនុស្សក្នុងការយល់ដឹង និង ការសម្របខ្លួនទៅតាមការវិវឌ្ឍឥតឈប់ឈររបស់បច្ចេកវិទ្យាឌីជីថលដែលចាក់ជ្រៅទៅក្នុងធុរកិច្ច សេដ្ឋកិច្ច និង សង្គម ។ |
| ២២ | Digital Adoption | ការស្រូបយក ឬ ការចាប់យកឌីជីថល | ស្ថានភាពដែលមនុស្សមានជំនាញក្នុងការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិក ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង ថ្នាលឌីជីថលតាមបំណង និង ឱ្យអស់លទ្ធភាព ។ |
| ២៣ | Digital business | ធុរកិច្ចឌីជីថល | ធុរកិច្ចដែលមានអាជីវកម្មចម្បងប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ឬ ផ្តល់សេវាឌីជីថល ឬ បង្កើតផលិតផលជាបច្ចេកវិទ្យាឌីជីថល។ |
| ២៤ | Digital Citizen | ពលរដ្ឋឌីជីថល | ប្រជាពលរដ្ឋដែលចេះប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងកិច្ចការ និង ការរស់នៅប្រចាំថ្ងៃ ។ |
| ២៥ | Digital Content | ខ្លឹមសារឌីជីថល | ខ្លឹមសារនៃព័ត៌មានក្នុងទម្រង់ឌីជីថល ដែលអាចមើល អាន ស្តាប់ ឬ ទាញយកបាន ក្នុងទម្រង់ជាអត្ថបទ រូបភាពសំឡេង វីដេអូ ។ល។ |
| ២៦ | Digital Government | រដ្ឋាភិបាលឌីជីថល | ដំណើរការនៃការធ្វើទំនើបកម្មលើប្រព័ន្ធគ្រប់គ្រងរដ្ឋាភិបាល និង សេវាសាធារណៈតាមរយៈការប្រើប្រាស់នូវបច្ចេកវិទ្យាឌីជីថល ដូចជាកុំព្យូទ័រ ឧបករណ៍ឆ្លាត និង ប្រព័ន្ធអ៊ីនធឺណិត សំដៅជួយសម្រួលដល់ការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់រដ្ឋ ការសម្រេចចិត្ត និង ការផ្តល់សេវាជូនប្រជាពលរដ្ឋ វិស័យឯកជន និង ស្ថាប័នពាក់ព័ន្ធនានាប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និង បរិយាបន្នកម្ម ។ |
| ២៧ | Digital Identity | អត្តសញ្ញាណឌីជីថល | ព័ត៌មានដែលបញ្ជាក់ពីអត្តសញ្ញាណរូបវន្តបុគ្គល និង នីតិបុគ្គលក្នុងពិភពឌីជីថលដែលព័ត៌មាននេះបានភ្ជាប់ទៅនឹងអត្តសញ្ញាណរូបវន្តបុគ្គល និង នីតិបុគ្គលនៅក្នុងពិភពពិត ។ |
| ២៨ | Digital Literacy | អក្ខរកម្មឌីជីថល | ជំនាញដែលជំរុញសមត្ថភាពឌីជីថល និង ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និង ទូរគមនាគមន៍ សម្រាប់ការសិក្សារៀនសូត្រ កម្សាន្ត ការងារ និង ការប្រាស្រ័យទាក់ទង ។ |
| ២៩ | Digital Platform | ថ្នាលឌីជីថល | កម្មវិធីបច្ចេកវិទ្យាព័ត៌មានបង្កើតបានជាពិភពឌីជីថលបម្រើក្នុងគោលបំណងជាក់លាក់មួយ និង សម្រាប់សម្របសម្រួលអ្នកប្រើប្រាស់ធ្វើអន្តរសកម្ម និង អន្តរប្រតិបត្តិការជាមួយនឹងអ្នកពាក់ព័ន្ធនានា ។ |

| | | | |
|---|---|---|---|
| ៣៩ | Ecosystem | ប្រព័ន្ធអេកូឡូស៊ី | ប្រព័ន្ធទំនាក់ទំនងដែលមានភាពប្រកួតប្រជែងគ្នានៃសមាសភាពពាក់ព័ន្ធរួមមាន មនុស្ស ស្ថាប័ន កម្មវិធី នីតិវិធី អន្តរាគមន៍ ទីផ្សារ ប្រព័ន្ធផ្សព្វផ្សាយ ។ល។ បង្កើតបានជាប្រព័ន្ធមួយអាចគ្រប់គ្រង និង អភិវឌ្ឍខ្លួនឯងបាន ប្រកបដោយចីរភាព ។ |
| ៤០ | E-government | រដ្ឋាភិបាលអេឡិចត្រូនិក | ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ ជាពិសេសប្រព័ន្ធអ៊ីនធឺណិត ដោយរាជរដ្ឋាភិបាល ដើម្បីសម្រេចបាននូវរាជរដ្ឋាភិបាលមួយដែលល្អប្រសើរ ។ |
| ៤១ | Electronic Know Your Customer (eKYC) | ការសម្គាល់អតិថិជនឌីជីថល | ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដើម្បីបង្កើត និង កំណត់អត្តសញ្ញាណរបស់អតិថិជនក្នុងពិភពឌីជីថលតាមប្រព័ន្ធអេឡិចត្រូនិក ដោយពឹងផ្អែកលើឯកសារសម្គាល់អត្តសញ្ញាណដែលទទួលស្គាល់ដោយរាជរដ្ឋាភិបាល ។ |
| ៤២ | FinTech (Financial Technology) | បច្ចេកវិទ្យាហិរញ្ញវត្ថុ | បច្ចេកវិទ្យា និង នវានុវត្តន៍លើវិស័យហិរញ្ញវត្ថុ ទាំងវិស័យ ធនាគារ និង វិស័យហិរញ្ញវត្ថុមិនមែនធនាគារ បង្កើតឡើងដើម្បីឱ្យមានការចូលប្រើប្រាស់ ផ្តល់ និង ទទួលសេវាហិរញ្ញវត្ថុបានទូលំទូលាយ ប្រកបដោយបរិយាបន្នកម្ម ។ |
| ៤៣ | FinTech Regulatory Sandbox | បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ | បរិស្ថានសម្រាប់ឱ្យគ្រឹះស្ថានបច្ចេកវិទ្យាហិរញ្ញវត្ថុសាកល្បងនូវផលិតផល និង សេវារបស់ខ្លួនជាមួយនឹងអតិថិជនពិតប្រាកដ ប៉ុន្តែក្នុងទំហំ និង រយៈពេលកំណត់មួយ មុននឹងធ្វើការដាក់ចេញ និង ការជំរុញការប្រើប្រាស់ឱ្យបានទូលំទូលាយ ។ |
| ៤៤ | Industry 4.0 | ឧស្សាហកម្ម ៤.០ | បរិបទនៃការវិវឌ្ឍឧស្សាហកម្មដែលបច្ចេកវិទ្យាអនុញ្ញាតឱ្យមានការបញ្ចូលគ្នានៃទិន្នន័យពីម៉ាស៊ីន ឧបករណ៍ និង សេនស័រ ពីខ្សែច្រវាក់ផលិតកម្ម និង ពីការប្រើប្រាស់របស់មនុស្ស ហើយដែលផ្តល់ព័ត៌មានច្បាស់លាស់ និង ទាន់ពេល ដល់អ្នកផលិត និង អ្នកពាក់ព័ន្ធ សំដៅធ្វើឱ្យប្រសើរឡើងនូវខ្សែច្រវាក់ផលិតកម្មទាំងមូល ។ |
| ៤៥ | Internet | អ៊ីនធឺណិត | បណ្តាញកុំព្យូទ័រសកលដែលភ្ជាប់គ្នាតាមរយៈពិធីសារគមនាគមន៍រួមមួយដើម្បីចែករំលែក និង ផ្តល់ព័ត៌មាន ។ |
| ៤៦ | Internet of Things (IoT) | ប្រព័ន្ធអ៊ីនធឺណិតនៃវត្ថុ | ការបំពាក់ឧបករណ៍អ៊ីនធឺណិតទៅនឹងសត្វ មនុស្ស ផ្ទះ អគារ យានយន្ត និង វត្ថុផ្សេងៗទៀត... ដើម្បីប្រតិបត្តិការជាមួយនឹងមជ្ឈមណ្ឌលអ៊ីនធឺណិតនៅគ្រប់ទីកន្លែង គ្រប់ពេលវេលាសម្រាប់បញ្ជូន-ទទួលព័ត៌មាន ។ |

# ក្របខណ្ឌគោលនយោបាយ
# សេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា
# ២០២១-២០៣៥

ខែ ឧសភា ឆ្នាំ ២០២១

រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយ
# រដ្ឋាភិបាលឌីជីថលកម្ពុជា
# ២០២២-២០៣៥



# “កសាងរដ្ឋាភិបាលឌីជីថល ដើម្បីលើកកម្ពស់ គុណភាពជីវិតនិងទំនុកចិត្តប្រជាពលរដ្ឋ តាមរយៈការបម្រើសេវាសាធារណៈឱ្យកាន់តែល្អប្រសើរ”

រៀបចំដោយ
ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
ខែមករា ឆ្នាំ២០២២

# ៣- ស្ថានភាពរដ្ឋាភិបាលឌីជីថលកម្ពុជា

## ៣.១- ដំណើរវិវត្ត

នៅឆ្នាំ២០០០ សេវាសាធារណៈឌីជីថលនៅកម្ពុជាបានចាប់ផ្តើមជាលើកដំបូង ហើយ**អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា(NiDA)** ត្រូវបានបង្កើតក្រោមទីស្តីការគណៈរដ្ឋមន្ត្រី។ អាជ្ញាធរនេះបានស្ថាបនាបណ្តាញហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ ដែលចាប់ផ្តើមពីការតភ្ជាប់ក្រសួងស្ថាប័ន និងបន្ទាប់មកពង្រីកទៅតាមខេត្តអាទិភាព ចំនួន៩ ដោយមានមជ្ឈមណ្ឌលទិន្នន័យ ចំនួន៣ និងប្រព័ន្ធព័ត៌មានឌីជីថល ចំនួន៣។

នៅឆ្នាំ២០១៣ NiDA ត្រូវបានធ្វើសមាហរណកម្មមកក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ហើយបណ្តាញហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិនៅបន្តប្រើប្រាស់ តាមក្រសួងស្ថាប័នរហូតដល់បច្ចុប្បន្ន។ បន្ទាប់មក រាជរដ្ឋាភិបាលកម្ពុជាបានបន្តអភិវឌ្ឍវិស័យទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដោយបានដាក់ចេញនូវឯកសារគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួន ដែលខ្លឹមសារគោលនៃឯកសារទាំងនេះមានសង្គតិភាពជាមួយឧត្តមានុវត្តន៍អន្តរជាតិ និងបានរំលេចភាពជាដៃគូរវាងរដ្ឋនិងឯកជន។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ពីឆ្នាំ២០១៣ដល់ឆ្នាំ២០១៨ បានគូសបញ្ជាក់នូវភាពចាំបាច់បន្តអភិវឌ្ឍរដ្ឋាភិបាលអេឡិចត្រូនិក(e-Government) និងជំរុញវិស័យឯកជនឱ្យវិនិយោគកាន់តែច្រើនលើបច្ចេកវិទ្យានិងហេដ្ឋារចនាសម្ព័ន្ធឌីជីថល។ នៅឆ្នាំ២០១៤ ***ផែនការមេបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានកម្ពុជាឆ្នាំ២០២០*** ត្រូវបានអនុម័តក្នុងគោលបំណងជំរុញការអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងពង្រឹងការអភិវឌ្ឍមូលធនមនុស្ស ការតភ្ជាប់ប្រព័ន្ធអ៊ីនធឺណិត សន្តិសុខឌីជីថល និងសេវាសាធារណៈតាមប្រព័ន្ធអេឡិចត្រូនិក។

នៅឆ្នាំ២០១៤ រាជរដ្ឋាភិបាលបានបង្កើតវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន(NIPTICT) ជាសេនាធិការរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីចូលរួមការបណ្តុះបណ្តាលមូលធនមនុស្សជំនាញនិងអក្ខរកម្មឌីជីថលដល់មន្ត្រីរាជការ និងជំរុញការស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថល ហើយវិទ្យាស្ថាននេះត្រូវបានអភិវឌ្ឍទៅជាបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា(CADT)នៅឆ្នាំ២០២១។ គិតត្រឹមឆ្នាំ២០២១ បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជាបានបណ្តុះបណ្តាលដល់និស្សិតជំនាញឌីជីថល៥០០នាក់ អក្ខរកម្មឌីជីថលដល់មន្ត្រីរាជការជាង៦ ៧០០នាក់ ពីគ្រប់ក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងអក្ខរកម្មឌីជីថលដល់សិស្សានុសិស្ស និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិជាង៥ ០០០នាក់នៅតំបន់ដាច់ស្រយាល ព្រមទាំងស្រាវជ្រាវលើបច្ចេកវិទ្យាឌីជីថលដូចជាបច្ចេកវិទ្យាភាសាខ្មែរ បញ្ញាសិប្បនិម្មិត ជាដើម និងបានចូលរួមជំរុញនវានុវត្តន៍ឌីជីថលនិងការកសាងប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មីឌីជីថល។

នៅឆ្នាំ២០១៥ ***ច្បាប់ស្តីពីទូរគមនាគមន៍*** ត្រូវបានប្រកាសឱ្យប្រើក្នុងគោលបំណងជានា ១- ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញ និងការផ្តល់សេវាទូរគមនាគមន៍ប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព គុណភាព ភាពជឿទុកចិត្ត និងតម្លៃសមរម្យ ២- ការជំរុញនិងលើកទឹកចិត្តដល់វិស័យឯកជនឱ្យចូលរួមក្នុងការអភិវឌ្ឍវិស័យនេះ និង ៣-ការប្រកួតប្រជែងដោយសុចរិតនិងការពារអ្នកប្រើប្រាស់។

នៅឆ្នាំ២០១៦ រាជរដ្ឋាភិបាលបានអនុម័ត ***គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានឆ្នាំ២០២០*** ដោយបានដាក់ចេញនូវវិធានការនិងកំណត់គោលដៅក្នុងការពង្រឹងមូលដ្ឋាននៃការអភិវឌ្ឍវិស័យទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ពង្រឹងសន្តិសុខឌីជីថល ជំរុញការអភិវឌ្ឍឧស្សាហកម្ម និងលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។ លទ្ធផលនៃការអនុវត្តគោលនយោបាយនេះនៅមានកម្រិត និងមិនទាន់សម្រេចបានតាមគោលដៅ ដោយសារបញ្ហាប្រឈមផ្សេងៗ ដូចជា ធនធានថវិកា មូលធនមនុស្ស ជាដើម។

ចាប់តាំងពីឆ្នាំ២០១៨ រាជរដ្ឋាភិបាលបានចាត់ទុកការអភិវឌ្ឍឌីជីថលជាអាទិភាពសំខាន់ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ដើម្បីឆ្លើយតបនឹងនិន្នាការនៃបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤។ ផ្ដើមចេញពីនេះ រាជរដ្ឋាភិបាលបាននិងកំពុងរៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត សំដៅដាក់ចេញកម្មវិធីសេវាឌីជីថលប្រកបដោយគុណភាព ដោយមានការចូលរួមផ្ដល់មតិយោបល់ពីប្រជាពលរដ្ឋ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់។

នៅចុងឆ្នាំ២០១៩ កម្ពុជាបានអនុម័ត ***ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក*** ដែលកំណត់អំពីយថាភូតភាព សុក្រឹតភាព សុវត្ថិភាព និងភាពជឿទុកចិត្តនៃទម្រង់និងទំនាក់ទំនងអេឡិចត្រូនិក និង***ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់*** ដើម្បីលើកកម្ពស់ការប្រកួតប្រជែងដោយសុចរិត។ ជាមួយគ្នានោះដែរ កម្ពុជាក៏បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មក្នុងក្របខណ្ឌតំបន់ដូចជា ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់(RCEP) និងកិច្ចព្រមព្រៀងអាស៊ានស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលបានកំណត់កាតព្វកិច្ចរបស់កម្ពុជាក្នុងការអនុវត្តកិច្ចព្រមព្រៀងទាំងនោះ។ ក្រៅពីនេះ រាជរដ្ឋាភិបាលបាននិងកំពុងរៀបចំ ***សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន*** ក្នុងគោលដៅបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសបច្ចេកវិទ្យាព័ត៌មាន ***សេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខសាយប័រ*** ដើម្បីកំណត់គោលការណ៍ និងយន្តការបង្ការ គ្រប់គ្រង និងឆ្លើយតបចំពោះការគំរាមកំហែងសន្តិសុខឌីជីថលនិងឧប្បត្តិហេតុសន្តិសុខឌីជីថល និង ***សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន***ក្នុងគោលបំណងធានាដល់សាធារណជនគ្រប់រូបនូវសិទ្ធិសេរីភាពក្នុងការទទួលបានព័ត៌មានពីស្ថាប័នសាធារណៈ ស្របតាមស្មារតីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

គិតត្រឹមឆ្នាំ២០២០ មានគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលនិងប្រព័ន្ធព័ត៌មានឌីជីថលជាច្រើន ដូចជាការរៀបចំមជ្ឈមណ្ឌលទិន្នន័យចំនួន៣និងបន្ទប់សេវូបករណ៍នៅតាមក្រសួងស្ថាប័នចំនួន២០។ ក្រសួងស្ថាប័នបានរៀបចំបណ្ដាញផ្ទៃក្នុងនិងតភ្ជាប់បណ្ដាញអ៊ីនធឺណិតផ្ដល់ដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ឬក្រុមហ៊ុន ប៉ុន្តែមិនបានតភ្ជាប់ទៅគ្រប់នាយកដ្ឋានឬអង្គភាពពាក់ព័ន្ធមួយចំនួន។

នៅឆ្នាំ២០២១នេះ មានអ្នកចុះឈ្មោះប្រើប្រាស់សេវាអ៊ីនធឺណិតប្រមាណ១៧,៦៥លាន ក្នុងនោះអ្នកចុះឈ្មោះប្រើប្រាស់សេវាអ៊ីនធឺណិតចល័តមានប្រមាណ១៧,៣៥លាន(ដូចមានក្នុងតារាងទី១)។ ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍មិនទាន់គ្របដណ្ដប់នៅទូទាំងផ្ទៃប្រទេស ចំណែកបណ្ដាញខ្សែកាបអុបទិកឆ្អឹងខ្នងមានប្រមាណ៤៦ពាន់គីឡូម៉ែត្រ និងបណ្ដាញខ្សែកាបអុបទិកក្រោមបាតសមុទ្រចំនួន២ ក្នុងនោះ ខ្សែកាបអុបទិកក្រោមបាតសមុទ្រទី១ តភ្ជាប់កម្ពុជាទៅប្រទេសថៃនិងម៉ាឡេស៊ី(Malaysia Cambodia Thailand MCT) រីឯខ្សែទី២ តភ្ជាប់កម្ពុជាទៅប្រទេសចំនួន១៨ ក្នុងទ្វីបអាស៊ី អាហ្វ្រិក និងអឺរ៉ុប(Asia Africa Europe 1 AAE-1)។ បណ្ដាញទូរសព្ទចល័តជំនាន់ទី៤(4G) កំពុងផ្ដល់សេវាជូនប្រជាពលរដ្ឋប្រមាណ៨០%។

**តារាងទី១ : អត្រាអ្នកប្រើប្រាស់សេវាអ៊ីនធឺណិតនិងសេវាទូរគមនាគមន៍គ្របដណ្ដប់ឆ្នាំ២០២១**

| អត្រាអ្នកប្រើប្រាស់សេវាអ៊ីនធឺណិត | | | |
|---|---|---|---|
| ប្រតិបត្តិករ | ចំនួនអ្នកប្រើប្រាស់ | អត្រាក្នុង១០០នាក់ | ចំណែកទីផ្សារ |
| សេវាអ៊ីនធឺណិតចល័ត(៥ក្រុមហ៊ុន) | ១៧ ៣៤៩ ២៦១ | ១០៥,៦០ | ៩៨,៣០% |
| សេវាអ៊ីនធឺណិតអចល័ត(៣៥ក្រុមហ៊ុន) | ៣០៤ ០៧១ | ១,៨២ | ១,៧០% |
| សរុប | ១៧ ៦៥៣ ៣៣២ | ១០៧,៤២ | ១០០% |

# គោលនយោបាយ
# រដ្ឋាភិបាលឌីជីថលកម្ពុជា
# ២០២២-២០៣៥

ខែ មករា ឆ្នាំ ២០២២

# រាជរដ្ឋាភិបាលកម្ពុជា

# យុទ្ធសាស្ត្របញ្ចកោណ

## ដំណាក់កាលទី ១

## ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និង ចីរភាព
## កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០

## រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា

ធ្វើនៅ រាជធានីភ្នំពេញ, ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧
ត្រូវនឹង ខែសីហា គ្រិស្តសករាជ ២០២៣

# យុទ្ធសាស្ត្របញ្ចកោណ

## ដំណាក់កាលទី ១

## ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និង ចីរភាព

## កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេច

## ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០

ធ្វើនៅ រាជធានីភ្នំពេញ ខែស្រាពណ៍ ឆ្នាំថោះ ពុទ្ធសករាជ ២៥៦៧

ត្រូវនឹង ខែសីហា គ្រិស្តសករាជ ២០២៣

ទាបជាង ១០% និង បន្តខិតខំទាញទម្លាក់អត្រានៃភាពក្រីក្រ ឱ្យស្ថិតនៅក្នុងកម្រិតជាអប្បបរមា តាមរយៈ វិធានការបង្រួមវិសមភាពសេដ្ឋកិច្ច; ការអភិវឌ្ឍ និង ការកសាងប្រព័ន្ធគាំពារសង្គមឱ្យមានលក្ខណៈប្រមូលផ្ដុំ និង សង្គតិភាព; ការកាត់បន្ថយបន្ទុកជីវភាពប្រជាជន; និង ការផ្តល់សេវាសាធារណៈ ប្រកបដោយគុណភាព, ប្រសិទ្ធភាព និង បរិយាបន្ន ។

៤. បន្តពង្រឹងសមត្ថភាព អភិបាលកិច្ច និង លើកកម្ពស់គុណភាពស្ថាប័ន, ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពនៃសេវាសាធារណៈ; បន្តពង្រឹងអភិបាលកិច្ចវិស័យឯកជន; និង បន្តកិច្ចប្រឹងប្រែងលើកកម្ពស់បរិយាកាសអំណោយផល សម្រាប់ធុរកិច្ច, ការវិនិយោគ និង ពាណិជ្ជកម្ម ។

៥. ធានាចីរភាពនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និង កសាងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ដោយធ្វើបរមភាវូបនីយកម្ម (Optimization) ផលលាភប្រជាសាស្ត្រ និង ពង្រឹងភាពធន់នៃប្រជាសាស្ត្រ; លើកកម្ពស់សមភាពយេនឌ័រ; គ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព; បង្កើនហិរញ្ញប្បទានចីរភាព និង បៃតង នៅក្នុងបណ្ដុំកម្ចីសរុប ដើម្បីបង្កើនលំហូរហិរញ្ញវត្ថុឆ្ពោះទៅរកការវិនិយោគបៃតង និង សេដ្ឋកិច្ចបៃតង; ជំរុញការវិនិយោគសាធារណៈ ដែលមានភាពធន់នឹងអាកាសធាតុ និង មានការបញ្ចេញកាបូនទាប; និង ធានាចីរភាពបរិស្ថាន ព្រមទាំងត្រៀមខ្លួនជាស្រេច ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ។

## អាទិភាពគន្លឹះ ៥ រួមមាន ដូចខាងក្រោម ៖

នៅក្នុងការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ក្នុងរយៈកាលកន្លងមក, រាជរដ្ឋាភិបាលបានកំណត់យកអាទិភាពគន្លឹះ ចំនួន ៤ រួមមាន **មនុស្ស ផ្លូវ ទឹក** និង **ភ្លើង** ដើម្បីជំរុញការអភិវឌ្ឍប្រទេស ដែលលំដាប់នៃសារៈសំខាន់របស់អាទិភាពទាំងនេះ ត្រូវបានផ្លាស់ប្តូរទៅតាមដំណាក់កាលនីមួយៗ ។

**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** កំណត់យកអាទិភាពគន្លឹះចំនួន ៥ ដោយបន្ថែមបច្ចេកវិទ្យា និង បន្តកំណត់យក **មនុស្ស** ជាអាទិភាពទី ១ ហើយ **ផ្លូវ ទឹក ភ្លើង** និង **បច្ចេកវិទ្យា** គឺជាអាទិភាព បន្តបន្ទាប់តាមលំដាប់ ។ ក្នុងន័យនេះ, បញ្ចកោណយុទ្ធសាស្ត្រ ទាំង ៥ ត្រូវបានគិតគូរឡើងវិញ ទៅតាមអាទិភាពខាងលើ ដោយរៀបចំឱ្យមានលក្ខណៈប្រទាក់ក្រឡាគ្នា ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និង ទិសដៅនៃការអភិវឌ្ឍកម្ពុជា ក្នុងដំណាក់កាលថ្មីខាងមុខ ។ អាទិភាព **"មនុស្ស"** ត្រូវបានឆ្លុះបញ្ចាំងជាចម្បង ក្នុងបញ្ចកោណទី ១ និង បំពេញបន្ថែមដោយមុំទី ១ នៃបញ្ចកោណទី ៣, មុំទី ១ នៃបញ្ចកោណទី ៤, និង មុំទី ១ នៃបញ្ចកោណទី ៥ ។ អាទិភាព **"ផ្លូវ ទឹក និង ភ្លើង"** ត្រូវបានរៀបចំជាចម្បង ក្នុងមុំទី ២ នៃបញ្ចកោណទី ២ និង មានលក្ខណៈបំពេញគ្នា ក្នុងចំណោមមុំផ្សេងទៀតនៃបញ្ចកោណនេះផង ហើយប្រទាក់គ្នាទៅនឹងមុំទី ៣ និង មុំទី ៤ នៃបញ្ចកោណទី ៤ ផង ។ អាទិភាព **"បច្ចេកវិទ្យា"** ត្រូវបានផ្តោតជាសំខាន់ក្នុងបញ្ចកោណទី ៥, ជាពិសេស ការកសាង និង ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដែលមាននៅក្នុងមុំទី ៣ និង មានភាពប្រទាក់ក្រឡាយ៉ាងស្អិតរមួត ក្នុងគ្រប់មុំនៃបញ្ចកោណទាំង ៤ ផ្សេងទៀត ។ ជារួម, អាទិភាពគន្លឹះទាំង ៥ ក្នុង ទម្រង់ **"បញ្ចកោណយុទ្ធសាស្ត្រ"** ត្រូវបានរៀបចំ ដូចខាងក្រោម ៖

**បញ្ចកោណទី ១ ៖ ការអភិវឌ្ឍមូលធនមនុស្ស :** (១). ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា; (២). ការបណ្តុះបណ្តាលជំនាញបច្ចេកទេស; (៣). ការលើកកម្ពស់សុខភាព និង សុខុមាលភាពប្រជាជន; (៤). ការពង្រឹងប្រព័ន្ធគាំពារសង្គម និង ប្រព័ន្ធស្បៀង; និង (៥). ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌, សមធម៌ និង បរិយាបន្ន ។

**បញ្ចកោណទី ២ ៖ ការធ្វើពិពិធកម្មសេដ្ឋកិច្ច និង ការបង្កើនភាពប្រកួតប្រជែង :** (១). ការអភិវឌ្ឍវិស័យគន្លឹះ និង ប្រភពថ្មី នៃកំណើនសេដ្ឋកិច្ច;

និង ការប្រកបមុខរបររបស់ជនបរទេស; និង ការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យអន្តោប្រវេសន៍ សំដៅបង្ការ និង ទប់ស្កាត់ ការលបលួចជ្រៀតចូល, ការស្នាក់នៅ និង ការប្រកបមុខរបរ ដោយខុសច្បាប់ ។

ទី៩- ការពង្រឹង ការអនុវត្តច្បាប់ និង ការកសាងសមត្ថភាព ដើម្បីទប់ស្កាត់បទល្មើស តាមប្រព័ន្ធបច្ចេកវិទ្យា ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

ទី១០- ការជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម ឆ្នាំ ២០១៧-២០២៦ ដោយបង្កើតឱ្យមានមជ្ឈមណ្ឌលជាតិគ្រប់គ្រងទិន្នន័យប្រជាជន; រៀបចំឱ្យប្រើប្រាស់លេខសម្គាល់អត្តសញ្ញាណបុគ្គល; និង ជំរុញការអនុវត្តច្បាប់ស្តីពីអត្រានុកូលដ្ឋាន, ស្ថិតិអត្រានុកូលដ្ឋាន និង អត្តសញ្ញាណកម្ម, និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

### មុំទី២. ការប្រកាន់ខ្ជាប់នូវនយោបាយការបរទេសឯករាជ្យ, ផ្អែកលើច្បាប់ និង ឈ្លាសវៃ

គោលដៅជាយុទ្ធសាស្ត្រ គឺការបន្តពង្រឹងការអនុវត្តនយោបាយការបរទេសឯករាជ្យ ផ្អែកលើច្បាប់ ក្នុងកិច្ចការពារ និង ក្នុងការជំរុញបង្កើនផលប្រយោជន៍ស្នូលរបស់ជាតិ; និង ការកសាងមិត្តភាព និង កិច្ចសហប្រតិបត្តិការប្រសើរ ជាមួយប្រទេសទាំងអស់នៅលើសកលលោក និង អង្គការអន្តរជាតិនានា; ព្រមទាំងការចូលរួមយ៉ាងសកម្ម ចំពោះបុព្វហេតុសន្តិភាព, ស្ថិរភាព, សន្តិសុខ និង វិបុលភាព ក្នុងតំបន់ និង សកលលោក ស្របតាមអភិក្រម **"រក្សាចាស់, បង្កើតថ្មី"** ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការបន្តអនុវត្តនយោបាយការបរទេសឯករាជ្យ ដោយផ្អែកលើច្បាប់អន្តរជាតិ និង គោរពដាច់ខាតនូវ អធិបតេយ្យ, បូរណភាពទឹកដី និង ឯករាជ្យរបស់រដ្ឋសមាជិក អនុលោមតាមធម្មនុញ្ញអង្គការសហប្រជាជាតិ និង គោលការណ៍ដែលទទួលស្គាល់ជាសកល ។

ប្រសិទ្ធភាព ។

ទី២- ការបន្តជំរុញ និង កសាងហេដ្ឋារចនាសម្ព័ន្ធទឹក រួមទាំងប្រព័ន្ធប្រព្រឹត្តកម្ម ដើម្បីធានានូវសន្តិសុខទឹក និង ចីរភាពបរិស្ថាន, និង ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ។

ទី៣- ការបន្តបង្កើនការប្រើប្រាស់បច្ចេកវិទ្យា ភាគរបរិស្ថាន និង ភាគរ-អាកាសធាតុ ដូចជា បច្ចេកវិទ្យា, ដំណោះស្រាយតាមបែបធម្មជាតិ, និង ការ-ប្រើប្រាស់ម៉ូដែល និង បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត ទៅក្នុងការគ្រប់គ្រង សុវត្ថិ-ភាព ទឹក និង បរិស្ថាន ជាដើម ។

ទី៤- ការបន្តពង្រឹងក្របខ័ណ្ឌគតិយុត្ត និង គោលនយោបាយពាក់ព័ន្ធបរិស្ថាន ទឹក និង គ្រោះមហន្តរាយធម្មជាតិ ក៏ដូចជា ការងារការទូតបៃតង ដើម្បីធានានិរន្តរភាពប្រព័ន្ធអេកូឡូស៊ី និង ការរួមចំណែកក្នុងការកាត់បន្ថយការប្រែ-ប្រួលអាកាសធាតុ ។

ទី៥- ការបន្តអភិវឌ្ឍ សមត្ថភាពជំនាញ និង ចំណេះដឹងបច្ចេកទេស ព្រមទាំងការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ លើផ្នែកបរិស្ថាន, ការអភិវឌ្ឍបៃតង, សន្តិសុខទឹក, ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់, ការបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ, និង ការប្រើប្រាស់ធនធានធម្មជាតិ ប្រកបដោយចីរភាព; និង ការចងក្រងផលិតឯកសារឧបទេស សម្រាប់ការអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋទូទៅ ដើម្បីជំរុញ និង លើកទឹកចិត្តការចូលរួមអនុវត្ត សាលារៀន និង អារាម ភាគរបរិស្ថាន និង គោលនយោបាយភូមិ-ឃុំ-សង្កាត់ មានសុវត្ថិ-ភាព ប្រកបដោយ អនាម័យ, សោភ័ណភាព និង បរិស្ថានល្អ ។

### បញ្ចកោណទី៥. ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល

រាជរដ្ឋាភិបាល បានចាត់ទុកបច្ចេកវិទ្យាឌីជីថលជាកាតាលីករថ្មីដ៏មានសារៈសំខាន់ ដែលមានសក្តានុពលភាព និង កាលានុវត្តភាព ក្នុងការជំរុញកំណើនផលិតភាពសេដ្ឋកិច្ច និង សង្គម ក៏ដូចជាប្រសិទ្ធភាពនៃការងាររដ្ឋបាល ។

ឌីជីថល ។

ទី៤- ការរៀបចំក្របខ័ណ្ឌវាយតម្លៃឡើងវិញនូវចន្លោះប្រហោង និង ការពង្រឹងប្រព័ន្ធសន្តិសុខឌីជីថលសម្រាប់ហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ។

ទី៥- ការបណ្តុះបណ្តាល និង ការបង្កើនការអភិវឌ្ឍ ជំនាញសន្តិសុខឌីជីថល, និង ការលើកកម្ពស់ការយល់ដឹងអំពីបញ្ហាសន្តិសុខឌីជីថល ដើម្បីបញ្ជ្រាបការយល់ដឹងជាសាធារណៈ អំពីបញ្ហាសន្តិសុខឌីជីថល និង កិច្ចការពារខ្លួន និង ការប្រឆាំងបទល្មើសបច្ចេកវិទ្យាព័ត៌មាន ។

ទី៦- ការបង្កើតយន្តការនៃកិច្ចសហការ និង កិច្ចសហប្រតិបត្តិការជាមួយនឹងស្ថាប័នពាក់ព័ន្ធ, ទាំងរដ្ឋ វិស័យឯកជន និង ប្រជាជន, ដើម្បីចូលរួមពារការណ៍, ទប់ស្កាត់, បំពាក់សុវត្ថិភាពក្នុងប្រព័ន្ធឌីជីថល និង ឈានឆ្ពោះទៅដល់ការបង្ក្រាបទាន់ពេល នូវបទល្មើសបច្ចេកវិទ្យាព័ត៌មាន ។

ទី៧- ការបង្កើតក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ, ទាំងក្នុងតំបន់ និង ជាសកល, ក្នុងការចែករំលែកព័ត៌មាន និង ការគ្រប់គ្រងហានិភ័យពាក់ព័ន្ធនឹងសន្តិសុខឌីជីថល ក្នុងបរិការណ៍តំបន់ និង សកល ។

### មុំទី៥. ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ

គោលដៅជាយុទ្ធសាស្ត្រ គឺការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ដោយចាប់យកកាលានុវត្តភាព និង ទាញយកអត្ថប្រយោជន៍ជាអតិបរមាពីបច្ចេកវិទ្យាឌីជីថល ដើម្បីលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ, រក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ, និង ជំរុញការនវានុវត្តហិរញ្ញវត្ថុ តាមរយៈ ការអនុវត្ត "គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨" ។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលផ្តោតអាទិភាពលើ ៖

ទី១- ការរៀបចំ ការធ្វើវិសោធនកម្ម និង ការពង្រឹងប្រសិទ្ធភាព នៃការអនុវត្តច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីកសាងប្រព័ន្ធអេកូឡូស៊ីគតិយុត្ត សម្រាប់ការធ្វើនិយ័តកម្ម, ការធ្វើសុខដុម-

# គំនូរបំព្រួញស្តីពី «យុទ្ធសាស្ត្របញ្ចកោណ - ដំណាក់កាលទី ១»
## ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និង ចីរភាព : កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០



# ឧបសម្ព័ន្ធរូបភាព

អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល
និងផ្សព្វផ្សាយអប់រំ ក្រសួងមហាផ្ទៃ

# ទំនើបកម្ម កំណើន និងកង្វះការយល់ដឹង នៃការប្រើប្រាស់បច្ចេកវិទ្យា បង្កឱ្យលេចឡើងនូវបទល្មើសថ្មីប្លែក។

## តើភាពងាយរងគ្រោះនៃបទល្មើសបច្ចេកវិទ្យា បណ្តាលមកពីកត្តាអ្វីខ្លះ?

តាមរយៈការសិក្សា កត្តារួមផ្សំមួយចំនួនដែលធ្វើឱ្យបទល្មើសបច្ចេកវិទ្យា មានការកើនឡើង ក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាក្នុងតំបន់ មានដូចជា៖

1- តម្រូវការ និងកំណើននៃការប្រើប្រាស់បច្ចេកវិទ្យាពីសំណាក់អង្គភាពពាក់ព័ន្ធ ពិសេសប្រជាពលរដ្ឋទូទៅ

2- កង្វះការយល់ដឹង ឬភាពធ្វេសប្រហែសលើហានិភ័យនៃការប្រើប្រាស់បច្ចេកវិទ្យា និងបច្ចេកទេសការពាររួម ទាំងកម្រិតស្ថាប័ន និងបុគ្គល

3- កត្តាច្បាប់ បទដ្ឋានគតិយុត្ត និងយន្តការពាក់ព័ន្ធនានា ដើរពុំទាន់បរិបទនៃបច្ចេកវិទ្យា (ដោយមើលឃើញបញ្ហាទាំងនេះ រាជរដ្ឋាភិបាល តាមរយៈអង្គភាពជំនាញកំពុងធ្វើសេចក្តីព្រាងច្បាប់ បទដ្ឋានគតិយុត្ត និងយន្តការពាក់ព័ន្ធនានា តួយ៉ាងច្បាប់ប្រឆាំងបទល្មើសបច្ចេកវិទ្យាព័ត៌មាន ច្បាប់ស្តីពីកិច្ចគាំពារអត្តសញ្ញាណបុគ្គល និងច្បាប់សន្តិសុខបច្ចេកវិទ្យា ជាដើម)

4- ភាពអំណោយផលនៃប្រតិបត្តិការផ្ទេរប្រាក់ (Crypto Currency / Digital Payment / Payment System / Bank Transfer)

5- ឧក្រិដ្ឋជនបច្ចេកវិទ្យា ប្រើប្រាស់វិធីសាស្ត្រ បច្ចេកទេសខ្ពស់ និងស្មុគស្មាញក្នុងការប្រព្រឹត្តិបទល្មើស

6- ឧក្រិដ្ឋជនចាប់ផ្តើមប្រព្រឹត្តិបទល្មើស ស្ថិតក្រោមរចនាសម្ព័ន្ធចាត់តាំង

## បទល្មើសបច្ចេកវិទ្យាធំៗ នៅកម្ពុជារបាយការណ៍សង្ខេបអំពីបទល្មើសបច្ចេកវិទ្យាធំៗទាំង៧ ក្នុងព្រះរាជាណាចក្រកម្ពុជា ៖

1. បទល្មើសឆបោកប្រាក់ (Money Deposit / Flipping Scam)
2. បទល្មើសលួចកាន់កាប់គណនីអនឡាញខុសច្បាប់ (Account Phishing / Hijacking)
3. បទល្មើសបរិហាកេរ្តិ៍ /សម្លុតឬយាយី (Cyber Defamation / Harrasment / Bully)
4. បទល្មើសថតសកម្មភាពអាក្រាតជម្រិតទារប្រាក់ (Sextortion)
5. បទល្មើសចម្លងមេរោគ /ជម្រិតទារប្រាក់ (Malware/Ransomware)
6. បទល្មើសបន្លំលួចប្រាក់តាមប្រព័ន្ធបច្ចេកវិទ្យា (Money Fraud)
7. បទល្មើសជ្រៀតចូលប្រព័ន្ធដោយខុសច្បាប់ (System Compromise / Hacking)




## តើអ្វីជាមូលដ្ឋាននៃឧក្រិដ្ឋវិទ្យាបច្ចេកវិទ្យា?

ដើម្បីដោះស្រាយសមីកា បទល្មើសបច្ចេកវិទ្យា (Cybercrime) កម្រិត ថ្នាក់ជាតិ និងតំបន់ ប្រកបដោយប្រសិទ្ធភាព យន្តការនៃកិច្ចសហប្រតិបត្តិការ បទដ្ឋានបច្ចេកទេស និងច្បាប់ គឺជាធាតុផ្សំសំខាន់ដែលមន្ត្រីអនុវត្តច្បាប់ត្រូវការជាចាំបាច់។ ទោះជាយ៉ាងណាក៏ដោយ ភាពជឿនលឿននៃបច្ចេកវិទ្យា ប្រភពហិរញ្ញវត្ថុ និងបច្ចេកទេសនៃឧក្រិដ្ឋជន បានធ្វើឲ្យបទល្មើសបច្ចេកវិទ្យាថ្មីៗ ប្លែកៗកើតមានឡើងជារៀងរាល់ថ្ងៃ ជាហេតុធ្វើឲ្យការបង្ការបង្ក្រាប និងកិច្ចការស្រាវជ្រាវកាន់តែលំបាកទៅៗ។ បើទោះបីជាយ៉ាងនេះក្តី ដើម្បីកសាងនូវយន្តការដ៏មានប្រសិទ្ធភាពក្នុងការប្រយុទ្ធប្រឆាំងនឹងបទល្មើសបច្ចេកវិទ្យា ថ្នាក់ជាតិ និងតំបន់ អ្នកជំនាញអាចធ្វើការដោះស្រាយសមីកាបទល្មើសឈរលើមូលដ្ឋាននៃឧក្រិដ្ឋវិទ្យា (Criminology) ដែលមាន**ធាតុផ្សំចម្បងចំនួន ៣គឺ៖**

1. ការសិក្សាលើបទដ្ឋាន បទបញ្ញាតិ និងច្បាប់ប្រឆាំងបទល្មើសបច្ចេកវិទ្យា (កម្ពុជាប្រើប្រាស់ក្រមព្រហ្មទណ្ឌ និងច្បាប់ពាក់ព័ន្ធមួយចំនួន)
2. ការសិក្សាពីប្រភពឬសគលនៃបទល្មើស និងឧក្រិដ្ឋជន
3. ការសិក្សាលើយន្តការគ្រប់គ្រង និងការស្តាស្ថានភាពបទល្មើស (ជនរងគ្រោះ និងឧក្រិដ្ឋជន)។

ដូច្នេះដើម្បីចូលរួមកាត់បន្ថយភាពងាយរងគ្រោះនៃបទល្មើសបច្ចេកវិទ្យា ពលរដ្ឋគ្រប់រូបគួរស្វែងយល់អំពីបច្ចេកវិទ្យា ហានិភ័យពាន់ព័ន្ធ ដោយធ្វើការអាន ស្តាប់ ទស្សនាវីដេអូ សិក្សាស្វែងយល់ លើអត្ថបទកាសែត អត្ថបទអប់រំ វីដេអូអប់រំ ព័ត៌មានពាក់ព័ន្ធផ្សេងៗ និងបន្តផ្សព្វផ្សាយអប់រំ ចែករំលែកជូនដល់សាច់ញាតិ បងប្អូន មិត្តភក្តិ ព្រមទាំងចូលរួមធ្វើសេចក្តីរាយការណ៍ជូនសមត្ថកិច្ចពាក់ព័ន្ធ ក្នុងករណីជួបប្រទះ ឬសង្ស័យថាជា បទល្មើសបច្ចេកវិទ្យា។

ទាញយកកម្មវិធី ក្រសួងមហាផ្ទៃ

ANDROID APP ON Google play

Download on the App Store

GD DTM